01096406

E1/296.1/Old-3

OLD VERSION

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 12-May-2015, 10:06

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៧៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឯម ហ៊ាយ

កញ្ញា រ៉ូប៊ីនី ក្រហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អារុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ម៉ម រិទ្ធា | ខ្មែរ |
| លោកស្រី ខឹម បឿន (2-TCW-979) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ខឹម បឿន ហៅ យាយបឿន** (2-TCW-979)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ទំព័រ ៣
សួរដោយលោក សេង លាង ផ្ដើមពី ........ទំព័រ ៨
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........ទំព័រ ២១
សួរដោយលោកស្រី ម៉ារីហ្គីរ៉ូដ៍ ផ្ដើមពី ........ទំព័រ ៦៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-979 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបងមកជាមួយនឹង អ.វ.ត.ក។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន លើកលែងតែលោក អាកទូវ វែកគែន និងលោកស្រី អង់តាហ្គីសសេ មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមាននៅក្នុងសប្តាហ៍នេះ ដោយលោកទាំងពីរមានធុរៈផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-979។ សាក្សីរូបនេះនឹងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយកាលពីព្រឹកមិញនេះមុននឹងផ្តល់សក្ខីកម្ម ហើយសាក្សីនឹងមានមេធាវីប្រឹក្សាគឺលោក ម៉ម រិទ្ធា។ តាមការបញ្ជាក់ពីខាងបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះ គឺបានរៀបចំរួចរាល់ហើយ ហើយសាក្សីក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនេះផងដែរ។

សូមអរគុណលោកប្រធាន។

[០៩:០៦:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនចាប់ចោទ នួន ជា ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះខ្លាំង ពិបាកអង្គុយ និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការ។

[០៩:០៨:២៧]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី តើលោកស្រីឈ្មោះអី?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ខ្ញុំឈ្មោះ ខឹម បឿន។

**ប្រធានអង្គជំនុំ៖**

សូម១ផ្អាកបន្តិចលោកស្រី ខឹម បឿន។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[០៩:០៩:៤០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ មុននឹងអង្គជំនុំជម្រះចាប់ផ្តើមសួរទៅលើសាក្សី ខ្ញុំបាទសូមការបំភ្លឺពីអង្គជំនុំជម្រះ ទាក់ទងទៅនឹងមូលហេតុដែលនាំឲ្យមានការជំនុំជម្រះតាមរយៈវីដេអូលីងនេះ។ ដោយខ្ញុំបានពិនិត្យឃើញទៅលើអ៊ីម៉ែលរបស់អង្គជំនុំជម្រះតាមរយៈមន្ត្រីច្បាប់ពីថ្ងៃទី២៤ ខែ៤ ឆ្នាំ២០១៥ បានបញ្ជាក់អំពីសាក្សីពីររូបដែលត្រូវឡើងមកបំភ្លឺនៅសប្តាហ៍នេះតាមរយៈវីដេអូលីង ក៏ប៉ុន្តែក្នុងអ៊ីម៉ែលនោះក៏មិនបានបញ្ជាក់ពីមូលហេតុ ដែលនាំឲ្យមានការរៀបចំសវនាការតាមរយៈវីដេអូលីងនេះដែរ។ ហើយកាលពីសប្តាហ៍មុនអង្គជំនុំជម្រះក៏បានជូនដំណឹងនៅក្នុងពេលសវនាការ គឺនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ដែលបានអញ្ជើញភាគីឲ្យមកចូលរួមសវនាការដែលមានបញ្ជាក់អំពីសាក្សីដែលត្រូវផ្តល់សក្ខីកម្មតាមរយៈវីដេអូលីងនេះដែរ ក៏ប៉ុន្តែមិនមានការបញ្ជាក់អំពីមូលហេតុថាហេតុអ្វីបានត្រូវរៀបចំធ្វើជាវីដេអូលីងនេះទេ។ កាលពីប៉ុន្មានសប្តាហ៍មុនខ្ញុំចាំបានថា អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់អំពីបញ្ហាសុខភាពទៅលើសាក្សីម្នាក់ចាំឆ្លើយនៅមុខអង្គជំនុំជម្រះ ហើយត្រូវគាត់មានបញ្ហាសុខភាពបញ្ជូនត្រឡប់ទៅវិញ។ ដោយហេតុនេះ ខ្ញុំបាទសូមអង្គជំនុំជម្រះមេត្តាជួយបញ្ជាក់ទៅលើចំណុចនេះផង ពីព្រោះថាវាមានភាពពាក់ព័ន្ធសំខាន់សម្រាប់មេធាវី -- សម្រាប់ជនជាប់ចោទនៅក្នុងការតទល់ជាមួយនឹងសាក្សីនៅអង្គជំនុំជម្រះនៅក្នុងបន្ទប់សវនាការនេះជៀសជាងតាមរយៈវីដេអូ។ ដូច្នេះ បើសិនជាអង្គជំនុំជម្រះមានមូលដ្ឋានអ្វីដែលបញ្ជាក់អំពីហេតុផលដែលនាំឲ្យមានការរៀបចំវីដេអូលីងនេះ សូមអង្គជំនុំជម្រះជួយបំភ្លឺ។ បាទ សូមអរគុណ។

[០៩:១២:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ជូនលោកមេធាវីនិងភាគីជ្រាបថា សាក្សីទាំងពីរនេះមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលគាត់មិនអាចមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះបាន។ ហើយបញ្ហាជម្រើសដែលអង្គជំនុំជម្រះជ្រើសទី១ គឺលះបង់បោះបង់ចោលនូវការស្តាប់សក្ខីកម្មនូវសាក្សីដែលមានបញ្ហាសុខភាពនេះ។ បញ្ហាទី២ កិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះពិនិត្យលទ្ធភាពតាមសំណើសុំរបស់គាត់ ហើយនិងយើងទៅវាយតម្លៃដោយមានខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញទៅជួយ គឺពិនិត្យវាយតម្លៃដោយមានគ្រូពេទ្យឯករាជ្យធ្វើការសន្និដ្ឋានវាយតម្លៃ ថាបញ្ហាសុខភាពគាត់ពិតជាមានពិតប្រាកដ ដូចអ្វីដែលអង្គជំនុំជម្រះបានជួបចំពោះសក្ខីកម្មសាក្សី 822 កន្លងមក។ ហើយដើម្បីឱ្យដំណើរការនេះអាចប្រព្រឹត្តទៅបាន ដោយសារសក្ខីកម្មរបស់អ្នកទាំងពីរតាមពិនិត្យឯកសារបឋមដែលសាកសួរសក្ខីកម្ម ដោយក្រុមអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត និងឯកសារពាក់ព័ន្ធ ឃើញថាវាមានសារប្រយោជន៍នៅក្នុងរួមវិភាគទានក្នុងការស្វែងរកការពិតនេះ។ ហេតុដូច្នេះហើយ ទើបអង្គជំនុំជម្រះសម្រេចវាយតម្លៃបង្គាប់ឱ្យខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញធ្វើការវាយតម្លៃពិនិត្យបញ្ហាសុខភាពថា តើធ្ងន់ធ្ងរអាចរហូតដល់ថាមិនចាំបាច់សក្ខីកម្មឬក៏យ៉ាងណា? ប៉ុន្តែពេលយើងវាយតម្លៃទៅឃើញថា សុខភាពរបស់គាត់ហ្នឹងអាចធ្វើការពីចម្ងាយបាន ហើយតាមសំណើរបស់គាត់ ហេតុដូច្នេះហើយទើបអង្គជំនុំជម្រះព្យាយាមដើម្បីធ្វើយ៉ាងណាឱ្យដំណើរការនៃសវនាការនេះបានស្តាប់ មានឱកាសស្តាប់នូវកសក្ខីកម្មសាក្សីពីររូបដែលមានសារៈសំខាន់នេះ តាមរយៈមធ្យោបាយសោតទស្សន៍។ ទាំងតាមសំណូមពររបស់គាត់ ទាំងការសន្និដ្ឋានវាយតម្លៃរបស់គ្រូពេទ្យឯករាជ្យមួយដែលវាយតម្លៃពិនិត្យសុខភាពរបស់គាត់។

[០៩:១៩:១៧]

អ៊ីចឹងយើងធ្វើគឺថា លក្ខខណ្ឌនេះគឺយើងធ្លាប់បានធ្វើកន្លងមកនៅក្នុងសំណុំរឿង ពីមុនក៏យើងធ្លាប់បានធ្វើរបៀបនេះដែរ។ ហើយអង្គជំនុំជម្រះព្យាយាមណាស់ ជៀសវាងលើបញ្ហាលទ្ធភាពបែបនេះ ប៉ុន្តែការព្យាយាមគឺជម្រើសយើងចុងក្រោយគឺយើងនៅតែទទួលយកនូវសំណើសុំបែបនេះដើម្បីឱ្យដំណើរការអាចស្តាប់សក្ខីកម្មប្រភេទនេះបាន ដោយសារមូលហេតុចាស់ជរា ហើយនិងមូលហេតុសុខភាព។

*(សម្រាករយៈពេលខ្លី)*

[០៩:១៩:៥៥]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរគុណលោកស្រី ខឹម បឿន តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំបានដែរឬទេ អាចប្រាប់តុលាការបានទេ?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ខ្ញុំកើតឆ្នាំប៉ុន្មាន ភ្លេច ភ្លេចឆ្នាំហើយ។ តែដល់ឥឡូវនេះ៧២ ហើយអាយុ។

**ស៖** បាទ អរគុណ។ លោកស្រីមានអាយុ៧២ឆ្នាំហើយ ឆ្នាំនេះ។ ហើយលោកស្រីកើតទីកន្លែងណាលោកស្រីចាំដែរឬទេ?

**ឆ៖** កំណើតខ្ញុំកើតនៅឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ លោកស្រី ខឹម បឿន តើទីលំនៅសព្វថ្ងៃ តើលោកស្រីរស់នៅកន្លែងណា?

**ឆ៖** ខេត្តបាត់ដំបង ចាស។

**ស៖** លោកស្រីអាចប្រាប់ស្រុកបានទេ នៅឃុំអី ស្រុកអីបានទេ?

[០៩:១៦:០២]

**ឆ៖** ស្រុកសំពៅលូន ចាស។

**ស៖** ឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ឃុន។ ម្តាយឈ្មោះ ជា។

**ស៖** ស្វាមីរបស់លោកស្រីឈ្មោះអី ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស ស្វាមីខ្ញុំឈ្មោះ ចន។ មានកូនបួននាក់ ចាស។

**ស៖** លោកស្រី ខឹម បឿន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកស្រីមិនមានឪពុកម្តាយ បុព្វញាតិ កូន បច្ឆាជាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ -- ប្តី ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី០០២នេះទេ។ តើពិតដែរឬទេ?

**ឆ៖** ចាស ពិត។

**ស៖** ហើយរបាយការណ៍របស់លោកក្រឡាបញ្ជីថា លោកស្រីបានស្បថហើយមុននឹងមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះដែលបានរៀបចំតាមរយៈសោតទស្សន៍ពីកន្លែងដែលលោកស្រីស្នាក់នៅនាពេលនេះ តើជាការពិតដែរឬទេ?

**ឆ៖** ចាស ការពិត។

[០៩:១៧:២៣]

**ស៖** ជាបន្តទៅនេះអង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីរបស់លោកស្រីក្នុងឋានៈជាសាក្សី អំពីសិទ្ធិលោកស្រី ខឹម ហឿន ក្នុងឋានៈជាលោកស្រីក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលោកខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកស្រីនោះនាំឲ្យលោកស្រីនឹងត្រូវរងការចោទប្រកាន់។

អំពីករណីយកិច្ច លោកស្រី ខឹម ហឿន នៅក្នុងនាមលោកស្រីជាសាក្សីត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះ លោកស្រីត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លោកលែងតែសំណួរដែលនាំឲ្យលោកស្រីឆ្លើយតប ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើននាំឲ្យដាក់ពិរុទ្ធភាពខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោកស្រីរួចមកហើយអម្បាញ់មិញនេះ។ ក្នុងនាមលោកស្រីជាសាក្សី ត្រូវតែឆ្លើយការណ៍ដែលពិតដែលលោកស្រីបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោកស្រី។ តើលោកស្រីយល់អំពីសិទ្ធិ និងករណីក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះទេ?

**ឆ៖** ចាស យល់ខ្លះ ប៉ុន្តែស្តាប់មិនបានខ្លះ។

[០៩:១៩:០៥]

**ស៖** លោកស្រី ខឹម ហឿន តើលោកស្រីដែលធ្លាប់ផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក? ប្រសិនបើមានតើធ្វើប៉ុន្មានដង? ធ្វើនៅទីណា?

**ឆ៖** ចាស ធ្លាប់ ធ្លាប់មាន ចាស។ ធ្វើនៅភ្នំពេញ។

**ស៖** ប៉ុន្មានដងដែរលោកស្រី?

**ឆ៖** ម្តង ចាស។

**ស៖** នៅមុនពេលចូលចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកស្រី ខឹម ហឿន បានពិនិត្យ

មើល ឬក៏អានន្ទូវកំណត់ហេតុដែលលោកស្រីបានផ្តល់ចម្លើយកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ផ៖** ចាស បានអាន តែមិនអានសព្វ ព្រោះយើងមើលមិនអស់ មើលមិនឃើញ។

**ស៖** បាទ អរគុណលោកស្រី ខឹម បឿន។ តាមសមត្ថភាពដែលលោកស្រីអាចដឹងនិងចងចាំ តើអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬក៏សមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកស្រីបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

[០៩:២០:៣៦]

**ផ៖** ចាស។

**ស៖** លោកស្រី ខឹម បឿន នៅពេលនេះលោកស្រីបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះផ្តល់ឲ្យលោកស្រីតាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញតាមសំណើរបស់លោកស្រី គឺមេធាវីលោក ម៉ម រិទ្ធា។ តើលោកស្រីបានមានវត្តមានលោក ម៉ម រិទ្ធា នៅជិតលោកស្រីទេ ហើយលោកស្រីបានប្រឹក្សាយោបល់ជាមួយមេធាវីប្រឹក្សាលោកស្រីរួចហើយ ឬនៅនាពេលនេះ?

**ផ៖** ចាស បាននៅជិត។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះការសួរដេញដោលចំពោះសាក្សីរូបនេះដែលអនុវត្តតាមបទប្បញ្ញត្តិ នៃវិធាន ៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជ អាជ្ញាសួរដេញដោលសាក្សី ខឹម បឿន មុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:២១:៥០]

**លោក សេង លាង៖**

អរគុណលោកប្រធាន។ សូមគោរពលោក លោកស្រី ចៅក្រម លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការនាពេលនេះ។

## ការតាំងសំណួរដោយសហព្រះរាជអាជ្ញា

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកស្រី សាក្សី ខ្ញុំបាទ ឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះ ខ្ញុំមានសំណួរទៅលើប្រធានចំនួនបីដើម្បីជូនទៅអ្នកស្រី ឲ្យជួយបំភ្លឺដល់អង្គសវនាការពាក់ព័ន្ធជាមួយនឹងប្រវត្តិមុនឆ្នាំ១៩៧៥ និងតួនាទី និងសិទ្ធិអំណាចនៅពេលដែលលោកស្រីត្រូវបានតែងតាំងជាមេឃុំជាងទង និងរចនាសម្ព័ន្ធរបស់ឃុំជាងទង និងប្រធានបទមួយទៀតពាក់ព័ន្ធជាមួយនឹងការរៀបការដោយបង្ខំ។ បន្ទាប់មក សហសេវិកអន្តរជាតិរបស់ខ្ញុំគឺលោក វាំង សង់ និងមានសំណួរមួយចំនួនពាក់ព័ន្ធជាមួយកិច្ចប្រជុំនានា និងសំណួរផ្សេងៗទៀតដើម្បីឲ្យលោកស្រីជួយបំភ្លឺផងដែរ។ ជាការចាប់ផ្ដើម ឥឡូវនេះខ្ញុំសូមផ្ដើមនូវសំណួររបស់ខ្ញុំជាមួយនឹងប្រវត្តិមុនឆ្នាំ១៩៧៥។ តើលោកស្រីអាចប្រាប់បានទេ ថាតើលោកស្រីរស់នៅឯណាមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ខ្ញុំ ចាសខ្ញុំរស់នៅ ឃុំជាងទង ភូមិក្បាលអូរ។

**ស៖** អរគុណលោកស្រី។ តើនៅពេលណាដែលពួកខ្មែរក្រហមបានចូលមកកាន់កាប់តំបន់របស់លោកស្រី?

**ឆ៖** ខ្មែរក្រហមបានចូលកាន់កាប់តាំងពីឆ្នាំ៧១។

[០៩:២៣:៤៣]

**ស៖** អរគុណលោកស្រី។ នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកស្រីគឺឯកសារ E319/12.3.2 នៅត្រង់ចម្លើយលេខ១៣៩ លោកស្រីបាននិយាយថា ខ្ញុំសូមដកស្រង់៖ "រហូតដល់ឆ្នាំ១៩៦៩ ទើបខ្ញុំទៅភូមិកំណើតវិញដោយខ្ញុំបានលក់ផ្ទះនៅទីក្រុងភ្នំពេញចោល"។ សូមលោកស្រីជួយបញ្ជាក់មើលថាតើលោកស្រីត្រឡប់ទៅរស់នៅស្រុកកំណើតរបស់លោកស្រីមុនពេលខ្មែរក្រហមចូលកាន់កាប់តំបន់លោកស្រី ឬក៏យ៉ាងណា?

**ឆ៖** ចាស កាលពីឆ្នាំ១៩៦៩ ហ្នឹងម្ដាយខ្ញុំ ម្ដាយនាងខ្ញុំឈឺខ្វិន។ ដូច្នេះ ខ្ញុំលក់ផ្ទះមកថែទាំម្ដាយមកនៅស្រុកកំណើតវិញ។

**ស៖** អរគុណលោកស្រី។ តើលោកស្រីបានចូលរួមជាមួយចលនាបដិវត្តន៍នៅឆ្នាំណា? ហើយពេលនោះលោកស្រីមានឋានៈអ្វីដែរ?

**ធ៖** ខ្ញុំបានចូលរួមតាំងពីឆ្នាំ៧១ ហើយក៏ចូលជានារីក្នុងភូមិ ជានារីភូមិ។

**ស៖** តើអ្នកណាគេជាអ្នកចាត់តាំងឲ្យលោកស្រីកាន់តួនាទីនេះ?

**ធ៖** កាលជំនាន់នោះមានឈ្មោះ ខុម។

**ស៖** សូមលោកស្រីជួយបញ្ជាក់ម្តងទៀតបានទេ ថាអ្នកណាគេជាអ្នកចាត់តាំងឲ្យលោកស្រីកាន់តួនាទីនោះ?

**ធ៖** ឈ្មោះៗ ខុម។

**ស៖** តើ ខុម ជាអ្នកណាគេដែរលោកស្រី?

**ធ៖** ខុម (ស្រី) ហើយកូន តាម៉ុក។

[០៩:២៥:៥៣]

**ស៖** អរគុណលោកស្រី។ តើលោកស្រីអាចប្រាប់បានទេ លោកស្រីមានបងប្អូនប៉ុន្មាននាក់ដែរ?

**ធ៖** ចាស ខ្ញុំមានបងប្អូនបួននាក់។

**ស៖** រួមទាំងលោកស្រីផង តើប៉ុន្មាននាក់?

**ធ៖** ប្រាំនាក់ទាំងខ្ញុំ។

**ស៖** អរគុណលោកស្រី។ តើលោកស្រីអាចលម្អិតបន្តិចបានទេ ថាបងប្អូនលោកស្រីមានឈ្មោះអ្វីខ្លះ?

**ធ៖** ឈ្មោះបងទី១ឈ្មោះ ឃិន – ខឹម ឃិន, ទី២ ខឹម ខុន, ទី៣ ខឹម បូរ (ស្រី)។

**ស៖** នៅម្នាក់ទៀត ឈ្មោះអ្វីដែរលោកស្រី?

**ធ៖** ខឹម ឃឿន (ប្រុស)។

**ស៖** អរគុណលោកស្រី។ ក្នុងចំណោមអ្នកទាំងបួននាក់ហ្នឹង តើមានអ្នកណាគេបានកាន់តួនាទីអ្វីខ្លះនៅក្នុងរបបខ្មែរក្រហម?

**ធ៖** បានមានបងស្រីម្នាក់ ឈ្មោះគាត់ ខឹម បូរ ក្រៅពីនេះស្លាប់តាំងពីមុន ហើយនិងស្លាប់ពេលដែលរត់ មានធ្វើអី។

**ស៖** អរគុណ។ តើ ខឹម បូរ និង យាយបូរ ហ្នឹងគឺជាមនុស្សតែម្នាក់ ឬយ៉ាងណា?

**ធ៖** ចាស។

[០៩:២៧:៤០]

**សៈ** តើ យាយបូរ កាន់តួនាទីអីដែរនៅសម័យនោះ?

**ឆៈ** ខ្ញុំមិនបានដឹងដែរ ព្រោះអត់សូវដែលបានជួបគ្នា។

**សៈ** នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ឯកសារ E319/12.3.2 ឆ្លើយនឹងសំណួរសួរថា៖ "តើលោកស្រីស្គាល់ តាម៉ុក ដោយផ្ទាល់ដែរឬទេ?" នៅត្រង់ចម្លើយលេខ៥៦ លោកស្រីបញ្ជាក់ថា៖ "ចាស ខ្ញុំស្គាល់គាត់ដោយផ្ទាល់"។ តើលោកស្រីស្គាល់ តាម៉ុក មុន ឬក៏ក្រោយឆ្នាំ១៩៧៩? ហើយលោកស្រីស្គាល់ តាម៉ុក តាមរបៀបណាដែរ?

**ឆៈ** ខ្ញុំស្គាល់ក្រោយឆ្នាំ៧៥ ព្រោះអីគាត់ចុះមកតាមសហករណ៍។

**សៈ** អរគុណលោកស្រី។ ឥឡូវខ្ញុំមានសំណួរមួយទៀត តើលោកស្រីស្គាល់មន្ទីរពេទ្យ១០៥ ដែលមានឈ្មោះមន្ទីរពេទ្យត្រពាំងគល់ដែរឬទេ?

**ឆៈ** ចាស ស្គាល់។

**សៈ** តើលោកស្រីមានស្គាល់ពេទ្យម្នាក់ដែលឈ្មោះថា រៀល សន ដែលបម្រើការនៅមន្ទីរពេទ្យនោះដែរឬទេ?

**ឆៈ** ខ្ញុំអត់ស្គាល់ទេ ខ្ញុំអត់សូវបានទាក់ទង ភ្លេចបាត់ហើយ។

**សៈ** តើលោកស្រីមានធ្លាប់ស្គាល់លោក ខៀវ សំផន ដែរឬទេ?

**ឆៈ** ចាស អត់ទេ, អត់ដែលស្គាល់។

**សៈ** តើលោកស្រីមានធ្លាប់ឮថា លោក ខៀវ សំផន មកកាន់តំបន់របស់លោកស្រីមុនពេល ឬក្រោយពេលដែលលោកស្រីចូលរួមជាមួយចលនាបដិវត្តន៍ដែរឬទេ?

**ឆៈ** អត់ដឹង ខ្ញុំអត់ដែលបានជួបផង។

[០៩:២៩:៤៨]

**សៈ** អម្បាញ់មិញខ្ញុំបានសួរពីឈ្មោះបុរសម្នាក់ដែលធ្វើជាពេទ្យនៅមន្ទីរពេទ្យ១០៥ គាត់ឈ្មោះថា រៀល សន។ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ នៅក្នុងឯកសារ E319.1.21 ឆ្លើយទៅនឹងសំណួរសួរថា៖ "តើ យាយបឿន ជានីរសារឲ្យអ្នកណា?" ត្រង់ចម្លើយ១៨៧៖ គាត់ឆ្លើយថា "នីរសារឲ្យ ខៀវ សំផន ហើយតាព្រំ (ស្លាប់) ក៏ជានីរសារឲ្យ ខៀវ សំផន ដែរ"។ តើលោកស្រីយល់យ៉ាងណាដែរចំពោះចម្លើយរបស់គាត់នេះ?

**ឆៈ** អត់ ខ្ញុំអត់ដែលបានទាំងស្គាល់ផង។ ខ្ញុំអត់ទាំងស្គាល់ផង ខៀវ សំផន។

**ស៖** ឥឡូវ ខ្ញុំចង់ត្រឡប់មករកប្រធានបទមួយទៀត គឺពាក់ព័ន្ធជាមួយនឹងអំឡុងពេលដែលលោកស្រីបំពេញតួនាទីជាមេឃុំជាងទងវិញម្តង។ តើលោកស្រីអាចប្រាប់បានទេថា នៅពេលណាដែលលោកស្រីត្រូវបានគេតែងតាំងជាមេឃុំជាងទង?

**ឆ៖** ខ្ញុំចាំមិនបានឆ្នាំទេ ភ្លេច ប៉ុន្តែក្នុងអំឡុង៧៤-៧០ អីហ្នឹង ក្នុងអំឡុងហ្នឹង។

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេថា៧២ ឬក៏៧៤?

**ឆ៖** ខ្ញុំធ្វើជានារីរហូតដល់៧២, ៧៣។ ៧៤ ក្នុងអំឡុង ៧៤ ដែលខ្ញុំបានធ្វើនៅនឹងឃុំជាងទងហ្នឹង។ ពីមុនធ្វើខាងនារី។

[០៩:៣១:៤០]

**ស៖** អរគុណលោកស្រី។ នៅក្នុងកិច្ចសម្ភាសន៍មួយទៀតរបស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E319/12.3.2។ ឆ្លើយទៅនឹងសំណួរសួរថា លោកស្រីជាសមាជិកបក្សកុម្មុយនីស្តពេញសិទ្ធិ។ តើត្រឹមត្រូវដែរឬទេ? នៅត្រង់ចម្លើយលេខ៩២ លោកស្រីបាននិយាយថា លោកស្រីមិនមែនជាសមាជិកពេញសិទ្ធិនោះទេ។ តើលោកស្រីអាចពន្យល់បានទេវាខុសគ្នាយ៉ាងម៉េចរវាងសមាជិកពេញសិទ្ធិ និងសមាជិកមិនពេញសិទ្ធិ?

**ឆ៖** ចាស សមាជិកពេញសិទ្ធិគឺថា ចូលបក្ខជនពេញសិទ្ធិ ឯមិនពេញសិទ្ធិគេហៅថា "ចូលយុវជន"។ ហ្នឹងការដែលខ្ញុំចាំបាន។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងជាតិ រួមទាំងសាក្សី ខឹម បឿន ផងនៅពេលសួរនិងឆ្លើយសូមទុកគម្លាតពេលវេលាសមស្របសម្រាប់ការបកប្រែភាសាឲ្យបានត្រឹមត្រូវឲ្យបានច្បាស់លាស់ ប្រសិនបើសួរឆ្លើយរបៀបនេះអ្នកបកប្រែៗមិនអស់សេចក្តីទេ បកប្រែមិនទាន់ទេ។

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** ឥឡូវ ខ្ញុំសូមដកស្រង់យកឯកសារមួយទៀតដែលជាចម្លើយរបស់លោកសាក្សី រៀល សនដដែល គឺឯកសារ 319.1.21។ ឆ្លើយទៅនឹងសំណួរសួរថា "តើ យាយបឿន ជាអ្នកជឿទៅលើកុម្មុយនីស្តដោយគ្មានលក្ខខណ្ឌឬយ៉ាងណា?" ត្រង់ចម្លើយ១៩៧ លោក រៀល សន បានឆ្លើយថា គាត់គឺជា

បេក្ខជនយូរមកហើយ។ ហើយស្របទៅនឹងសំណួរមួយទៀតថា “តាមលោកដឹង តើ យាយហឿន ជាសមាជិកពេញសិទ្ធិ ឬក៏ជាសមាជិកត្រៀម?” នៅត្រង់ចម្លើយ១៩៨ ឆ្លើយថា “ជាសមាជិកពេញសិទ្ធិ”។ ហើយឆ្លើយតបទៅនឹងសំណួរមួយទៀតមានន័យថា “យាយហឿន ជាមនុស្សមានឥទ្ធិពលខ្លះណាស់នៅសម័យនោះ។ តើត្រឹមត្រូវដែរឬទេ?” ត្រង់ចម្លើយ១៩៩ ឆ្លើយថា “បាទ មានឥទ្ធិពលខ្លាំងណាស់”។ តើលោកស្រីយល់យ៉ាងណាដែរចំពោះចម្លើយរបស់សាក្សីឈ្មោះ រៀល សន?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយ។ ការដែលមានឥទ្ធិពល ឬមិនមាន ខ្ញុំគឺអាស្រ័យអ្នកខាងក្រៅគេមើល ខ្ញុំមិនដឹងថាមានឥទ្ធិពលយ៉ាងម៉េចទេ។

[០៩:៣៥:២៥]

**ស៖** អរគុណលោកស្រី។ តើលោកស្រីត្រូវបានគេតែងតាំងឲ្យទៅធ្វើការនៅមន្ទីរស្រុកនៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំបានចូលទៅក្នុងមន្ទីរស្រុកនៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែត្រ -- មួយពាន់ប្រាំបួនរយប៉ុន្មាន? មុនរំដោះហើយ ៧៨ នៅខែ១០ ៧៨។

**ស៖** អរគុណលោកស្រី តើពេលនោះលោកស្រីបានក្លាយជាសមាជិកបក្សពេញសិទ្ធិហើយឬនៅ?

**ឆ៖** អត់មានបានដាក់ថាពេញសិទ្ធិ ឬមិនពេញទេ គឺចាត់តាំងឲ្យទៅធ្វើតែម្តង។

**ស៖** ឥឡូវបែរមកចម្លើយរបស់លោកស្រី គឺត្រង់ឯកសារ នៅឯកសារ E319/12.3.2 វិញ នៅត្រង់ចម្លើយលេខ៩៣ លោកស្រីបាននិយាយថា ខ្ញុំសូមដកស្រង់៖ “ប្រសិនបើអ្នកណាជាសមាជិកពេញសិទ្ធិ គឺគេឲ្យទៅធ្វើការនៅថ្នាក់ស្រុក ឬខាងលើទៀត”។ ចំពោះចម្លើយនេះ លោកស្រីយល់យ៉ាងណាដែរ?

**ឆ៖** ចាស ចម្លើយហ្នឹងការពិត គឺអ៊ីចឹង។

**ស៖** អម្បាញ់មិញលោកស្រីបានបញ្ជាក់ថា លោកស្រីត្រូវបានគេតែងតាំងឲ្យបម្រើការនៅមន្ទីរស្រុកត្រាំកក់ អ៊ីចឹងមានន័យថា លោកស្រីត្រូវបានគេតែងតាំងជាសមាជិកបក្សពេញសិទ្ធិ ហើយឬក៏យ៉ាងណា?

**ឆ៖** គេចាត់តាំងឲ្យទៅធ្វើ អត់មានថា ពេញសិទ្ធិ មិនពេញផង។ នេះជាការពិត។

[០៩:៣៦:៥៩]

**ស៖** សូមលោកស្រីរៀបរាប់បន្តិចអំពីរចនាសម្ព័ន្ធរបស់ឃុំជាងទង ក្រោយពេលដែលលោកស្រីបម្រើការនៅទីនោះ?

**ឆ៖** ខ្ញុំអត់យល់ សូមម្តងទៀត។ ខ្ញុំមិនយល់ គាត់និយាយថាម៉េច។

**ស៖** សំណួរខ្ញុំចង់ឲ្យលោកស្រីរៀបរាប់បន្តិចមើល៍អំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ឃុំលោកស្រីក្រោយពេលដែលលោកស្រីទៅធ្វើការនៅឃុំនោះ តើរចនាសម្ព័ន្ធគ្រប់គ្រងហ្នឹងមានលក្ខណៈដូចម្តេចដែរ?

**ឆ៖** ការគ្រប់គ្រង ខ្ញុំចាំមិនច្បាស់ដែរ ប៉ុន្តែគ្រាន់ដឹងថា ការរៀបចំជាក្រុម ជាពួក ហើយគេរៀបចំតាមសហករណ៍ ហ្នឹងចាំបាន។ រចនាសម្ព័ន្ធមានតែកងកុមារផ្សេង យុវជនផ្សេង នារីផ្សេង និងស្ត្រីផ្សេង តែប៉ុណ្ណោះឯង។

[០៩:៣៨:២៣]

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេ ថាតើអ្នកណាគេជាអនុប្រធានរបស់លោកស្រី ហើយអ្នកណាគេជាអ្នកកាន់ខាងយោធា ឬក៏កងឈ្លប ហើយអ្នកគេជាអ្នកកាន់ខាងការងារផ្សេងៗទៀត?

**ឆ៖** ចាស ខាងកងខ្ញុំ គឺមានឈ្មោះ ខុម។ ខុម គាត់កាន់ខាងយោធា ហើយមួយទៀតគឺឈ្មោះ ប៉ូ។ ចាស មួយទៀតឈ្មោះ តុប។ បីនាក់។

**ស៖** តើនៅមានអ្នកណាគេកាន់ខាងឈ្លបទៀតដែរ ឬទេលោកស្រី?

**ឆ៖** ឈ្លប ឈ្មោះ ខឹម គាត់ទទួលខាងឈ្លបផងក្នុងឃុំហ្នឹង។

**ស៖** តើនៅពេលដែលលោកស្រីកាន់តួនាទីជាមេឃុំ តើលោកស្រីធ្វើអ្វីខ្លះ លោកស្រីអាចបញ្ជាក់បានដែរឬទេ?

**ឆ៖** ខ្ញុំធ្វើ ដឹកនាំធ្វើស្រែ ធ្វើចម្ការ ធ្វើជី ធ្វើស្រែប្រាំង។

**ស៖** តើខាងយោធា និងកងឈ្លបមានភារកិច្ចអ្វីខ្លះនៅក្នុងឃុំរបស់លោកស្រី?

**ឆ៖** ខាងយោធា កងឈ្លបហ្នឹងតែមួយ។ គឺមានតួនាទីខាងយាមកាម ការពារភូមិឃុំ ចាស។

[០៩:៤០:៣៨]

**ស៖** អរគុណលោកស្រី។ នៅក្នុងកិច្ចសម្ភាសន៍មួយទៀតរបស់លោកស្រី ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារលេខ E319./12.3.2 ត្រង់ចម្លើយ១២៩ លោកស្រីបាននិយាយថា ខឹម ទទួលបន្ទុកខាងយោធា និងឈ្លប។ ហើយត្រង់ចម្លើយ១៧៦ លោកស្រីបាននិយាយថា ចន

ជាប្រធានឈ្លបដែលគ្រប់គ្រងផ្ទាល់។ ហើយគាត់ស្ថិតនៅក្រោម ខឹម។ តើលោកស្រីចង់និយាយថា ខឹម ហ្នឹងជាមេរបស់ ចន ឬយ៉ាងណា?

**ឆ៖** មេ ចាស មេ។ ចនហ្នឹងនៅជាមួយឈ្លបផ្ទាល់ ខ្ញុំភ្លេច ខ្ញុំអត់ចាំ។

**ស៖** តើ--

**ប្រធានអង្គជំនុំ៖**

លោកស្រី ខឹម ហឿន នៅពេលលោកស្រីឆ្លើយតប លោកស្រីបង្អង់បន្តិច។ គិតពិចារណាលើនូវខ្លឹមសារនៃសំណួរផង ហើយបង្អង់បន្តិចដើម្បីឆ្លើយតបនឹងសំណួរដើម្បីទុកលទ្ធភាពផ្តល់អង្គភាពបកប្រែភាសាហ្នឹងអាចបកប្រែភាសាបានល្អ បានពេញលេញ។ បាទ សូមអរគុណ លោកស្រី ខឹម ហឿន។

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស។

**សួរដោយ សេង លាង៖**

**ស៖** អរគុណលោកប្រធាន។ តើនៅក្នុងសម័យនោះ អ្នកណាគេជាអ្នកទទួលបន្ទុក រើសកងឈ្លបនៅក្នុងឃុំរបស់លោកស្រី?

**ឆ៖** មាន ខឹម ហើយនិង ចន ហ្នឹង។

**ស៖** អរគុណលោកស្រី។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតមួយទៀតគឺឯកសារ E319/12.3.2 ឆ្លើយនឹងសំណួរថា "តើ ចន ត្រូវរាយការណ៍ទៅ ខឹម ឬយ៉ាងណា?" ត្រង់ចម្លើយ ១៧៩ លោកស្រីឆ្លើយថា "ចាស ត្រូវរាយការណ៍ទៅ ខឹម"។ ហើយឆ្លើយ តបទៅនឹងសំណួរសួរថា ហើយ "ខឹម ត្រូវរាយការណ៍ទៅលោកស្រី តើត្រឹមត្រូវដែរឬទេ?" ត្រង់ចម្លើយ១៨០ លោកស្រីឆ្លើយថា "ចាស ខ្ញុំត្រូវរាយការណ៍ទៅថ្នាក់លើ"។ តើលោកស្រីអាចបញ្ជាក់បានទេថា ជាធម្មតារបៀបរាយការណ៍ត្រូវធ្វើតាមរបៀបនេះ ឬយ៉ាងណា?

[០៩:៤២:៥៧]

**ឆ៖** ចាស ធ្វើការ រាយការណ៍គឺតាមរបៀបនេះឯង។

**ស៖** តើលោកស្រីអាចប្រាប់បានទេថា តើ ចន និង ខឹម ហ្នឹងគាត់បានទទួលការរាយការណ៍ពីភូមិហ្នឹងតាមរបៀបណាដែរ?

**ឆ៖** គាត់ទៅរាយតាម -- ទទួលពីភូមិ។

**ស៖** ខ្ញុំទៅមួយសំណួរទៀត។ សូមលោកស្រីប្រាប់អង្គសវនាការមើលថាតើរបាយការណ៍របៀបណាដែល ចន និង ខឹម បានរាយការណ៍ប្រាប់លោកស្រី?

**ឆ៖** ចាស កាលដែល ចន និង ខឹម បានរាយការណ៍មកគាត់សរសេរជាលាយលក្ខណ៍អក្សរមកជូនដល់ខ្ញុំ ខ្ញុំត្រូវបញ្ជូនទៅលើទៀត។

**ស៖** តើរបាយការណ៍ដែល ចន និង ខឹម រាយការណ៍នោះ ជាប្រភេទរបាយការណ៍បែបសន្តិសុខ ឬក៏របាយការណ៍អីដែរ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចាស អាចសន្តិសុខខ្លះ អាចជាគុក។ ជំនាន់នោះកងឈ្លបក៏បង្កើនផលដែរដើម្បីចិញ្ចឹមជីវិត។ ខាងសេដ្ឋកិច្ចផង ខាងយោធាផង។

**ស៖** អរគុណលោកស្រី។ នៅពេលដែលមានសេចក្តីរាយការណ៍មកលោកស្រីពាក់ព័ន្ធជាមួយនឹងបញ្ហាសន្តិសុខនោះ តើលោកស្រីដែលរៀបចំកិច្ចប្រជុំពិភាក្សាអំពីសេចក្តីរាយការណ៍ទាំងនោះជាមួយថ្នាក់ភូមិដែរឬទេ?

**ឆ៖** ចាស មាន។

[០៩:៤៥:00]

**ស៖** ប្រសិនបើដូច្នោះ តើកិច្ចប្រជុំនោះគេពិភាក្សាពីអ្វីខ្លះ? តើលោកស្រីបានណែនាំអ្វីខ្លះដល់ភូមិវិញ?

**ឆ៖** តាមជាក់ស្តែង រាយការណ៍ពីសភាពការណ៍សេដ្ឋកិច្ច ក៏បានណែនាំពីការដាំដុះ បង្កើនផលដើម្បីដោះស្រាយជីវភាព។ តែបើរាយការណ៍ថាខាងផ្នែកផ្សេងៗទៀតក៏ដោះស្រាយតាមនោះដែរ តាមជាន់ស្តែង។

**ស៖** ចុះចំពោះបញ្ហាសន្តិសុខវិញ តើលោកស្រីដោះស្រាយតាមរបៀបណាដែរជាធម្មតា?

**ឆ៖** សន្តិសុខ បើរាយពីភូមិ មានរាយការណ៍មកពីភូមិ មកពីឈ្លប គឺខ្ញុំ រាយមកដល់ខ្ញុំ ខ្ញុំបញ្ជូនទៅលើ ខ្ញុំបញ្ជូនទៅថ្នាក់លើ។

**ស៖** អរគុណលោកស្រី។ លោកស្រីបានបញ្ជាក់ថា លោកស្រីបញ្ជូនទៅថ្នាក់លើ តើលោកស្រីបញ្ជូនទៅថ្នាក់ដែរ?

**ឆ៖** ទៅថ្នាក់ស្រុកចាស។

[០៩:៤៦:១២]

**ស៖** បន្ទាប់មក តើថ្នាក់ស្រុកត្រូវធ្វើយ៉ាងម៉េចជាមួយនឹងរបាយការណ៍នោះ? តើលោកស្រីដឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនសូវបានដឹងដែរ។

**ស៖** អរគុណលោកស្រី។ ក្រៅពីកិច្ចប្រជុំ តើមានរបៀបអ្វីខ្លះដែលលោកស្រីប្រើក្នុងការទំនាក់ទំនងជាមួយថ្នាក់លើរបស់លោកស្រី?

**ឆ៖** ក្រៅពីប្រជុំជាមួយថ្នាក់លើ មានអី មានតែសំណូមពរសូមការផ្គត់ផ្គង់ជីវភាពសំខាន់ជាងគេដល់ប្រជាជន។

**ស៖** ខ្ញុំចង់សំដៅទៅលើការទាក់ទងគ្នាដូចជា តាមលិខិត ឬតាមទូរសារនានា តើលោកស្រីមានដែលប្រើដែរឬទេ ចំពោះបញ្ហាទាំងអស់នេះ?

**ឆ៖** អត់ទេ។

**ស៖** អរគុណលោកស្រី។ ឥឡូវខ្ញុំទៅមុខបន្តិចទៀត ទៅកាន់ប្រធានបទចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធជាមួយនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ E319/12.3.2 ត្រង់ចម្លើយ១១២ លោកស្រីបាននិយាយថា ខ្ញុំសូមដកស្រង់៖ "បក្សជាអ្នកសម្រេច ប៉ុន្តែគេរៀបចំឲ្យប្រជាជនថ្មីរៀបការជាមួយប្រជាជនថ្មី ចំណែកប្រជាជនចាស់រៀបការជាមួយប្រជាជនចាស់"។ សំណួរសួរថា ហេតុអ្វីបានជាការរៀបការត្រូវរៀបចំឡើងដោយបក្សទៅវិញ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[០៩:៤៨:១២]

**ឆ៖** ចាស ការរៀបចំ ទាល់ស្នើទៅខាងលើ ខាងលើសម្រេច បានខាងក្រោមប៉ានរៀបចំ។

**ស៖** អរគុណលោកស្រី។ តាមដែលលោកស្រីដឹង តើគោលនយោបាយក្នុងការរៀបការនេះចេញមកពីណាដែរ?

**ឆ៖** ចេញមកពីថ្នាក់លើចាស។

**ស៖** ថ្នាក់លើដែលលោកស្រីសំដៅហ្នឹង គឺថ្នាក់មជ្ឈិម ឬក៏ថ្នាក់តំបន់ ឬក៏ថ្នាក់ភូមិភាគ?

**ឆ៖** អត់ទេ, ថ្នាក់ខ្ញុំទទួលត្រឹមថ្នាក់ស្រុកទេចាស។ ខ្ញុំដឹង ដឹងត្រឹមស្រុកទេខ្ញុំ។

**ស៖** អ៊ីចឹងលោកស្រីចង់និយាយថា ស្រុកជាអ្នកណែនាំលោកស្រីឬយ៉ាងណា?

**ឆ៖** ចាស។

**សៈ** តើគោលនយោបាយនេះលោកស្រីផ្សព្វផ្សាយទៅថ្នាក់ក្រោមតាមរបៀបណា? គោល-នយោបាយស្តីអំពីការរៀបការនេះ លោកស្រីផ្សព្វផ្សាយទៅថ្នាក់ក្រោមតាមរបៀបណា?

**ធៈ** តាមរបៀបថ្នាក់ភូមិ ប្រធានភូមិ។

**សៈ** តាមដែលលោកស្រីដឹង តើមូលហេតុអ្វីបានជាប្រជាជនថ្មីមិនត្រូវបានគេអនុញ្ញាតឲ្យរៀបការជាមួយប្រជាជនចាស់?

**ធៈ** តាមដែលខ្ញុំដឹង ដឹងច្បាស់មិនច្បាស់ តែខ្ញុំដឹងថា ប្រជាជនថ្មីទៅឲ្យរៀបចំជាមួយប្រជាជនថ្មី ហើយអ្នកចាស់ជាមួយចាស់។ ថាប្រជាជនថ្មី និងប្រជាជនចាស់ជំនាន់នោះវា ដូចថាវាអត់ទាន់ស្គាល់គ្នា អត់ស៊ីចង្វាក់គ្នា ដូចអស់លោកដឹងស្រាប់ហើយ។

**សៈ** អរគុណលោកស្រី។ នៅក្នុងចម្លើយរបស់លោកស្រីគឺនៅក្នុងឯកសារ E319/12.3.2ត្រង់ចម្លើយលេខ១២០ លោកស្រីបានឆ្លើយថា៖ “ខ្ញុំយល់ថាប្រជាជនថ្មីមិនល្អ ជាខ្មាំងមិនសូវមានតម្លៃដូចប្រជាជនចាស់ ដូច្នេះគេពុំអនុញ្ញាតឲ្យរៀបការជាមួយប្រជាជនចាស់នោះទេ”។ តើលោកស្រីយល់យ៉ាងណាចំពោះអ្វីដែលលោកស្រីបានលើកឡើងហ្នឹងនៅក្នុងកិច្ចសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ?

[០៩:៥១:០៤]

**ធៈ** ចាស ខ្ញុំនិយាយយោងតាមការអប់រំពីលើចាស។

**សៈ** លោកស្រីបានមានប្រសាសន៍ថា លោកស្រីនិយាយតាមការអប់រំពីថ្នាក់លើ។ តើថ្នាក់ណាដែរជាអ្នកអប់រំ?

**ធៈ** ថ្នាក់ស្រុក។

**សៈ** តើគេអប់រំថាយ៉ាងម៉េច លោកស្រីអាចលម្អិតបន្តិចបានដែរឬទេ?

**ធៈ** ចាស បាន។ អប់រំថាប្រជាជនថ្មីត្រូវរៀបចំជាមួយប្រជាជនថ្មី ហើយប្រជាជនចាស់ក៏អ៊ីចឹង ដើម្បីកុំឲ្យ ម៉្យាងទាស់គ្នា ម៉្យាងទៀតក៏មិនទាន់ស្គាល់ស៊ីចង្វាក់គ្នា ព្រោះប្រជាជនថ្មីវាទើបនឹងមកថ្មី ហើយប្រជាជនចាស់ វានៅចាស់ហ្នឹងចាស។

**សៈ** ខ្ញុំចង់សំដៅទៅលើចម្លើយរបស់លោកស្រីត្រង់ចម្លើយលេខ១២០ អម្បាញ់មិញ ដែលខ្ញុំបានអាន “គឺខ្ញុំយល់ថា ប្រជាជនថ្មីមិនល្អ ជាខ្មាំង មិនសូវមានតម្លៃដូចប្រជាជនចាស់” ដូច្នេះគេពុំអនុញ្ញាតឲ្យរៀបការជាមួយប្រជាជនចាស់នោះទេ”។ ខ្ញុំចង់ឲ្យលោកស្រីជួយប្រាប់មើលថា តើថ្នាក់លើ

ហ្នឹងគេណែនាំថា យ៉ាងម៉េចអំពីបញ្ហានេះ?

**ផ៖** ចាស ថ្នាក់ថាមិនឲ្យរៀបចំប្រជាជនថ្មី និងប្រជាជនចាស់រៀបការជាមួយគ្នា ព្រោះប្រជាជនថ្មីទើបនឹងមកថ្មី ហើយការរៀបចំរស់នៅក៏ទើបតែនឹងរៀបចំរស់នៅ ហើយមិនស្គាល់គ្នា មិនទុកចិត្តគ្នា និយាយរួមគឺអត់ទុកចិត្តគ្នា។ នេះសូមជម្រាបការពិត។

[០៩:៥២:៥២]

**ស៖** អរគុណលោកស្រី។ ខ្ញុំសូមទៅកាន់សំណួរមួយទៀតពីព្រោះពេលវេលាកាន់តែខើចហើយ។ សូមលោកស្រីមេត្តាជួយរៀបរាប់ប្រាប់អង្គសវនាការបន្តិចមើល៍ថា តើការរៀបការនេះត្រូវបានផ្តួចផ្តើមយ៉ាងដូចម្តេចនៅក្នុងរបបខ្មែរក្រហម?

**ផ៖** ការរៀបការ ខ្ញុំមិនសូវយល់ដែរ ព្រោះតាមទទួលការណែនាំពីលើមកថា ឲ្យរៀបការប៉ុន្មាន រៀបប៉ុណ្ណឹងហើយ ជាមួយចាស់ ជាមួយថ្មី ដូចខ្ញុំបានជម្រាប។ ខ្ញុំមិនយល់ដែរ។

**ស៖** ជាធម្មតា តើថ្នាក់លើណែនាំឲ្យរៀបការប៉ុន្មានគូដែរ?

**ផ៖** ខ្ញុំនិយាយបានត្រឹមក្នុងក្របខ័ណ្ឌដែលខ្ញុំរស់នៅ មួយគូក៏បាន ច្រើនគូក៏បាន តែខ្ញុំមិនដែលបានរៀបច្រើនទេ បានយ៉ាងច្រើនបីបួនគូប៉ុណ្ណោះ។

**ស៖** នៅក្នុងឯកសារមួយនៃកិច្ចសម្ភាសដដែលហ្នឹងគឺឯកសារ E319/12.3.2 ត្រង់ចម្លើយលេខ១១៦។ លោកស្រីបានឆ្លើយថា "ថ្នាក់ភូមិជាអ្នកសរសេរឈ្មោះបុរសស្ត្រីដែលត្រូវរៀបការ ហើយបញ្ជូនទៅថ្នាក់តំបន់ជាអ្នកសម្រេច ថាតើត្រូវរៀបការប៉ុន្មានគូម្តង? ខ្ញុំថ្នាក់ក្រោមពុំបានសម្រេចចិត្តចំពោះបញ្ហានេះទេ"។ តើចំពោះបញ្ហានេះ លោកស្រីយល់យ៉ាងណាដែរ?

**ផ៖** ខ្ញុំ -- ដូចខ្ញុំបានជម្រាបអ៊ីចឹង ទៅវាយការណ៍ទៅខាងលើយល់ព្រមក៏រៀប បើអត់យល់ព្រមអត់។

[០៩:៥៤:៤៧]

**ស៖** អរគុណលោកស្រី។ តើនរណាគេជាអ្នកទទួលខុសត្រូវក្នុងការរៀបចំពិធីរៀបការនៅក្នុងឃុំរបស់លោកស្រី?

**ផ៖** ពេលរៀបចំគឺមាន ភូមិ ឃុំ រួមទាំងខ្លួនខ្ញុំផង ចាស។

**ស៖** តើក្នុងមួយឆ្នាំៗ គេរៀបចំពិធីការញឹកញាប់ដែរ ឬទេ?

**ផ៖** អត់សូវទេ។ ការតិចតួចទេ។

**ស៖** តើលោកស្រីជាអ្នករៀបចំបញ្ជីឈ្មោះនិងផ្គូរផ្គងគូស្រករៀបការឬយ៉ាងណាសូមពន្យល់?

**ឆ៖** ចាស ខ្ញុំបានរៀបចំមែន។ ខ្ញុំសរសេរ ដូចឃើញថា ស្ត្រី យុវនារី យុវជនហ្នឹងវាចាស់ៗ ខ្លាចវាមានសីលធម៌មិនល្អ រស់នៅជាមួយគ្នា ក៏សរសេរជូនទៅខាងលើទៅ ខាងលើសម្រេចក៏រៀបចំ បើអត់ ក៏រំសាយទៅ។

**ស៖** តើពិធីរៀបការប្រព្រឹត្តទៅយ៉ាងដូចម៉េចដែរ លោកស្រីអាចរៀបរាប់បានទេ?

**ឆ៖** ចាស ការរៀបការមានអី ក្រៅពីជួបជុំគ្នាហើយ មានធ្វើបាយទឹកបន្តិចបន្តួច ហូបចុក ហើយ ក៏សាមីខ្លួនសងខាងឡើងចាប់អារម្មណ៍ ថាស្រឡាញ់គ្នា យកគ្នាទៅអនាគតអ៊ីចឹងទៅ ហើយក៏ ប្រធានរៀបចំហ្នឹង ក៏ជួយណែនាំ ជូនពរ ចប់។ ចប់ហើយ។

**ស៖** អរគុណ លោកស្រី។ តើហេតុអ្វីបានជាគេតម្រូវឱ្យមានការឡើងប្តេជ្ញាចិត្តពីគូស្រករក្នុង ពិធីរៀបការហ្នឹង?

**ឆ៖** ខ្ញុំមិនយល់ដែរ អាហ្នឹងជាទម្លាប់ទាំងអស់ ធ្វើអ៊ីចឹង។ ប្តេជ្ញាចិត្តមានអ៊ីចឹងមែន។

**ស៖** តើអ្នកណាគេជាអ្នកណែនាំឱ្យលោកស្រី តម្រូវឱ្យគូស្រករឡើងប្តេជ្ញាចិត្ត?

**ឆ៖** ខាងលើតៗមក។ ខ្ញុំទទួលបានត្រឹមខាងស្រុក។ លើទៀតអត់ដឹង។

**ស៖** តើលោកស្រីអាចប្រាប់បានទេថា អំពីប្រពៃណីទំនៀមទម្លាប់ តើគេអនុញ្ញាតដែរ ឬទេ ក្នុង ពិធីរៀបការហ្នឹង?

[០៩:៥៧:៣៣]

**ឆ៖** ទំនៀមទម្លាប់ការ វាមិនទំនៀមទម្លាប់ដូចយើងពីដើមទេ ការដូចខ្ញុំជម្រាបហើយ។ ការរៀប ចំឱ្យឡើងប្តេជ្ញាចិត្តយកគ្នា ជាប្តី ជាប្រពន្ធទៅអនាគតតែប៉ុណ្ណឹង មិនមានការរៀបចំដូចយើងតាម ប្រពៃណីខ្មែរទេ។

**ស៖** ឥឡូវខ្ញុំទៅមុខមួយសំណួរទៀត មុននឹងខ្ញុំឈានដល់មួយសំណួរចុងក្រោយរបស់ខ្ញុំ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺឯកសារ E319/12.3.2 នៅត្រង់ចម្លើយទី១១២ នៃឃ្លាដដែល ឃ្លាបន្ទាប់មក លោកស្រីបាននិយាយថា “យើងអាចនិយាយថា បង្ខំឱ្យរៀបការបាន ព្រោះបក្សជាអ្នកសម្រេចនៅក្នុងការរៀបការនេះ”។ តើលោកស្រីចង់បញ្ជាក់ថា ការរៀបការនេះ ជាការរៀបការដោយបង្ខំ ឬយ៉ាងណា តាមអ្វីដែលលោកស្រីលើកឡើង?

**ឆ៖** តាមទស្សនៈខ្ញុំ ខ្ញុំថាមិនត្រូវបង្ខំ ប៉ុន្តែបើថាត្រូវរ៉ូវគ្នា ត្រូវតែបង្ខំឱ្យរៀបចំ។

**សៈ** ខ្ញុំចង់សំដៅទៅលើចម្លើយនៅក្នុងឯកសារ E319/12.3.2 ត្រង់ចម្លើយ១១២ ដែលខ្ញុំអានអម្បាញ់មិញ លោកស្រីបាននិយាយថា "យើងអាចនិយាយថា បង្ខំឲ្យរៀបការបាន ព្រោះបក្សជាអ្នកសម្រេចនៅក្នុងការរៀបការនេះ"។ តើលោកស្រីចង់បញ្ជាក់ថា អាពាហ៍ពិពាហ៍នោះគឺជាការបង្ខំ ឬយ៉ាងណា? អាចបញ្ជាក់ម្តងទៀត។

**ផៈ** ចាស។

**សៈ** អរគុណលោកស្រី។ ឥឡូវ ខ្ញុំផ្តោះទៅកាន់សំណួរចុងក្រោយរបស់ខ្ញុំ ដោយសារថាពេលពេលវេលាវាមានតិច។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E319/12.3.2 ត្រង់ចម្លើយ១១៨ លោកស្រីបាននិយាយថា ហើយខ្ញុំសូមដកស្រង់ "មិនចាំបាច់ល្អួបទៅយកការណ៍នោះទេ នៅក្នុងភូមិតូចតែមួយ អ្នកណាមិនដឹងថា អ្នកណាស្រឡាញ់គ្នា ឬមិនស្រឡាញ់គ្នា"។ សំណួរចង់សួរថា តើនឹងមានអ្វីកើតឡើង ប្រសិនបើគូស្រករថ្មីមិនស្រឡាញ់គ្នា តើលោកស្រីអាចប្រាប់បានដែរ ឬទេ?

[១០:០០:០០]

**ផៈ** ចាស បើមិនស្រលាញ់គ្នា គឺយកគ្នាមិនបានមែន ជាការពិត។

**សៈ** តើអនុញ្ញាតឲ្យគូស្រករថ្មីដែលទើបរៀបការជាមួយគ្នាហ្នឹងលែងលះជាមួយគ្នាដែរឬទេ?

**ផៈ** អត់មានសម្រេចទេ តែអាចមានលែងលះ ចាស។

**សៈ** លោកស្រីអាចលើកឧទាហរណ៍ជាក់ស្តែងបានទេថា តើគេលែង អ្នកណាគេលែងគ្នាហ្នឹង?

**ផៈ** ខ្ញុំចាំមិនបានទេ លោក ខ្ញុំភ្លេចអស់ហើយ។

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ខ្ញុំចង់បញ្ចប់សំណួរខ្ញុំត្រង់នេះ ដោយសារថា សហការីខ្ញុំគាត់មានសំណួរច្រើន។ ហើយខ្ញុំសូមជូនវេទិកានេះ ទៅសហការីរបស់ខ្ញុំ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រី ចៅក្រម។

[១០:០១:១៧]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកស្រី ខឹម បឿន ខ្ញុំឈ្មោះ វាំងសង់ ដេវីល ខ្ញុំជាសហព្រះរាជអាជ្ញារងអន្តរជាតិ។ ជាដំបូងខ្ញុំសូមរំឭកលោកស្រីថា យើងមិនមែននៅទីនេះ ដើម្បីចោទប្រកាន់លោកស្រីនោះទេ។ ខ្ញុំសូមកោតសសើរដែលលោកស្រីបានឆ្លើយយ៉ាងស្មោះត្រង់ទៅជូនចៅក្រមស៊ើបអង្កេតនៅពេលដែលខាងសហចៅក្រមស៊ើបអង្កេតទៅសម្ភាសលោកស្រីនោះ។ អ៊ីចឹងខ្ញុំសូមឲ្យលោកស្រីបន្តធ្វើអ៊ីចឹងទៀត។ អ៊ីចឹងយើងនៅទីនេះ គឺដើម្បីស្ដាប់សក្ខីកម្មរបស់លោកស្រីដើម្បីស្វែងរកការពិត។ ប្រសិនបើលោកស្រីមិនចាំត្រង់ចំណុចណាមួយទេ សូមលោកស្រីកុំប្រឌិត កុំស្មាន លោកស្រីគ្រាន់តែឆ្លើយថាខ្ញុំមិនដឹងទេ តែប៉ុណ្ណឹងទៅបានហើយ។ ប្រសិនបើលោកស្រីមិនយល់សំណួរសូមសួរឲ្យខ្ញុំសួរឡើងវិញ។ សូមអរគុណលោកស្រី។

ជាដំបូង ខ្ញុំចង់សួរពាក់ព័ន្ធនឹងទីកន្លែងកំណើត។ លោកស្រីថា លោកស្រីកើត នៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់។ មានកម្មាភិបាលទាំងស្រី ទាំងប្រុសគាត់មានដើមកំណើតមកពីភូមិលោកស្រីដែរក្បាលអូរ តើមានទេ ខ្ញុំចង់សួរថា តើមានកម្មាភិបាលដែលមកពីភូមិដូចលោកស្រីទេ?

**ឆ៖** ចាស អត់មានទេ។

[១០:០២:៥៣]

**ស៖** ក្រៅពីបងស្រីរបស់លោកស្រី ហើយនិងលោកស្រីនោះ ខ្ញុំគិតថា លោកស្រីបាននិយាយអំពី យាយបូ ដែលជាបងរបស់លោកស្រី ដែលក្នុងចម្លើយទី៣២ នៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រីគឺE319/12.3.2 ថាគាត់មានមុខតំណែងនៅក្នុងគណៈស្រុកគិរីវង់។ អម្បាញ់មិញនេះលោកស្រីមិននិយាយទេ អ៊ីចឹងខ្ញុំរំឭកឡើងវិញ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើក្រៅពីលោកស្រី និងបងរបស់លោកស្រីនោះ លោកស្រីស្គាល់ឈ្មោះ យាយយុត ព្រោះគាត់ក៏មកពីភូមិក្បាលអូរដែរ?

**ឆ៖** ចាស ខ្ញុំស្គាល់តើ។

**ស៖** អ៊ីចឹងតើគាត់មានមុខងារអ្វីដែរនៅក្នុងរបបខ្មែរក្រហម?

**ឆ៖** គាត់ចេញបាត់យូរ ខ្ញុំអត់បានដឹងពី គាត់ចេញពីស្រុកពីភូមិទៅបាត់យូរមិនដឹង ទៅឆ្ងាយ។

**ស៖** នៅក្នុងកំណត់ហេតុរបស់លោកស្រី លោកស្រីនិយាយអំពី តាអាន់ ជាប្រធានគុកក្រាំងតាចាន់ ហ្នឹង។ អ៊ីចឹងខ្ញុំចង់ដឹងថាតើ តាអាន់ ហ្នឹងគាត់មកពីភូមិក្បាលអូរដែរ ឬក៏មកពីភូមិជិតៗហ្នឹង?

**ឆ៖** គាត់ភូមិទទឹងថ្ងៃជាប់ជាមួយក្បាលអូរ។

**ស៖** មានសាក្សីមួយរូបដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែលគាត់ថា តាអាន់ ហ្នឹង និងលោកស្រីហ្នឹងជាបងប្អូនជីដូនមួយនឹងគ្នា។ អ៊ីចឹងតើត្រឹមត្រូវទេ លោកស្រី និង តាអាន់ ហ្នឹងជាបងប្អូនជីដូនមួយនឹងគ្នាមែនទេ?

**ឆ៖** ចាស។

[១០:០៥:១៩]

**ស៖** សម្រាប់ជាប្រតិចារឹក គឺសាក្សី វ៉ាន់ សឿន ដែលជានីរសាតនៅក្រាំងតាចាន់ ដែលគាត់បានឆ្លើយបែបនេះនៅចម្លើយទី៨៦នៃឯកសារ E319.1.33។ តើ យាយចែម ឬក៏ អ៊ឹម ចែម មកពីភូមិក្បាលអូរមែនទេ?

**ឆ៖** ចាស។

**ស៖** នៅចុះគាត់មានតំណែងអ្វីដែរនៅតំបន់ គឺតំបន់នៅស្រុកត្រាំកក់?

**ឆ៖** ចាស អត់យល់។ សូមម្តងទៀត។

**ស៖** ខ្ញុំចង់ដឹងថាតើ អ៊ឹម ចែម ហ្នឹងគាត់មានមុខងារអ្វីដែរនៅក្នុងតំបន់របស់លោកស្រីនោះ នៅក្នុងតំបន់១៣?

**ឆ៖** ចាស គាត់មុខងារគាត់ជាប្រធាននារីក្នុងតំបន់។

**ស៖** តើក្រោយមកទៀតនោះ គាត់មានមុខងារនៅក្នុងភូមិភាគកណ្តាលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅកំពង់ចាមដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងដែរ។

**ស៖** តើគាត់ជាសាច់ញាតិរបស់លោកស្រីដែរឬទេ អ៊ឹម ចែម ហ្នឹង?

**ឆ៖** ចាស ជាសាច់ញាតិ ស្រុកភូមិជាមួយគ្នា វាឆ្ងាយ។

**ស៖** ប្តីរបស់លោកស្រី តាជន ដែលជាមេឃុំពេល ស្រុកត្រាំកក់ តើគាត់មកពីភូមិក្បាលអូរដូចលោកស្រីដែរមែនទេ?

**ឆ៖** ចាស។

**ស៖** តើលោកស្រីអាចពន្យល់បានទេថា ហេតុអីបានជាមានកម្មាភិបាលសំខាន់ៗជាច្រើនមកពីភូមិក្បាលអូរហ្នឹង?

**ឆ៖** ខ្ញុំមិនយល់ដែរ ឃើញថាភូមិក្បាលអូរចាត់តាំងឲ្យធ្វើអ៊ីចឹងទៅ ខ្ញុំមិនយល់ដែរ។

[១០:០៨:២៨]

**ស៖** តាព្រំ មានសាក្សីម្នាក់និយាយថា គាត់ជាពូរបស់លោកស្រី ហើយគាត់ -- តើគាត់ហ្នឹងមានជាអ្នករើសទាហានអីសម្រាប់បក្សទេ?

**ឆ៖** ចាស ជាពូ ប៉ុន្តែខ្ញុំមិនដឹង ដឹងគាត់ម៉េចទេ ខ្ញុំអត់ដឹងដែរ។

**ស៖** មុនពេលសម្រាកខ្ញុំសូមសួរបន្តិចទៀតលោកប្រធាន។ ខ្ញុំចង់និយាយអំពីរចនាសម្ព័ន្ធស្រុកត្រាំកក់។ តើលោកស្រីអាចជម្រាបបានទេថា នៅពេលដែលលោកស្រីក្លាយជាមេឃុំជាងទង គឺនៅចម្លើយទី២២ នៃកំណត់ហេតុរបស់លោកស្រី គឺលោកស្រីថាចុងឆ្នាំ៧៣។ តើលោកស្រីអាចរៀបរាប់បានទេថា លេខាស្រុកត្រាំកក់ជាបន្តបន្ទាប់មានអ្នកណាខ្លះ ចន្លោះឆ្នាំ៧៣រហូតទៅដល់ឆ្នាំ៧៩?

**ឆ៖** ខ្ញុំមិនចាំមិនបានទេ។ ចាំមិនបានអស់ទេ ចាំបានខ្លះៗ តែក៏មិនសូវច្បាស់ដែរ បើខុសត្រូវយ៉ាងម៉េច សូមអធ្យាស្រ័យ។ ពីមុន ពីយូរហើយមក ខ្ញុំភ្លេចបាត់ហើយ ចាំទេ--

**ស៖** យើងដឹងហើយថា រឿងរ៉ាវនោះវាយូរណាស់ទៅហើយ ក៏ប៉ុន្តែនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបានរៀបរាប់ឈ្មោះមួយចំនួន គឺនៅចម្លើយ២៧, ២៨ ក៏ដូចជាចម្លើយ២៨៥។ អម្បាញ់មិញនេះលោកស្រីនិយាយអំពីឈ្មោះ ខុម ដែលជាកូនរបស់ តាម៉ុក នៅចំពោះមុខចៅក្រមស៊ើបអង្កេត នៅចម្លើយទី២៧ លោកស្រីនិយាយអំពីគណៈស្រុកត្រាំកក់ ដែលមាន តាគិត, តាចាយ និង តាជឹម។ នៅចម្លើយទៅ២៨ លោកស្រីនិយាយថា យាយខុម និង តាជឹម ហ្នឹងគឺជាសមាជិកគណៈស្រុកដំបូងគេម្ល៉េះ គឺតាំងពីឆ្នាំ៧៣។ បន្ទាប់មកទៀត មានតាគិត, តាចាយ។ ក្រោយមក លោកស្រីរៀបរាប់អំពីឈ្មោះរបស់តា -- មុខងាររបស់ តាញ៉េវ ដែលជាអ្នកទទួលខុសត្រូវខាងផ្នែកយោធា។ ជាចុងក្រោយនោះ លោកស្រីបញ្ជាក់ថា លេខាស្រុកចុងក្រោយគេ គឺតាសាន ហើយជាមួយនឹង តាសាន នេះហើយដែលលោកស្រីបានធ្វើការជាមួយចាប់ពីខែតុលា ឆ្នាំ១៩៧៨មកនោះ។ អ៊ីចឹងតើលោកស្រីមានចាំអំពីចម្លើយដែលលោកស្រីបានឆ្លើយនៅពេលនុ៎ងជូនសហចៅក្រមស៊ើបអង្កេតទេ?

[១០:១១:៤៩]

**ឆ៖** ចាស ខ្ញុំចាំបាន មានដូចអស់លោកលើកឡើងហើយថា ខុម – យាយខុម, តាគិត, តាចាយ និងក្រោយគេ តាសាន ចាស។ ខ្ញុំភ្លេច។

**ស៖** ដូច្នេះ គឺលោកស្រីឆ្លើយថា តាសាន ហ្នឹងជាលេខាស្រុកត្រាំកក់ចុងក្រោយ មុនពេលវៀតណាម វ៉ៃចូល ហើយសាក្សីផ្សេងទៀតក៏ឆ្លើយអ៊ីចឹងដែរ។ តាសាន ត្រូវបានស្តាប់ចម្លើយដោយអង្គ

ជំនុំជម្រះកាលពីថ្ងៃ០៩ ខែមីនា ឆ្នាំ២០១៥ គឺឯកសារប្រតិចារឹក E1/173.1 គាត់និយាយថា សាក្សី ហើយនិងលោកស្រីផងច្រឡំ ដែលនិយាយថា គាត់ហ្នឹងជាលេខាស្រុក។ តាមពិត គាត់មិនមែនជាលេខាស្រុកទេ គាត់គ្រាន់តែជាលេខាស្រុក ដែលចាត់តាំងដោយ តាម៉ុក តែប៉ុណ្ណោះ សម្រាប់ធ្វើការមួយចំនួន ដែល តាម៉ុក ចាត់តាំង។ គាត់ថា "តារ៉ន ដែលជួនកាលនៅតំបន់១៣ ដែលជាអ្នកដឹកនាំស្រុកត្រាំកក់នោះ មិនមែនគាត់ទេ" ក៏ប៉ុន្តែតាសាន ហ្នឹងក៏បាននិយាយថាផងដែរ "មានតែគាត់ ហើយនិងលោកស្រីទេ នៅក្នុងគណៈស្រុកនៅឆ្នាំ៧៨"។ អ៊ីចឹងលោកស្រីឯកភាពជាមួយគាត់ទេ? គាត់ឈ្មោះពិតគាត់ហ្នឹង គឺ នាង អ៊ូច។ គាត់និយាយថា គាត់មិនមែនជាលេខាស្រុកទេ ឬក៏ប្រធានស្រុកទេ តើលោកស្រីអាចបញ្ជាក់បានទេថានៅក្នុងស្រុកត្រាំកក់ នៅឆ្នាំ១៩៧៨ហ្នឹង គឺថាគាត់មិនមានឋានៈជាលេខាស្រុកទេ តើថាអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន ព្រោះមានឈ្មោះ រ៉ន ខ្ញុំភ្លេច។ រ៉ន អ្នកទទួលខុសត្រូវរួម។

[១០:១៥:២៤]

**ស៖** លោកស្រីនិយាយថា ពិតហ្នឹងយ៉ាងម៉េច? មានន័យថា តាសាន ជាលេខាស្រុកចុងក្រោយគេរបស់ត្រាំកក់ហ្នឹង ឬក៏យ៉ាងម៉េច? ហើយចុះ រ៉ន ហ្នឹងមុខងារគាត់ពិតប្រាកដហ្នឹង គាត់ធ្វើអីដែរ រ៉ន ហ្នឹង តារ៉ន?

**ឆ៖** រ៉ន ហ្នឹងមុខងារគាត់ទទួលតំបន់ផង តែគាត់ទទួលគ្រប់គ្រងស្រុកត្រាំកក់។

**ស៖** នៅក្បែរគណៈស្រុកហ្នឹង តើមានមន្ទីរស្រុក ដែលមានទទួលខុសត្រូវខាងសេដ្ឋកិច្ច ហើយនិងខាងសន្តិសុខទេ?

**ឆ៖** នៅក្បែរហ្នឹង មិនមានធំដុំទេ មានតែផ្ទះមួយសម្រាប់ទុកដាក់សេដ្ឋកិច្ចផ្គត់ផ្គង់នៅក្នុងស្រុកហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ លោកស្រី ខឹម បឿន ឥឡូវនេះដល់ពេលសម្រាកហើយ ហើយសូមលោកស្រីសម្រាក ហើយសម្រាកពេលនេះ រហូតដល់ម៉ោងដប់កន្លះ សូមលោកស្រីមកកាន់កន្លែងផ្តល់សក្ខីកម្មបន្តទៀត។

អញ្ជើញសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៦ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣២:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ខឹម បឿន។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រីសាក្សី យើងបាននិយាយអំពីមន្ទីរស្រុកត្រាំកក់អម្បាញ់មិញនេះ។ អ៊ីចឹងលោកស្រីអាចជម្រាបបានទេថា អ្នកណាជាអ្នកប្រធានមន្ទីរស្រុកត្រាំកក់ នៅពេលដែលលោកស្រីធ្វើជាមេឃុំជាងទង? ហើយនិងបន្ទាប់មកទៀតនៅពេលដែលលោកស្រីឡើងជាអនុប្រធានស្រុកត្រាំកក់នោះ?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស សូមៗសំណួរម្តងទៀត។

**ស៖** អម្បាញ់មិញនេះយើងនិយាយអំពីគណៈស្រុក។ ឥឡូវនេះយើងនិយាយអំពីមន្ទីរស្រុកវិញម្តង គឺជាអង្គភាពពីរផ្សេងគ្នា។ លោកស្រីនិយាយថា មន្ទីរស្រុកហ្នឹងជាអ្នកទទួលខាងសេដ្ឋកិច្ច តើលោកស្រីអាចជម្រាបបានទេថា អ្នកណាជាប្រធានមន្ទីរស្រុក នៅពេលដែលលោកស្រីធ្វើជាលេខាឃុំជាងទង និងក្រោយមកទៀតនៅពេលដែលលោកស្រីឡើងជាអនុប្រធានស្រុកត្រាំកក់? អ៊ីចឹងខ្ញុំចង់ដឹងថាតើអ្នកណាជាប្រធានមន្ទីរស្រុកត្រាំកក់?

**ឆ៖** ចាស ពីមុនឈ្មោះ ដន។

**ស៖** តើមានកម្មាភិបាលផ្សេងទៀតដែលធ្វើការនៅមន្ទីរស្រុកដែរ ឬទេ? លោកស្រីស្គាល់ឈ្មោះ ភី, ឃន និង អ៊ុល ហឿន លោកស្រីមានស្គាល់ឈ្មោះទាំងហ្នឹងទេ?

[១០:៣៥:២៤]

**ឆ៖** ចាស ស្គាល់។

**ស៖** តើអ្នកទាំងហ្នឹងមានតួនាទីអីដែរនៅក្នុងមន្ទីរស្រុក?

**ឆ៖** ចាស អ្នកទាំងអស់ហ្នឹងមានតួនាទីខាងសេដ្ឋកិច្ចផង ខាងឈ្លបស្រុកផង។

**ស៖** អ៊ីចឹងមានន័យថា មន្ទីរស្រុកកាន់ខាងសេដ្ឋកិច្ច និងគ្រប់គ្រងឈ្លបស្រុក។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ឈ្លបស្រុកគឺឈ្មោះ ភី, ឈ្មោះ ចន។ ឯសេដ្ឋកិច្ចគឺឈ្មោះ ដន។

**ស៖** តើលោកស្រីអាចជម្រាបបានទេថា ឌុច គាត់ធ្វើការនៅក្នុងមន្ទីរណា? ឬហៅថាគាត់ អៀប ឌុច ហើយគាត់ជាអ្នកទទួលខុសត្រូវខាងយុវជនថ្នាក់ស្រុក តើលោកស្រីធ្លាប់ជួបគាត់ទេ ហើយតើគាត់ធ្វើការនៅមន្ទីរស្រុកដែរ ឬទេ?

**ឆ៖** ចាស ឌុច ធ្លាប់ជួប។ គាត់នៅមន្ទីរស្រុកខាងយុវជន។

**ស៖** តើលោកស្រីដឹងទេថា គាត់ហ្នឹងក៏មានតួនាទីផងដែរ នៅមន្ទីរសន្តិសុខក្រាំងតាចាន់?

**ឆ៖** ចាស ខ្ញុំអត់បានដឹង។

**ស៖** ពាក់ព័ន្ធទៅនឹងទីតាំងគណៈស្រុក និងមន្ទីរស្រុក លោកស្រីនិយាយថា កន្លែងទាំងពីរហ្នឹងនៅជិតគ្នា។ អ៊ីចឹងខ្ញុំចង់ដឹងថា តើកន្លែងទាំងពីរហ្នឹងមានទីតាំងនៅឯណាដែរ?

**ឆ៖** ចាស នៅអង្គរកា។

**ស៖** គឺនៅជិតឃុំជាងទង ឬក៏នៅចន្លោះជាងទង ហើយនិងត្រពាំងធំខាងជើង?

**ឆ៖** ចាស នៅចន្លោះឃុំជាងទង និងត្រពាំងធំ។

[១០:៣៨:៥៧]

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីការប្រជុំនៅគណៈស្រុក និងដែលលោកស្រីចូលរួមផងដែរក្នុងឋានៈជាមេឃុំ។ នៅចម្លើយ១៥៩ លោកស្រីនិយាយថា មានការប្រជុំធម្មតានៅស្រុកហ្នឹង គឺបីដងមួយខែ ថ្ងៃ១០ ថ្ងៃ២០ និងថ្ងៃទី៣០។ គឺបានន័យថាបីដងក្នុងមួយខែ ហើយលោកស្រីក៏បាននិយាយថាផងដែរអំពីការប្រជុំអប់រំ។ តើមេស្រុក ឬអនុស្រុក គាត់និយាយអ្វីខ្លះនៅក្នុងពេលប្រជុំធម្មតានៅក្នុងស្រុកអង្គរកានោះ?

**ឆ៖** ចាស ខ្ញុំចាំមិនបានអស់ទេ ប៉ុន្តែគ្រាន់ដឹងថា គាត់បាននិយាយអប់រំ ពិសេសគឺសេដ្ឋកិច្ច

ដោះស្រាយជីវភាពឲ្យប្រជាជន ថ្ងៃ១០ ថ្ងៃ២០។ ក្រៅពីនេះ ខ្ញុំអត់បានចាំទេ។

**ស៖** នៅក្នុងរបៀបវារៈប្រជុំហ្នឹង តើគេមាននិយាយអំពីសភាពការណ៍ខ្មាំង វិន័យរបស់ប្រជាជន ជាពិសេសវិន័យរបស់ពួក១៧មេសា ឬក៏អ្នកថ្មីនេះ។ គេមាននិយាយអំពីចំណុចទាំងពីរហ្នឹងទេ?

**ឆ៖** ចាស មាននិយាយ តែខ្ញុំមិនបានចាំអស់។ ភ្លេចបាត់អស់ហើយ។

**ស៖** នៅពេលប្រជុំនៅថ្នាក់ស្រុកនោះ តើមានការឡើងរាយការណ៍ដូចជាលោកស្រី ឡើងរាយ-ការណ៍ក្នុងឋានៈជាមេឃុំ ហើយនិងមានការណែនាំអ្វីពីខាងថ្នាក់ស្រុកមកវិញទេ?

**ឆ៖** ចាស មាន។

[១០:៤១:៣៤]

**ស៖** នៅចម្លើយ១៥៧ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី លោកស្រីបានពន្យល់ថា នៅពេលប្រជុំអប់រំគេបាននិយាយថា “ភូមិត្រូវរាយការណ៍មកឃុំ ហើយឃុំរាយការណ៍មកស្រុក”។ ហើយចម្លើយ១៥៨ លោកស្រីនិយាយថា “នៅក្នុងការប្រជុំនោះ គេនិយាយថា បើមានសភាពការណ៍អ្វីនៅក្នុងភូមិត្រូវរាយការណ៍មកឃុំជាបន្ទាន់ ហើយឃុំត្រូវរាយការណ៍ទៅស្រុកជាបន្ទាន់ដែរ”។ អ៊ីចឹងខ្ញុំចង់ដឹងថាតើនេះជាប្រព័ន្ធពីរ៉ាមីតមែនទេ គឺថា ពីភូមិ ឬសហករណ៍រាយការណ៍ឡើងទៅថ្នាក់ឃុំ ហើយថ្នាក់ឃុំរាយការណ៍ឡើងទៅថ្នាក់ស្រុកជាបន្តបន្ទាប់ អ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** លោកស្រីធ្វើការនៅថ្នាក់ស្រុក គឺនៅឆ្នាំ១៩៧៨ លោកស្រីក៏បានឆ្លើយថា បានចូលរួមកិច្ចប្រជុំជាច្រើននៅតំបន់១៣។ តើលោកស្រីអាចរៀបរាប់បានទេថា មេស្រុកនោះ មេស្រុកត្រាំកក់ហ្នឹងគាត់រាយការណ៍អ្វីខ្លះទៅកាន់តំបន់១៣ នៅក្នុងពេលប្រជុំ? ឬក៏មានធ្វើជារបាយការណ៍ជាលាយលក្ខណ៍អក្សរ? អ៊ីចឹងខ្ញុំចង់ដឹងថាតើថ្នាក់ស្រុកហ្នឹងគាត់រាយការណ៍ប្រភេទណាខ្លះទៅថ្នាក់តំបន់នោះ?

**ឆ៖** ចាស គាត់អត់មានលាយលក្ខណ៍អក្សរទេ គាត់រាយការណ៍ពីយោធា សេដ្ឋកិច្ច នយោ-បាយ។ តែខ្ញុំមិនបានចាំអស់ទេ គ្រាន់តែដឹងជាគោល។

[១០:៤៣:៥៧]

**ស៖** ពាក់ព័ន្ធទៅនឹងអ្នកចូលរួមក្នុងកិច្ចប្រជុំធម្មតានៅថ្នាក់ស្រុក។ ក្រៅពីមេឃុំ និងគណៈឃុំ ឬក៏មន្ទីរស្រុក គណៈស្រុក តើមានកម្មាភិបាលមកពីមន្ទីរសន្តិសុខក្រាំងតាចាន់មកចូលរួមដែរទេ?

**ឆ៖** ចាស ជួនកាលមក ជួនកាលអត់។

**សៈ** លោកស្រីបាននិយាយថាបានជួប តាអាន់ ដែលជាប្រធានគុកក្រាំងចាន់នៅក្នុងរបបនោះ។ អ៊ីចឹងជួបហ្នឹង ជួបនៅពេលប្រជុំនៅថ្នាក់ស្រុក ឬក៏នៅថ្នាក់តំបន់?

**ឆៈ** ចាស ជួបនៅក្នុងថ្នាក់ស្រុក។

**សៈ** តើនៅពេលប្រជុំនៅថ្នាក់ស្រុកហ្នឹង តាអាន់ មានរាយការណ៍ជូនទៅគណៈស្រុកទេ?

**ឆៈ** ចាស មានរាយការណ៍ តែខ្ញុំអត់បានចាំទេ។

**សៈ** លោកស្រីបាននិយាយថា មានការធ្វើរបាយការណ៍។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើគាត់មានរាយការណ៍ផ្ទាល់មាត់ ពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខនៅក្រាំងតាចាន់ ជូនទៅថ្នាក់ស្រុកទេ?

**ឆៈ** ចាស គាត់អាចមាន តែខ្ញុំអត់បានចាំទេ ព្រោះខ្ញុំអត់ទទួល អត់បានទទួល។

**សៈ** តើលោកស្រីធ្លាប់ឮគេនិយាយអំពីបណ្ដាញគិញទេ នៅក្នុងពេលប្រជុំទាំងនោះ?

**ឆៈ** ចាស ធ្លាប់មានឮ។

**សៈ** តើតាអាន់ គាត់មានបានផ្ដល់តួលេខពាក់ព័ន្ធទៅនឹងអ្នកទោស នៅក្រាំងតាចាន់ ហើយនិងតួលេខអ្នកទោសដែលត្រូវបានបោសសម្អាតជាប្រចាំខែទេ?

**ឆៈ** ខ្ញុំអត់បានដឹងទេ។

**សៈ** នៅពេលដែលប្រជុំថ្នាក់ស្រុក តើលោកស្រីមានធ្លាប់ឈ្មោះ ម៉េង ទេ? គាត់ជាប្រធានមន្ទីរឃុំឃាំងមួយនៅខាងលិចអង្គរការ -- សូមទោស គឺនៅខាងកើតអង្គរកា?

**ឆៈ** ចាស ខ្ញុំអត់ស្គាល់ផង។ អត់ស្គាល់ឈ្មោះហ្នឹងផង។

[១០:៤៧:៥៣]

**សៈ** ឥឡូវនេះ ខ្ញុំនិយាយអំពីកិច្ចប្រជុំបន្ទាន់ ឬចាំបាច់នៅស្រុក១០៥ ដែលប្រព្រឹត្តទៅនៅពេលផ្សេង នៅពេលដែលសភាពការតម្រូវ។ តើលោកស្រីអាចជម្រាបបានទេថា នៅពេលណាដែលគេធ្វើកិច្ចប្រជុំបន្ទាន់ ឬវិសាមញ្ញនៅស្រុក១០៥? ហើយនៅពេលដែលប្រជុំបន្ទាន់ហ្នឹង គេនិយាយអំពីអ្វីដែរ?

**ឆៈ** ខ្ញុំអត់បានចាំ។

**សៈ** នៅចម្លើយ១៦០នៃកំណត់ហេតុរបស់លោកស្រីនុំង លោកស្រីបាននិយាយថា “ប្រជុំបន្ទាន់មានច្រើនយ៉ាង ឧទាហរណ៍ថានៅក្នុងឃុំមានស្រូវអង្ករលើស ហើយឃុំណាដែលខ្វះនោះ គេហៅខ្ញុំទៅភ្លាម ដើម្បីចែករំលែកស្រូវអង្ករដែលលើសនោះយកទៅកន្លែងដែលខ្វះខាត”។ ក៏ប៉ុន្តែនៅចម្លើយ១៦១ លោកស្រីក៏បាននិយាយផងដែរថា “នៅពេលប្រជុំហ្នឹង ក៏គេនិយាយអំពីបញ្ហាសន្តិសុខដែរ អ៊ីចឹងកិច្ច

ប្រជុំបែបហ្នឹង ក៏គេហៅថាកិច្ចប្រជុំបន្ទាន់ដែរ”។ អ៊ីចឹង តើលោកស្រីអាចជម្រាបបានទេ តើមានបញ្ហាសន្តិសុខបែបណាដែលតម្រូវឲ្យមានការប្រជុំបន្ទាន់បែបនោះនោះ? លោកស្រីអាចផ្តល់ជាឧទាហរណ៍បានទេ?

**ឆ៖** ចាស មានតែប្រជុំបន្ទាន់ មានតែពេលដែលវៀតណាមជិតដល់ក្នុងស្រុកហ្នឹង បានប្រជុំបន្ទាន់។

**ស៖** នៅខែមេសា ឆ្នាំ១៩៧៥ មុនពេលអ្នកជម្លៀសពីភ្នំពេញមកដល់នោះ តើមានកិច្ចប្រជុំបន្ទាន់នៅថ្នាក់ស្រុកទេ?

**ឆ៖** ចាស មានដែរ។

[១០:៥០:៤៣]

**ស៖** តើកិច្ចប្រជុំបន្ទាន់ហ្នឹងគឺដើម្បីត្រៀមរៀបចំកម្មាភិបាលសម្រាប់ការមកដល់នៃជម្លៀសពីភ្នំពេញ និងតាកែវមែនទេ?

**ឆ៖** ចាស។

**ស៖** អ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំពាក់ព័ន្ធទៅនឹងអ្នកជម្លៀសពីភ្នំពេញនោះ? ជាប្រធានស្រុក ជាប្រធានតំបន់ ឬក៏ជា តាម៉ុក?

**ឆ៖** កាលនោះខ្ញុំភ្លេចបាត់ទៅហើយ មិនមែន តាម៉ុក ទេគឺថ្នាក់ត្រឹមតំបន់ ស្រុកនេះទេ។ អត់មាន តាម៉ុក ទេ។

**ស៖** តើលោកស្រី -- គេប្រាប់លោកស្រីអ្វីខ្លះពាក់ព័ន្ធទៅនឹងការជម្លៀសមកពីភ្នំពេញ ហើយនិងតាកែវនុ៎ង? គេមានណែនាំអ្វីខ្លះទេនៅពេលដែលអ្នកជម្លៀសហ្នឹងមកដល់កន្លែងរបស់លោកស្រីនោះ?

**ឆ៖** ចាស មានរៀបចំឲ្យទីកន្លែងនៅ ចែកចាយតាមភូមិដើម្បីរៀបចំស្បៀង។

[១០:៥២:៣៨]

**ស៖** មុនពេលដែលអ្នកជម្លៀសមកដល់ឃុំរបស់លោកស្រីហ្នឹង គេមានប្រមូលផ្តុំអ្នកជម្លៀសហ្នឹងដាក់កន្លែងម្តុំជាក់លាក់សិនទេ មុននឹងបញ្ជូនទៅឃុំនោះ? នៅក្នុងកំណត់ហេតុ គឺនៅក្នុងចម្លើយ១០១ ខ្ញុំនឹងអានជាភាសាអង់គ្លេស ខ្ញុំសូមដកស្រង់៖ “តាមខ្ញុំចាំ ដំបូងគេយកប្រជាជនទាំងអស់នោះទៅដាក់ម្តុំសិន បន្ទាប់មកគេចែកទៅតាមភូមិដែលរស់នៅចម្រុះគ្នា”។ សូមបញ្ចប់ការដកស្រង់។ លោកស្រីបាននិយាយអំពីកន្លែងមួយដែលគេប្រមូលផ្តុំ យកទៅដាក់សិន។ អ៊ីចឹងខ្ញុំចង់ដឹងថា គេប្រមូលផ្តុំអ្នកជម្លៀស

មកពីភ្នំពេញហ្នឹងយកទៅដាក់កន្លែងណាសិន?

**ឆ៖** ចាស គេដាក់នៅម្តុំជិតវត្តចំប៉ា។

**ស៖** លោកស្រីផ្ទាល់ហ្នឹង លោកស្រីមានទៅដល់វត្តចំប៉ាហ្នឹងទេ នៅពេលនោះនុំងដើម្បីមើលថាតើមានរឿងអ្វីកើតឡើងនៅក្នុងវត្តហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំអត់បានទៅទេ។

**ស៖** លោកស្រីបានចូលរួមប្រជុំរៀបចំ តើក្នុងពេលប្រជុំនោះមានការផ្តល់ការណែនាំអីដែរឬទេដើម្បីឱ្យអ្នកដែលជម្លៀសមកពីទីក្រុងភ្នំពេញនោះត្រូវបានគេកំណត់ប្រវត្តិរូប ដូចជា នាយទាហានជាន់ខ្ពស់ អតីតមន្ត្រីរដ្ឋការជាន់ខ្ពស់របស់ លន់ នល់ អីជាដើមនោះ? គឺថានៅពេលដល់វត្តចំប៉ាហើយហ្នឹងមានការធ្វើយ៉ាងដូច្នេះដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹង ព្រោះខ្ញុំអត់បានទៅរួម អនុរបស់ខ្ញុំទៅ។

**ស៖** នៅពេលដែលពួកអ្នកគេជម្លៀសហ្នឹងមកដល់ក្នុងឃុំរបស់លោកស្រីហើយ ជម្លៀសមកពីទីក្រុងភ្នំពេញហ្នឹង តើត្រូវកត់ប្រវត្តិរូបរបស់ពួកគេ ហើយនិងតាមដានគេដែរឬទេ ពីព្រោះពួកគេទាំងអស់នោះសុទ្ធតែមកពីទីក្រុងភ្នំពេញ?

**ឆ៖** ចាស មានកត់ប្រវត្តិរូប។

[១០:៥៥:៤០]

**ស៖** តើប្រជាជន១៧មេសា ដូចដែលលោកបានស្រីលើកអម្បាញ់មិញនេះ លោកស្រីអម្បាញ់មិញបាននិយាយអំពីការរៀបការដោយបង្ខំ តើប្រជាជនថ្មីនៅពេលនោះត្រូវបានចាត់ទុកថាជាខ្មាំងដែរឬទេ ពីព្រោះថាអ្នកក្រុងហ្នឹង ក្រុងហ្នឹងអាចធ្វើឱ្យផ្ទត់គំនិតគេហ្នឹងខូច មិនល្អ?

**ឆ៖** ខ្ញុំអត់មានបានថា ចាត់ទុកថាជាខ្មាំងទេ គឺខ្ញុំថាតាមខាងលើ ថាពីមុននោះ។

**ស៖** បាទ ឥឡូវខ្ញុំសូមអានសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី គឺឯកសារ E319/12/3/2 គឺសំណួរ និងចម្លើយ២៥៤ ហើយនិង២៥៥។ បាទ ខ្ញុំសូមអានជាភាសាអង់គ្លេសសូមដកស្រង់៖ “សំណួរ២៥៤៖ នៅពេលដែលមេឃុំចាប់ផ្តើមប្រមូលប្រវត្តិរូបពីប្រជាជន ហើយរកឃើញថាអ្នកណាម្នាក់ជាប់ពាក់ព័ន្ធរបបលន់នល់ តើមានអ្វីកើតឡើងចំពោះអ្នកដែលរកឃើញជាប់ពាក់ព័ន្ធនឹងរបបលន់នល់នោះ?” លោកស្រីបានឆ្លើយថា “គឺចម្លើយ២៥៤៖ នៅពេលចាប់ផ្តើមរបបខ្មែរក្រហមភ្លាមៗ គឺចាប់ផ្តើមធ្វើប្រវត្តិរូបថាអ្នកខ្លះធ្លាប់ធ្វើជាគ្រូបង្រៀន អ្នកណាជាប៉ូលិស ឬក៏ជាមន្ត្រី

រាជការនៅក្នុងរបបលន់នល់។ បន្ទាប់មកបញ្ជូនប្រវត្តិរូបទាំងអស់នោះទៅថ្នាក់លើ។ នេះគឺជាបញ្ជាពីខាងលើមកឲ្យខ្ញុំធ្វើដូច្នេះ។ សំណួរ២៥៥៖ តាមអ្វីដែលលោកស្រីដឹង តើមានអ្វីកើតឡើងចំពោះអ្នកដែលជាប់ពាក់ព័ន្ធនឹងរបបលន់នល់? ឆ្លើយ៖ ក្រោយបញ្ជូនប្រវត្តិរូបទៅលើហើយ ខាងលើបានស្រង់ឈ្មោះអ្នកនោះមកឲ្យខ្ញុំ បន្ទាប់មក ខ្ញុំបញ្ជាឲ្យគេដើរចាប់អ្នកទាំងអស់នោះ រួចបញ្ជូនទៅខាងលើវិញ។ មានអ្នកខ្លះក៏បានត្រឡប់មកវិញ ហើយអ្នកខ្លះមិនបានត្រឡប់មកវិញទេ។ មនុស្សដែលត្រូវជាប់ខ្លួន ភាគច្រើនគឺទាហាន និងប៉ូលិស។ គ្រូបង្រៀនមិនសូវត្រូវបានបញ្ជូនទៅនោះទេ”។ សូមបញ្ចប់ការដកស្រង់។

បាទ ប្រវត្តិរូបរបស់គ្រូបង្រៀន របស់នគរបាល យោធា ឬក៏អតីតមន្ត្រីរដ្ឋការលន់នល់ ដែលលោកស្រីបាននិយាយនៅក្នុងសម្រង់ ដែលខ្ញុំទើបតែអានជូនលោកស្រីស្តាប់អម្បាញ់មិញនេះ តើប្រវត្តិរូបទាំងអស់នេះត្រូវបានធ្វើដោយសមាជិក ឬក៏កម្មាភិបាលឃុំរបស់លោកស្រីដែរឬទេ នៅពេលដែលពួកគេទាំងអស់ចេញពីវត្តចំប៉ាលើក ហើយទៅខាងជាងទងវិញនោះ?

[១០:៥៩:១៨]

**ឆ៖** ចាស ខ្ញុំស្តាប់អត់បាន សូមម្តងទៀត។

**ស៖** បាទ ខ្ញុំសួរម្តងទៀត នៅពេលដែលពួកគាត់ទាំងអស់នោះទៅដល់ឃុំជាងទង ដែលលោកស្រីជាប្រធាន តើអ្នកណាជាអ្នកធ្វើប្រវត្តិរូបរបស់អ្នកដែលគេជម្លៀសពីភ្នំពេញទៅទាំងអស់នេះ?

**ឆ៖** ចាស គឺតាមភូមិដែលយកទៅដាក់ ភូមិគេធ្វើបញ្ជូនមក ហើយយើងយកប្រជាជនទៅដាក់។

**ស៖** ក៏ប៉ុន្តែលោកស្រីបាននិយាយពីប្រវត្តិរូបដែលគេបានធ្វើ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកណានៅក្នុងឃុំជាងទងនេះ ទទួលបន្ទុកសួរមនុស្សទាំងអស់នោះ ដើម្បីប្រមូលផ្តុំប្រវត្តិរូបរបស់គាត់នោះ របស់អ្នកដែលគេជម្លៀសមកទីក្រុងភ្នំពេញ តើជាលេខាឃុំ ឬក៏ក្រឡាបញ្ជី ឬក៏ស្មៀន ឬក៏អ្នកទទួលបន្ទុកខាងសន្តិសុខ ឬខាងអីផ្សេង? អ៊ីចឹងលោកស្រីអាចបញ្ជាក់ជូនតុលាការបានទេ អ្នកណាគេជាអ្នកទទួលបន្ទុកខាងធ្វើប្រវត្តិរូបទាំងអស់ហ្នឹង?

**ឆ៖** ចាសដូចខ្ញុំជម្រាបហើយ គឺភូមិធ្វើ ឲ្យភូមិធ្វើមក បញ្ជូនមកឃុំ ចាស។ ប្រធានភូមិធ្វើហើយបញ្ជូនមកឃុំ ឃុំបញ្ជូនទៅលើទៀត។

**ស៖** តើលោកស្រីដឹងថា អ្នកណានៅថ្នាក់ស្រុកហ្នឹងទទួលបន្ទុកខាងវិភាគប្រវត្តិរូបអ្នកដែលគេជម្លៀស ដែលលោកស្រីបានបញ្ជូនទៅនោះ តើជាអ្នកនៅក្នុងគណៈស្រុក ឬក៏មន្ទីរស្រុកដែលគេធ្វើការវិភាគប្រវត្តិរូបដែលលោកស្រីផ្ញើទៅឲ្យ?

[១១:០១:៤៥]

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះការងារខាងស្រុក។

**ស៖** លោកស្រីបាននិយាយថា បន្ទាប់មកគេផ្ញើបញ្ជីឈ្មោះ អ្នកដែលត្រូវចាប់ខ្លួន គឺថាឈ្មោះនៅក្នុងចំណោមអ្នកដែលគេបានជម្លៀសចេញពីភ្នំពេញពីតាកែវទៅនោះ។ តើលោកស្រីមានបានដឹងដែរឬទេ តាមរបៀបណាមួយនោះ ដឹងថា តើនៅក្នុងមន្ទីរឃុំឃាំងណាដែលគេបញ្ជូនមនុស្សទាំងអស់នេះទៅនោះ?

**ឆ៖** ខ្ញុំមិនបានដឹងទេ។

**ស៖** បាទ ឥឡូវខ្ញុំសូមចូលទៅនិយាយពីរយៈពេលមួយទៀត។ យើងអម្បាញ់មិញនេះយើងទើបតែនិយាយអំពីការជម្លៀសមនុស្ស បន្ទាប់ពីថ្ងៃ១៧ មេសា ភ្លាមៗ ហើយកាលនោះគេស្វែងរកអតីតមន្ត្រីរដ្ឋការ ប៉ូលិស ហើយនិងគ្រូបង្រៀន។ ឥឡូវ ខ្ញុំសូមចូលមកនិយាយអំពីរយៈពេលក្រោយហ្នឹងទៀត គឺពីខែមេសា និងខែឧសភា ឆ្នាំ១៩៧៧។ នៅក្នុងរយៈពេលនេះ លើសពីប្រវត្តិរូបដែលគេបាន -- លោក តើលោកបានទទួលពីមេឃុំទាំងអស់ហ្នឹង អំពីបញ្ជីដែលមានរៀបរាប់ឈ្មោះអតីតមន្ត្រីរដ្ឋការ យោធា សម័យលន់ នល់ ដែរឬទេ? លោកស្រីស្ដាប់សំណួរខ្ញុំឮទេ?

[១១:០៤:០០]

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទ មានបញ្ហាប្រព័ន្ធវីដេអូខាង ផ្នែកខាងសាក្សីឯណោះ។ ឥឡូវនេះ កំពុងតែ អ្នកបច្ចេកទេសកំពុងតែពិនិត្យលទ្ធភាពដើម្បីតភ្ជាប់ឡើងវិញ។

*(មានបញ្ហាបច្ចេកទេស)*

[១១:០៦:០២]

**ប្រធានអង្គជំនុំ៖**

សួស្ដី លោកស្រី ខឹម បឿន!

**លោកស្រី ខឹម បឿន៖**

ចាស ជម្រាបសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវ យើងនេះ ដំណើរការបន្តទៅទៀត។ ឥឡូវ អង្គជំនុំជម្រះបន្តផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ខឹម បឿន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ សូមអរគុណលោកស្រីសាក្សី ខ្ញុំមិនដឹងថាលោកស្រីបានឮសំណួរខ្ញុំអម្បាញ់មិញទេ ប៉ុន្តែ ឥឡូវខ្ញុំចូលមកនិយាយពីដំណាក់មួយទៀតនៃរបបខ្មែរក្រហម មិនមែនក្រោយពេលជម្លៀសទីក្រុងភ្នំពេញភ្លាមៗទេ គឺនិយាយពីរយៈពេលចន្លោះខែមេសា ហើយនិងឧសភា ឆ្នាំ១៩៧៧។ ខ្ញុំសួរលោកថា បន្ថែមលើប្រវត្តិរូប តើលោកស្រីមានបានទទួលបទបញ្ជាពីតំបន់ ឬក៏ស្រុក ទៅឲ្យធ្វើបញ្ជីរបស់ក្រុមគ្រួសាររបស់អតីតយោធាលន់ នល់ ឬក៏អតីតមន្ត្រីរដ្ឋការលន់ នល់ ដែរឬទេ?

[១១:០៧:២០]

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ខ្ញុំអត់ចាំបាន។

**ស៖** តើលោកស្រីមានចាំដែរឬទេ ថាមានពេលណាមួយនោះ មានការណែនាំមកពីថ្នាក់លើ ដែលតម្រូវឲ្យចាប់អតីតយោធា ហើយនិងមន្ត្រីរដ្ឋការលន់ នល់ នៅរវាងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨?

**ឆ៖** ចាស ខ្ញុំអត់បានដឹង។

**ស៖** បាទ ឥឡូវ ខ្ញុំសូមរំឮកការចងចាំរបស់លោកស្រី ហើយខ្ញុំនឹងបង្ហាញឯកសារមួយចំនួន គឺឯកសារដែលលោកស្រីហ្នឹងប្រហែលជាមាននៅក្នុងដៃហើយ។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារទាំងអស់នេះ នៅលើអេក្រង់។ ឯកសារមួយចំនួន លោកប្រធាន។ ឯកសារទី១ គឺឯកសារ E3/2048 មានទំព័រជាច្រើនដែលយើងខ្ញុំចាប់អារម្មណ៍តែទំព័រទី១នោះ គឺទំព័រដែលមានលេខ ERN ជាភាសាខ្មែរគឺ 00079089។ បើសិនជាមេធាវីជំនួយការរបស់គាត់នោះអាចជួយបាននៅលើទំព័រហ្នឹង គឺឯកសារ E3/2048, ជាភាសាបារាំងគឺ 00611659 ជាភាសាអង់គ្លេសគឺ 00276562 ដល់ 63។

បាទ នេះជារបាយការណ៍ដែលផ្ញើដោយ បឿន។ មានការបកប្រែមួយចំនួនដែលនៅក្នុងសំណុំរឿងហ្នឹង បកប្រែថា មឿន។ ផ្ញើពី មឿន -- អ៎ ពី បឿន ហ្នឹង ចេញពីឃុំជាងទង ថ្ងៃទី៣០ មេសា ១៩៧៧ ទៅអង្គការស្រុកត្រាំកក់។ បាទ លោកសាក្សី បើសិនជាលោកស្រីមានឯកសារនេះនៅចំពោះ

មុខលោកស្រីហើយ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាមានឈ្មោះលោកស្រីនេះ ហើយនិងហត្ថលេខារបស់លោកស្រីនៅខាងផ្នែកខាងក្រោមនៃរបាយការណ៍នេះ?

**ឆះ** ចាស មិនច្បាស់។

[១១:១០:៣៣]

**សះ** បាទ ឥឡូវខ្ញុំសូមឲ្យលោកស្រីយកឯកសារនេះមើល គឺថាឯកសារ E3/2048 នៅទំព័រ ERN ជាភាសាខ្មែរគឺ 00079089។

**ប្រធានអង្គជំនុំ៖**

មេធាវីប្រឹក្សាសាក្សីជួយសម្របសម្រួលឯកសារជូនសាក្សីពិនិត្យ។

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកប្រធាន ខ្ញុំអត់ទាន់មានឯកសារ អត់ទាន់ឃើញគេបញ្ជូនឯកសារមកជូន។ E3/2048។

**ប្រធានអង្គជំនុំ៖**

E3/2048 ត្រង់ទំព័រ ERN 00079089។

[១១:១១:៥៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

នៅក្នុងឯកសារនេះជាភាសាខ្មែរត្រូវនឹងទំព័រទី៣។ តើលោកស្រីមានឯកសារនៅចំពោះមុខហើយឬនៅ? ព្រោះថាយើងបានផ្តល់ឯកសារ បញ្ជើឯកសារជូនលោកស្រីជាមុនរួចហើយ។

**លោក ម៉ម រិទ្ធា៖**

មើលអត់ឃើញ?

**លោកស្រី ខឹម បឿន៖**

មើលអត់ឃើញ។

**លោក ម៉ម រិទ្ធា៖**

ខ្ញុំអានឲ្យស្តាប់ណ៎ា!

**លោកស្រី ខឹម បឿន៖**

ចាស។

**លោក ម៉ម រិទ្ធា៖**

សេចក្តីឆ្លើយ -- ស្នើយោបល់។ សូមស្នើយោបល់មក--

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រី ខ្ញុំមិនសូមឱ្យលោកស្រីអានភ្លាមនោះទេ គ្រាន់តែសូមឱ្យមើលផ្នែកខាងក្រោមនៃឯកសារហ្នឹង ហើយសូមឱ្យលោកស្រីជម្រាបជូនថា ហ្នឹងពិតជាឈ្មោះលោកស្រីមែន ឬក៏យ៉ាងណា? ហើយនិងហត្ថលេខាលោកស្រីផងដែរ នៅផ្នែកខាងក្រោមនៃឯកសារហ្នឹងលោកស្រី?

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោក ឯកសារ--

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយតបៗ! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំទើបតែបានស្តាប់ឮពីក្រុមរបស់ខ្ញុំដែលថា គេអានអត្ថបទ គឺមេធាវីហ្នឹងអានអត្ថបទឱ្យសាក្សីស្តាប់។ តើវាអ៊ីចឹងមែនទេ? ប្រសិនបើដូច្នេះមែន ខ្ញុំគិតថាគួរតែកត់ត្រានូវអ្វីដែលមេធាវីបានអានឱ្យសាក្សីស្តាប់នោះ។

[១១:១៣:២៦]

**ប្រធានអង្គជំនុំ៖**

បាទ ជាការពិតហើយ ប៉ុន្តែទើបតែអានបានបន្តិចទេ ដោយសារវាជាកំហុសដែលមិនមែនបំណងរបស់សហព្រះរាជអាជ្ញាអន្តរជាតិចង់ធ្វើដូច្នេះទេ។ អ៊ីចឹង សហព្រះរាជអាជ្ញារងអន្តរជាតិបានកែតម្រូវវិញរួចហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសូមចោទសំណួរនេះទៅសាក្សីដដែល។ តើលោកស្រីស្គាល់ឈ្មោះ ហើយនិងហត្ថ-លេខានេះ ដែលជាឈ្មោះ ឬហត្ថលេខារបស់លោកស្រីហ្នឹងដែរឬទេ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស អត់ច្បាស់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមិនមែននិយាយពីអក្សរនៅក្នុងអត្ថបទទាំងអស់ហ្នឹងទេ ខ្ញុំនិយាយ

តែផ្នែកខាងក្រោមនេះ ដូចឈ្មោះ ហើយនិងហត្ថលេខានេះ។ ហើយយើងនឹងចូលទៅនិយាយអំពីអក្សរនៅពេលក្រោយ។ អ៊ីចឹងសួរថាឈ្មោះហ្នឹងជាឈ្មោះរបស់លោកស្រីមែនទេ? ហត្ថលេខារបស់លោកស្រីមែនទេ?

**ផ៖** ចាស ឈ្មោះៗខ្ញុំមែន ប៉ុន្តែអត់មានស៊ីញ៉េខ្ញុំទេ។ *(ឮអត់ច្បាស់)* តែខ្ញុំអត់មានស៊ីញ៉េ។

**ស៖** បាទ លោកស្រីឆ្លើយនៅក្នុងចម្លើយលេខទី២២៨ លោកនិយាយថា អក្សរហ្នឹង លោកស្រីសរសេរអក្សរមិនស្អាតទេ អ៊ីចឹងមានគេសរសេរជំនួសលោកស្រី។ តើជាទម្លាប់ ឬដែលមានមនុស្សម្នាក់សរសេររបាយការណ៍ទៅស្រុកហ្នឹងជំនួសលោកស្រី មែនទេ? ហើយលោកស្រីត្រួតពិនិត្យមើលរបាយការណ៍ហ្នឹងដែរមុននឹងបញ្ជូនទៅ?

[១១:១៦:២០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមសហព្រះរាជអាជ្ញារងមេត្តាបញ្ជាក់អំពីការស្រង់ចំណុចណានៅក្នុងឯកសារណាដែរ ដែលលោកលើកយកមកតាំងសំណួរអម្បាញ់មិញនេះ។ បាទ សូមអរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំអាចអាន ក៏ប៉ុន្តែយើងខាតពេលវេលាច្រើនណាស់លោកប្រធាន។ នៅក្នុងរបាយការណ៍របស់គាត់ គឺឯកសារ E319/12.3.2 នៅចម្លើយ២២៩ -- ២២៨ បាទសូមទោស "អក្សរដៃ ខ្ញុំសរសេរអក្សរមិនស្អាត អ៊ីចឹងមានគេសរសេរឲ្យខ្ញុំ"។ បញ្ចប់ការដកស្រង់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំជំទាស់ទៅនឹងការដកស្រង់បែបនេះ ព្រោះឯកសារនេះនិយាយអំពីរបាយការណ៍នៃការបញ្ជូនប្រជាជនមកដល់ភូមិ។ ដូច្នេះវាជាការរាយការណ៍ ដែលអ្វីដែលយើង -- ដែលគេនិយាយយោង ប៉ុន្តែដល់ពេលឥឡូវនេះ វាបែរជាទៅយោងឯកសារផ្សេង ឬឯកសារជាក់លាក់ណាមួយផ្សេងយកមកធៀបទៅវិញ។ ដូច្នេះ ខ្ញុំគិតថានេះវាជាការមិនត្រឹមត្រូវ ហើយខ្ញុំសូមធ្វើការជំទាស់។

[១១:១៧:៥៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចោទសំណួរទូទៅទេ ពីព្រោះថាលោកស្រីសាក្សីគាត់និយាយថា គាត់មិនបានទៅរៀនបានជ្រៅជ្រះ ហើយគាត់ក៏បានឆ្លើយថា មានគេអ្នកសរសេរជំនួសគាត់។ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរថា តើជាទូទៅ តាមទម្លាប់ហ្នឹង គេសរសេរឲ្យគាត់អ៊ីចឹងទេ។ ខ្ញុំមិនមែនចង់និយាយសម្រាប់កំណត់ហេតុស្តាប់ចម្លើយគាត់ទេ គឺឯកសារ E3/20/47 ខ្ញុំសួរសម្រាប់តែឯកសារមួយហ្នឹងតែប៉ុណ្ណឹងទេ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរគាត់ថា តើអ្នកណាជាអ្នកសរសេររបាយការណ៍មួយហ្នឹងឲ្យគាត់នៅសម័យខ្មែរក្រហមហ្នឹង។ តែប៉ុណ្ណឹងទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី ហើយសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិនូវសំណួរចុងក្រោយអម្បាញ់មិញនេះ។

[១១:១៩:០៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសូមសួរម្តងទៀត លោកស្រីបាននិយាយថា "ជួនកាលគេសរសេរឲ្យលោកស្រី"។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើអ្នកណា អ្នកសរសេរឲ្យលោកស្រី ហើយលោកស្រីជាអ្នកអានឲ្យគេសរសេរឲ្យ ឬដែលគាត់បុគ្គលរូបនោះ គាត់សរសេររបាយការណ៍ហ្នឹងឲ្យលោកស្រីនេះ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស មែន។

**ស៖** អ៊ីចឹងខ្ញុំចង់សួរថា តើអ្នកដែលសរសេរហ្នឹងជាលេខា -- ជាស្មៀននៅក្នុងឃុំរបស់លោកស្រី ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស។

**ស៖** តើលោកស្រីយល់ស្របដែរឬទេដើម្បីនិយាយថា ដោយសារមិញនេះលោកស្រីនិយាយថា ឈ្មោះនេះ ពិតជាឈ្មោះលោកស្រីហើយ។ តើលោកស្រីយល់ស្របដែរឬទេថា នៅក្នុងគណៈឃុំជាងទងមានមនុស្សម្នាក់ទៀត ឈ្មោះ ហឿន ដែរ ឬក៏យ៉ាងណា?

**ឆ៖** ចាស អត់ទេ។

[១១:២០:៣២]

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់ឯកសារនេះ មានការបកប្រែជាភាសាខ្មែរហើយ អ៊ីចឹងមិនបាច់អានឯកសារនេះ។ អ៊ីចឹងខ្ញុំសូមចោទសំណួរទាក់ទងនឹងអត្ថបទហ្នឹងតែម្ដង ដើម្បីឲ្យលោកស្រីហ្នឹងនឹកឃើញឡើងវិញអំពីខ្លឹមសារនៃរបាយការណ៍ហ្នឹង។ ខ្ញុំសូមដកស្រង់អ្វីដែល ហឿន ហ្នឹងបានលើកឡើងកាលនៅពេលនោះ។ ទាក់ទងនឹងសភាពការណ៍ខ្មាំងនៅក្នុងមូលដ្ឋានខ្ញុំ បន្ទាប់ពីបានទទួលសេចក្ដីណែនាំជាបន្តបន្ទាប់ពីអង្គការទាក់ទងទៅនឹងការប្រុងប្រយ័ត្នប្រឆាំងនឹងខ្មាំង និងការបោសសម្អាតពួកទាហានខ្មាំង ដែលមានបណ្ដាស័ក្តិ ក្នុងនោះយើងបានតាមដានពិនិត្យឃើញមានឈ្មោះដូចខាងក្រោមនេះ” បាទសូមបញ្ចប់ការដកស្រង់។ តើលោកស្រីមានចាំថា បានទទួលសេចក្ដីណែនាំជាបន្តបន្ទាប់ពីថ្នាក់លើមកទាក់ទងទៅនឹងខ្មាំង ហើយនិងការបោសសម្អាតទាហានខ្មាំងដែលមានបណ្ដាស័ក្តិដែរឬទេ?

**ឆ៖** ចាស។

**ស៖** តើលោកស្រីមានចាំថា អ្នកណាជាអ្នកចេញសេចក្ដីណែនាំឲ្យលោកស្រីដែរឬទេ? តើថ្នាក់ស្រុក ឬថ្នាក់តំបន់ ឬក៏ថ្នាក់ណាផ្សេងទៀត?

**ឆ៖** ចាស ខ្ញុំទទួលបានតែត្រឹមថ្នាក់ស្រុក។

**ស៖** តើពាក្យថា “ប្រយ័ត្នចំពោះខ្មាំង”នេះ ប្រុងប្រយ័ត្នចំពោះខ្មាំងនេះ មានន័យយ៉ាងដូចម្ដេចដែរ?

**ឆ៖** ចាស ពាក្យដែលថា “ប្រុងប្រយ័ត្នខ្មាំង” គឺខ្លាចខ្មាំងចូលមកវ៉ៃ ឬក៏ចូលមកធ្វើអីផ្សេងៗទៀតដែលនាំឲ្យប៉ះពាល់ដល់ប្រជាជន។

[១១:២៣:២៦]

**ស៖** តើថ្នាក់លើភ័យខ្លាចខ្មាំងបំពុល ឬក៏ធ្វើឲ្យសមាសភាពល្អខូចដែរឬទេ?

**ឆ៖** ចាស។

**ស៖** ទាក់ទងនឹងការបោសសម្អាតពួកទាហានខ្មាំងដែលមានបណ្ដាស័ក្តិនេះ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើសម័យនោះនៅពេលដែលគេនិយាយយ៉ាងដូច្នេះ មានន័យយ៉ាងដូចម្ដេចដែរ?

**ឆ៖** ចាស សុំសំណួរឲ្យច្បាស់បន្តិច ខ្ញុំមិនយល់។

**ស៖** បាទ ខ្ញុំនិយាយអំពីពាក្យដែលគេប្រើប្រាស់នៅក្នុងរបាយការណ៍នេះបាទ ដែលមាននិយាយអំពីការណែនាំជាបន្តបន្ទាប់ដែលអង្គការបញ្ជូនមកទាក់ទងទៅនឹងការបោសសម្អាតទាហានៗលន់នល់។

ពាក្យដែល "បោសសម្អាត"នេះ នៅសម័យនោះមានន័យថាយ៉ាងម៉េចដែរ មានន័យថា "ចាប់ខ្លួន ឬក៏ការកម្ទេច"?

**ឆ៖** ចាស ខ្ញុំអត់មានកម្ទេចទេ។ ខ្ញុំគ្មានសិទ្ធិទេ មានតែបញ្ជូន។ មានការរាយការណ៍ពីភូមិមក ហើយមកឃុំ ឃុំបញ្ជូនទៅស្រុក។

**ស៖** តើតាមសេចក្ដីសម្រេចរបស់ស្រុកហើយហ្នឹង លោកស្រីត្រូវចាប់អ្នកត្រូវបោសសម្អាត ហើយបញ្ជូនបុគ្គលទាំងអស់ហ្នឹង ទៅស្រុក ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំអត់មានបានចាប់ បានចងអីអ្នកណាទេ។

**ស៖** បាទ ខ្ញុំនឹងវិលត្រឡប់ពីចំណុចនេះ នៅពេលក្រោយ។ ខ្ញុំសូមអានរបាយការណ៍នេះបន្តទៀត លោកស្រីបាននិយាយថានៅក្នុងអត្ថបទនេះថា "យើងបានតាមដាន ហើយនិងកំណត់អត្តសញ្ញាណបុគ្គលទាំងអស់នេះ។ មនុស្សទី១ មានឈ្មោះ ឈិត ពិល ពាក់ស័ក្តិ១ ចេញពីភ្នំពេញមក ហើយបុគ្គលទី២ឈ្មោះ ខៀវ សុខា និយាយថា -- ហឿន សរសេរពី សុខា ដូចតទៅនេះ គឺថា "មុខរបរពួកគាត់នេះ ពេលដែលជម្លៀសចេញមកភ្លាមៗនោះ នៅពេលដែលខ្ញុំសួរចម្លើយវា វាឆ្លើយថា វាលក់អង្ករ លក់បាយ ក៏ប៉ុន្តែបន្ទាប់ពីការស៊ើបអង្កេតមើលទៅ ទៅពិនិត្យមើលទៅ ឃើញថាវាធ្វើការនៅក្រសួងអភិវឌ្ឍន៍សហគមន៍"។ សូមបញ្ចប់ការដកស្រង់។

[១១:២៦:៤៧]

នៅខែមេសា ឆ្នាំ១៩៧៧ គឺកាលបរិច្ឆេទនៃការរបាយការណ៍ហ្នឹង តើគេមានបានបញ្ជាឲ្យឃុំសួរទៅស្វែងរកប្រវត្តិរូបដើម្បីឲ្យដឹងថា មុខរបរគេពីមុនមកធ្វើអ្វីដែរនោះទេ? ហើយអីចឹងហើយបានមានសំណួរ -- ដោយសារអីចឹងហើយបានមានសំណួរនេះ គេចោទសួរឡើងនៅតាមឃុំនោះ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

ខឹម ហឿន កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស ខ្ញុំបាន--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប លោកស្រី ខឹម ហឿន!

**លោក វ៉ិចទ័រ កូប៉េ៖**

គ្រាន់តែជាការកត់ត្រាដើម្បីកំណត់ត្រាប៉ុណ្ណោះ គ្រាន់តែជាការកំណត់សម្គាល់ប៉ុណ្ណោះ។ គឺថា ព្រះរាជអាជ្ញាគាត់បានអាននៅក្នុងកថាខណ្ឌមួយនៃឯកសារនេះ ដែលនេះវាជាការសាកសួរ -- ជាការសួរចម្លើយ។ ដូច្នេះខ្ញុំមិនមែនជំទាស់ទេ ប៉ុន្តែគ្រាន់តែជាការកត់សម្គាល់ ហើយខ្ញុំសង្ឃឹមថានៅពេលដែលដល់វេនយើង គឺយើងទទួលបានការអនុញ្ញាតឲ្យប្រើប្រាស់ឯកសារសួរចម្លើយដូចគ្នានេះ។

[១១:២៨:០៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

លោកប្រធាន ខ្ញុំនិយាយតែពីរមាត់ទេ។ ឥឡូវនេះ យើងនិយាយពីសំណួរដែលសួរពីសម័យនោះទេ មិនមែនទាក់ទងនឹងការទារុណកម្មនោះទេ។ លោក កូប៉េ កំពុងតែធ្វើឲ្យយើងយល់ច្រឡំថា ចេញពីការធ្វើទារុណកម្មហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

**ស៖** លោកស្រីសាក្សី តើលោកស្រីអាចឆ្លើយនឹងសំណួរនេះបានទេ ថានៅខែមេសា ឆ្នាំ១៩៧៧ តើស្រុកមានបានសុំឲ្យឃុំសួរទៅខ្មាំងដែលមានសក្តានុពលដែរឬទេ ឧទាហរណ៍ដូចថា សួរឲ្យដឹងថា តើគេមានឋានន្តរសក្តិអ្វីដែរ មុខងារអ្វីដែរនៅក្នុងរបបចាស់នោះ?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស កន្លងមកមានសួរសាកហ្នឹង មាន ចាស។

**ស៖** បាទ ខ្ញុំសូមដកស្រង់ទាក់ទង ខៀវ សុខា ឈ្មោះនៅក្នុងរបាយការណ៍នេះដែរ។ ឈ្មោះទី២ មាននិយាយដូចតទៅនេះ "ឪពុករបស់វាធ្វើការនៅក្នុងអាជ្ញាធរខេត្តតាកែវ។ នៅពេលដែលយើងរំដោះដល់វត្តចំប៉ា អង្គការយើងហ្នឹងបានដកហូតពុកវាចេញពីតំណែង"។ សូមបញ្ចប់ការដកស្រង់។ អម្បាញ់មិញនេះលោកស្រីនិយាយថា លោកស្រីមិនបានដឹងរឿងអ្វីកើតឡើងនៅវត្តចំប៉ាលើកនោះទេ ក៏ប៉ុន្តែនៅក្នុងរបាយការណ៍នេះ លោកស្រីនិយាយថានៅពេលដែលយើងរំដោះបាន រំដោះដល់វត្តចំប៉ានោះ អង្គការយើងនោះបានដកឪវាចោល។ តើលោកស្រីចង់និយាយយ៉ាងម៉េចដែរ នៅត្រង់ចំណុចនេះ ចង់បានន័យថាយ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំអត់ច្បាស់ ខ្ញុំដូចអត់បាននិយាយរឿងដកឪដកអីទេ ហើយក៏មិនស្គាល់ឈ្មោះហ្នឹងទៀត។

[១១:៣០:១៩]

**ស៖** តើលោកស្រីដឹងដែរឬទេថា នៅវត្តចំប៉ាលើក កម្មាភិបាល លន់ នល់ ហើយនិងអ្នកមានបណ្ដាស័ក្តិនៅក្រោមរបប លន់ លន់ ត្រូវបានគេចាប់ខ្លួន? លោកស្រីមានដឹងទេ?

**ផ៖** ចាស ខ្ញុំអត់បានដឹងទេ។

**ស៖** បាទ នៅក្នុងផ្នែកបញ្ចប់នៃឯកសារនេះ ហឿន និយាយដូចតទៅនេះថា "បុគ្គលទាំងពីរហ្នឹងត្រូវបានបញ្ជូនទៅនគរបាល"។ នៅសម័យនោះនៅពេលដែលយើងនិយាយថា បញ្ជូនទៅនគរបាលនោះបាន -- ខ្ញុំសួរលោកស្រីថាតើនៅពេលដែលគេនិយាយថា "បញ្ជូនទៅនគរបាល" នេះសម័យនោះ មានន័យថាយ៉ាងម៉េច? ហើយនគរបាលហ្នឹង ចង់និយាយថាបញ្ជូនទៅកន្លែងណាដែរ?

**ផ៖** កាលសម័យនោះខ្ញុំអត់ដឹងនគរបាលនៅកន្លែងណាផង។ ក្រាំងតាចាន់ទើបនឹងកើតក្រោយ។

**ស៖** បាទ ឥឡូវខ្ញុំសូមបន្តនឹងឯកសារដដែល គឺឯកសារ E3/2048 គឺទំព័របន្តទៀត គឺឯកសារគឺ ERN 00079092 ដល់ 93 គឺឯកសារដដែលទេ, ជាអង់គ្លេស 00276565 ហើយជាភាសាបារាំងគឺ 00611662។ គឺជារបាយការណ៍ដែលផ្ញើដោយឈ្មោះ ជន ពីឃុំពពេល ហើយចុះថ្ងៃទី០៨ ឧសភា ឆ្នាំ១៩៧៧។ តើលោកស្រីមានឯកសារនេះនៅចំពោះមុខលោកស្រីដែរឬទេ?

[១១:៣៣:៤៩]

**ផ៖** ចាស មាន។

**ស៖** តើលោកស្រីអាចមើលនៅផ្នែកបញ្ចប់នៃឯកសារហ្នឹង ទំព័រហ្នឹង សួរថាមើលថាតើ ជន ពីឃុំពពេលហ្នឹង គាត់ជាអ្នកចុះហត្ថលេខាលើសារហ្នឹង? ឈ្មោះ ជន ហ្នឹងពិតជាប្ដីរបស់លោកស្រីមែនទេ?

**ផ៖** ចាស។ មើលមិនរួចខ្ញុំ អក្សរខ្សៀកពេក។

**ស៖** បាទ ខ្ញុំដឹងថាលោកស្រីមានបញ្ហាភ្នែក ក៏ប៉ុន្តែសូមលោកស្រីមើលអក្សរហ្នឹង ហើយនិងហត្ថលេខាលើឯកសារហ្នឹង។ អ៊ីចឹងតើអក្សរ ហើយនិងហត្ថលេខាហ្នឹងជារបស់ប្ដីលោកស្រី ឬក៏យ៉ាងណា? លោកស្រីសាក្សី តើលោកស្រីអាចឆ្លើយតបនឹងសំណួរនេះដែរឬទេ? តើ ជន ហត្ថលេខា ហើយនិងឈ្មោះ ជន នោះពិតជាប្ដីរបស់លោកស្រីមែនទេ?

**ផ៖** ចាស។

**ស៖** បាទ នៅក្នុងរបាយការណ៍នេះ ប្ដីរបស់លោកស្រីបាននិយាយដំបូងថា គាត់សូមផ្ញើជូន

អង្គការស្រុក ជនក្បត់បួននាក់។ ខ្ញុំមិនអានទាំងអស់ទេ ប៉ុន្តែក្នុងចំណោមបួននាក់ហ្នឹង គឺថាមានអតីតយោធាលន់នល់ ហើយមានមន្ត្រីរដ្ឋការជាន់ខ្ពស់ម្នាក់ ហើយនិងនិស្សិតច្បាប់ម្នាក់ ដែលគាត់បាននិយាយថា ពួកគេទាំងអស់នេះជាអ្នកប្រឆាំងយ៉ាងខ្លាំងក្លា និងបក្ស ហើយនិងនាំឲ្យក្មេងៗបះបោរ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា នៅសម័យនោះ ពួកដែលប្រឆាំងនឹងមានន័យថាយ៉ាងម៉េចដែរ? -- ពួកដែលទំនាស់បាទសូមទោស -- ពួកដែលទំនាស់នឹងប្រជាជន នឹងបក្សនេះ?

**ឆ៖** ទំនាស់មានច្រើនយ៉ាងដែរ។ ទំនាស់មួយគេបំផុសថា អ៊ីចេះអ៊ីចុះ ដែលធ្វើឲ្យប្រជាជនភ័យខ្លាច ខ្លះទៀតទំនាស់ វាមានច្រើនណាស់ តែខ្ញុំសូមបញ្ចាក់តែប៉ុណ្ណឹង។

[១១:៣៦:២០]

**ស៖** តើនៅសម័យនោះ គេមានស្វែងរកអតីតយោធាលន់នល់ ហើយនិងអតីតមន្ត្រីរដ្ឋការ ឬក៏មានស្រាវជ្រាវរកគ្រូបង្រៀន ហើយនិងនិស្សិតអីដែរឬទេនៅសម័យនោះដែលគេចាត់ទុកថា ពួកគេហ្នឹងជាអ្នកទំនាស់ដែលជ្រាលជ្រៅទៅនឹងបដិវត្តន៍ហ្នឹង?

**ឆ៖** ជំនាន់នោះដូចមិនមាន ក្នុងឃុំខ្ញុំដូចមិនមានអីច្រើន អ្នកមានបណ្ដាស័ក្តិអីមិនមាន មិនសូវមានទេ មានធ្វើបញ្ជី មានធ្វើអីមែន តែមិនមានច្រើនទេ។ ខ្ញុំមិនចាំបានដែរ ភ្លេច។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ សហព្រះរាជអាជ្ញារង។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀសនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អរគុណលោកស្រី ខឹម បឿន ព្រមទាំងមេធាវីប្រឹក្សាសាក្សី។ ឥឡូវនេះ ដល់ពេលសម្រាកហើយ ហើយយើងសម្រាបចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣២:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោកស្រី ខឹម បឿន! តើបានត្រៀមខ្លួនរួចហើយឬនៅដើម្បីឆ្លើយតបនឹងសំណួរបន្តទៀតនៅរសៀលនេះ?

សួស្តីលោកស្រី ខឹម បឿន!

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទ ជម្រាបភាគី និងសាធារណជនថា បញ្ហាប្រព័ន្ធសោតទស្សន៍នៅឯខេត្តបាត់ដំបងនោះ មានបញ្ហា។ ឥឡូវនេះ ដើម្បីកំពុងតែពិនិត្យភ្ជាប់ឡើងវិញ។

[១៣:៣៥:៤៧]

*(មានបញ្ហាបច្ចេកទេស)*

[១៣:៣៦:៥០]

**ប្រធានអង្គជំនុំ៖**

សួស្តីលោកស្រី ខឹម បឿន! តើលោកស្រីស្តាប់បានទេ?

**លោកស្រី ខឹម បឿន៖**

ចាស ស្តាប់បានដែរ ជម្រាបសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ យើងបន្តនីតិវិធីសវនាការរបស់យើងនៅរសៀលនេះ ណា៎ លោកស្រី។

**លោកស្រី ខឹម បឿន៖**

ចាស។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៣:៣៧:២៧]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរជាថ្មីម្តងទៀត លោកស្រីសាក្សី។ ខ្ញុំត្រឡប់មកនិយាយអំពីអ្វីដែលបាន កើតឡើងនៅវត្តចំប៉ាលើកម្តងទៀត។ មុននេះលោកស្រីនិយាយថា គេប្រមូលផ្តុំអ្នកជម្លៀសមកពីភ្នំពេញដាក់ម្តុំសិន ហើយយើងក៏មានឯកសារ E3/2048 ដែលបញ្ជាក់អំពីចំណុចនេះ ហើយក្នុងនោះមាននិយាយអំពីឈ្មោះ ហឿន ដែលនិយាយថា ឪពុករបស់ ខៀវ សុខា ត្រូវបានដកចេញដោយអង្គការនៅវត្តចំប៉ា។ ខ្ញុំចង់អាននូវអ្វីដែលកម្មាភិបាលស្រុកត្រាំកក់គាត់បាននិយាយ។ គឺឯកសារ 2-TCW-822។ កំណត់ហេតុស្តាប់ចម្លើយនោះ គឺ E319.1.32។ កម្មាភិបាលស្រុកនោះ គាត់និយាយនៅចម្លើយ១០៣ ដូចតទៅខ្ញុំសូមដកស្រង់៖ "ខ្មែរក្រហមប្រកាសជ័យជម្នះ។ យើងវាយកភ្នំពេញបានហើយ បន្ទាប់មកគេបណ្តេញប្រជាជនទីក្រុងភ្នំពេញ ហើយជម្លៀសទៅវត្តចំប៉ាលើក ដែលស្ថិតនៅខាងលិច ប្រហែល៣គីឡូម៉ែត្រពីអង្គតាសោម ស្រុកត្រាំកក់។ គេបានឱ្យអ្នកដែលមានបណ្តាស័ក្តិនៅសម័យលន់ នល់ ចុះឈ្មោះក្នុងបញ្ជីមួយក្នុងរយៈពេល៧ថ្ងៃ។ នៅពេលដែលគេធ្វើបញ្ជីហើយ គេនាំយកទៅបាត់ ដោយមិនមានបន្សល់ស្លាកស្នាមអ្វីទេ។ អ៊ីចឹង គេបានសម្លាប់ទាហានលន់ នល់ និងមន្ត្រីរដ្ឋការអស់ជាច្រើននាក់។ គឺមិនមានពួកទាហានឋានន្តរធំៗអីទេ គឺនៅសល់តែប្រជាជនធម្មតាតែប៉ុណ្ណោះ នៅក្នុងស្រុកកំណើត"។ សូមបញ្ចប់ការដកស្រង់។ តើចម្លើយរបស់សាក្សីនៅមន្ទីរស្រុកត្រាំកក់នេះ ធ្វើឱ្យលោកស្រីចងចាំឡើងវិញអំពីអ្វីដែលបានកើតឡើងនៅវត្តចំប៉ា ដែលថានាយទាហាននៃរបបលន់ នល់ នោះ ត្រូវបានគេកំណត់អត្តសញ្ញាណបានហើយ នាំខ្លួនយកទៅបាត់?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ខ្ញុំអត់បាននាំយកពីវត្តចំប៉ាទេ ព្រោះមិនមែនក្នុងឃុំជាងទងផង។

[១៣:៤០:៣៨]

**ស៖** សាក្សីពីររូបគឺលោក កែវ ច័ន្ទតារ៉ា ហើយនិង តាជឹម ហៅ ពេជ្រ ជឹម បានឆ្លើយថា តាម៉ុក បានទៅវត្តចំប៉ា។ តើលោកស្រីធ្លាប់ស្ដាប់ឮត្រង់ចំណុចហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំអត់បានដាក់ចាំដែរ។

**ស៖** ឥឡូវនេះខ្ញុំមកនិយាយអំពីឯកសារ E3/2048 គឺខ្ញុំនិយាយអំពីទំព័រមួយផ្សេងទៀត។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារដែលខ្ញុំនឹងផ្ដល់លេខ ERN។ ខ្មែរគឺ ERN 00079090, ជាភាសាអង់គ្លេស 00276563 រហូតទៅដល់ 64, ជាភាសាបារាំង 00611660។ ខ្ញុំមិនអានទាំងអស់ទេ គឺខ្ញុំអានតែមួយផ្នែកទេ។ លោកប្រធាន សូមការអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់លោកប្រធាន។

[១៣:៤២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នេះគឺជារបាយការណ៍មួយដែលផ្ញើដោយឈ្មោះ ជន ដែលជាប្ដីរបស់លោកស្រី ផ្ញើពីឃុំពពេលនៅដើមខែឧសភា ឆ្នាំ១៩៧៧។ គាត់ផ្ញើជូនអង្គការស្រុក គឺយើងនៅស្ថិតនៅក្នុងរយៈកាលដដែលដូចអម្បាញ់មិញអ៊ីចឹង គឺចុងខែមេសា ដើមខែឧសភា ឆ្នាំ៧៧។ ខ្ញុំនឹងដកស្រង់របាយការណ៍របស់ ជន “១) មានគ្រួសារកម្ពុជាក្រោម៦៤គ្រួសារ ហើយនិងប្រជាជនយួនដែលដូរយក ដូច្នេះមានទាំងអស់៦០០នាក់ជាង។ ទី២ គ្រួសារទាហានដែលត្រូវអង្គការកម្ទេច និងស្លាប់បាត់១០៦គ្រួសារ។ ៣) គឺនៅសល់៦៣១គ្រួសារ អ៊ីចឹងប្រហែលជា៨០០នាក់ជាង អ៊ីចឹងសរុបទាំងអស់ទៅគឺ១០០០នាក់ជាង។ ខ្ញុំសូមបញ្ជាក់ថា នៅមានគ្រួសារជាច្រើនទៀតដែលយើងមិនទាន់បានពិនិត្យ ដើម្បីដឹងថាតើអ្នកទាំងអស់នោះមានជាប់ពាក់ព័ន្ធជាមួយនឹងអតីតទាហានសម័យយើងមុន ឬក៏អត់”។ សូមបញ្ចប់ការដកស្រង់។ លោកស្រី តើប្ដីរបស់លោកស្រី ក៏ដូចជាលោកស្រីហ្នឹងមានបានទទួលការណែនាំឲ្យបែងចែកប្រជាជនពីរប្រភេទទេ? ទី១ គឺខ្មែរក្រហម -- ខ្មែរក្រោម (សូមទោស) ដែលដូចជាមួយនឹងយួន ហើយនិងមួយទៀត

គឺក្រុមគ្រួសារទាហាន លន់ នល់។ លោកស្រីសាក្សី តើលោកស្រីអាចឆ្លើយនឹងសំណួររបស់ខ្ញុំបានទេ? តើមានការណែនាំពីថ្នាក់ស្រុកឲ្យធ្វើបញ្ជីស្ថិតិខ្មែរក្រោម និងគ្រួសារទាហានលន់នល់ ដូចដែលខ្ញុំបានអាននូវរបាយការណ៍ដែលធ្វើជូនដោយ ជន នេះដែរឬទេ?

**ឆ៖** ចាសនៅកន្លែងខ្ញុំអត់មានខ្មែរក្រោមផង ដូចជម្រាបហើយមានតែបីគ្រួសារដែលនៅរហូត។

**ស៖** តើមានខ្មែរក្រហមច្រើនទេ ដែលរស់នៅក្នុងឃុំពេលនោះ ដែលជាឃុំដែលមានប្តីលោកស្រីជាមេឃុំ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ។

[១៣:៤៦:១៤]

**ស៖** នៅខែមេសា ឆ្នាំ១៩៧៧ តើមានការចាប់ខ្លួនអតីតទាហានលន់នល់ច្រើនទេនៅក្នុងឃុំ និងស្រុកត្រាំកក់នោះ ដោយផ្អែកទៅតាមឯកសារដែលខ្ញុំបានបង្ហាញជូន? លោកស្រីសាក្សី តើលោកស្រីអាចជម្រាបបានទេថា នៅចន្លោះខែមេសា និងឧសភា ឆ្នាំ១៩៧៧ នោះមានការចាប់ខ្លួនអតីតទាហានលន់ នល់ ជាច្រើននៅស្រុកត្រាំកក់?

**ឆ៖** ចាស ខ្ញុំអត់សូវបានដឹងដែរ បើនៅក្នុងឃុំខ្ញុំមិនមានទេ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំបានអានរបាយការណ៍ដែលលោកស្រីបានធ្វើ គឺពាក់ព័ន្ធទៅនឹងទាហានលន់នល់ នៅសម័យកាលដដែលដូចគ្នាហ្នឹង អ៊ីចឹងតើ ខ្ញុំចង់សួរថាតើវាគ្រាន់តែជាភាពគាប់ជួនគ្នា ឬក៏មានបញ្ជាពីថ្នាក់ស្រុកតែម្តងក្នុងការបោសសម្អាតទាហានលន់នល់?

**ឆ៖** សូមបញ្ជាក់ម្តងទៀត ស្តាប់អត់បាន។

**ស៖** អម្បាញ់មិញនេះ ខ្ញុំបានអានរបាយការណ៍មួយដែលលោកស្រីធ្វើជូនថ្នាក់ស្រុកពាក់ព័ន្ធទៅនឹងទាហានលន់នល់ នៅខែមេសា ឆ្នាំ១៩៧៧ ហើយអម្បាញ់មិញនេះ លោកស្រីក៏បានបញ្ជាក់ផងដែរថាមានការបញ្ជាថ្នាក់ស្រុកឲ្យសម្អាត បោសសម្អាតទាហានលន់នល់។ អ៊ីចឹងលោកស្រីថាមិនមានករណីហ្នឹងកើតឡើងទេ នៅឃុំរបស់លោកស្រី។ អ៊ីចឹងហើយបានជាខ្ញុំចង់ដឹងថា តើពិតជាមានបញ្ជាថ្នាក់លើពីថ្នាក់ស្រុកមកឲ្យបោសសម្អាតអ៊ីចឹងទេ?

**ឆ៖** ឃុំខ្ញុំអត់មានទេ។

**ស៖** យើងនឹងពិនិត្យមើលករណីប្តីរបស់លោកស្រីថែមទៀត។ យើងមានឯកសារជាច្រើន ហើយខ្ញុំជ្រើសរើសយកឯកសារ E3/2443 -- គឺ E3/2433 ដែលធ្វើដោយឈ្មោះ ជន នៅឃុំពេល

ដែលចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៧។ ERN ជាភាសាខ្មែរ 00270979, អង់គ្លេស 00322121, ជាភាសាបារាំង 00833780 ទៅដល់ 81។ នេះជារបាយការណ៍ដែលផ្ញើដោយឈ្មោះ ជន ដែលបានកំណត់អត្តសញ្ញាណទាហានមួយដែលជាប់ខ្សែអាមេរិក ហើយបញ្ជាក់ថា ប្រពន្ធ និងកូនត្រូវនាំទៅឱ្យអង្គការនៅថ្ងៃបន្ទាប់។ ខ្ញុំមានសំណួរមួយពាក់ព័ន្ធទៅនឹងបញ្ហានេះ តើវាជាទម្លាប់មែនទេ នៅពេលដែលគេចាប់បានទាហាន លន់នល់ គឺគេចាប់ទាំងសមាជិកគ្រួសាររបស់ទាហាននោះផងដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ។

ខឹម បឿន កុំអាល់ទាន់ឆ្លើយតប។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងការសួរសំណួរបែបនេះ។ សាក្សីគាត់អាចផ្តល់សក្ខីកម្មតែទៅលើអ្វីដែលគាត់បានស្តាប់ឮ និងបានដឹង អាចនៅក្នុងឃុំ ឬក៏នៅក្នុងស្រុករបស់គាត់តែប៉ុណ្ណោះ។ គាត់មិនអាចផ្តល់សក្ខីកម្មអំពីអ្វីដែលកើតឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យបាននោះឡើយ។ ខ្ញុំគិតថាវាអាចជួយដល់សាក្សីផង ប្រសិនបើព្រះរាជអាជ្ញាគាត់សួរនូវសំណួរសាមញ្ញៗ។ ប៉ុន្តែអ្វីដែលខ្ញុំចង់ជំទាស់គឺពាក់ព័ន្ធទៅលើសំណួរនេះ ដែលស្នើឱ្យសាក្សីធ្វើការទាយស្មាន។ សូមអរគុណ។

[១៣:៥២:០០]

**លោក វាំងសង់ វ៉ាយដ៏ ដេស្នាងលេ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។

**សួរដោយលោក វាំងសង់ វ៉ាយដ៏ ដេស្នាងលេ៖**

**ស៖** លោកស្រីសាក្សី ខ្ញុំមិនសុំឱ្យលោកស្រីស្មានទេ។ លោកស្រីបានចូលរួមក្នុងកិច្ចប្រជុំជាច្រើននៅថ្នាក់ស្រុក ហើយនៅពេលនោះ គេបានចេញសេចក្តីណែនាំពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ។ ខ្ញុំនឹងរៀបចំសំណួរខ្ញុំឡើងវិញ។ តើវាជាទម្លាប់មែនទេនៅថ្នាក់ស្រុក នៅពេលដែលគេប្រជុំ គេប្រាប់ថា ត្រូវតែចាប់ទាំងគ្រួសាររបស់ទាហានដែលជាខ្មាំងនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរ! ហើយស្តាប់សំណួរបានទេ បើស្តាប់មិនបានសុំឱ្យសួរសាជាថ្មីម្តងទៀត។

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស សុំម្តងទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាងលេ៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំអានសម្រង់ -- ខ្ញុំសូមអានសម្រង់កំណត់ហេតុ គឺចម្លើយ២៥៤ លោកស្រីបានបញ្ជាក់ថា គេធ្វើប្រវត្តិរូបដើម្បីស្វែងរកគ្រូបង្រៀន មន្ត្រីរដ្ឋការ ឬអតីតទាហានរបបលន់ នល់ គឺក្រោយខែមេសា ១៩៧៥។ ឥឡូវនេះខ្ញុំនិយាយអំពីឆ្នាំ១៩៧៧។ អ៊ីចឹងខ្ញុំសួរលោកស្រីថាតើនៅឆ្នាំ ១៩៧៧ ថ្នាក់ស្រុកមានបានចេញបញ្ជា ឬក៏មេស្រុកមានបានចេញបញ្ជាឲ្យកំណត់អត្តសញ្ញាណនិងចាប់ខ្លួនមន្ត្រីរដ្ឋការ ឬក៏ទាហាន លន់ នល់ ហើយនៅពេលដែលគេចាប់ទាហានណាម្នាក់នោះ តើគេចាប់ទាំងគ្រួសាររបស់ទាហានទាំងនោះមកដែរឬទេ?

**ឆ៖** ចាស ខ្ញុំសូមជម្រាបអំពីសំណួរនេះ។ ខ្ញុំបានទទួលការណែនាំខាងលើមែន តែការចាប់បញ្ជូនអីគឺខ្ញុំអត់មានបានចាប់បញ្ជូនទេ។

[១៣:៥៥:០០]

**ស៖** សូមអរគុណ។ តើលោកស្រីមានដឹងថា ខ្មែរក្រោមមានមកដល់ស្រុកត្រាំកក់ទេ បន្ទាប់ពីមានការដោះដូរជាមួយនឹងប្រជាជនយួននោះ? លោកស្រីធ្លាប់បានឃើញនៅក្នុងឃុំរបស់លោកស្រី ឬក៏ឃុំជិតៗនោះ ឃើញគេដូរខ្មែរក្រោមនោះ ជាមួយនឹងជនជាតិវៀតណាមទេ?

**ឆ៖** ខ្ញុំដឹងតែក្របខ័ណ្ឌឃុំខ្ញុំ អត់មានដូរទេ។

**ស៖** នៅក្នុងចម្លើយ១២៦ នៃកំណត់ហេតុស្តាប់ចម្លើយលោកស្រី លោកស្រីបានអះអាងថា មានគ្រួសារខ្មែរក្រោមពីរបីគ្រួសារ នៅក្នុងឃុំរបស់លោកស្រីដែលរស់នៅស្រុកគិរីវង់ ហើយជាអ្នកមកពីភ្នំពេញ ហើយលោកស្រីក៏ឮផងដែរ ថាមានខ្មែរក្រោមដែលរស់នៅក្នុងភូមិផ្សេងទៀត”។ តើនៅថ្នាក់ស្រុក ថ្នាក់តំបន់ លោកស្រីធ្លាប់ឮគេរៀបចំអំពីការមកដល់របស់ខ្មែរក្រោមដែលមកពីកម្ពុជាក្រោម ហើយអ្នកទាំងនុ៎ង ត្រូវបានគេដូរជាមួយនឹងជនជាតិវៀតណាម លោកស្រីមានធ្លាប់ឮអំពីបញ្ហាហ្នឹងទេ?

[១៣:៥៧:០០]

**ឆ៖** ចាស ធ្លាប់ឮដែរ តែអត់បានឃើញផ្ទាល់ទេ។

**ស៖** នៅចម្លើយ២៥២ និង២៥៣ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី លោកស្រីអះអាងថា ពាក់ព័ន្ធវៀតណាម និងខ្មែរក្រោមនោះ គេមិននិយាយនៅក្នុងកិច្ចប្រជុំធម្មតានៅថ្នាក់ស្រុកទេ

ក៏ប៉ុន្តែមានប្រជុំសម្ងាត់ដែលធ្វើឡើងនៅកន្លែងដែលមានវៀតណាម និងមានខ្មែរក្រោម។ តើលោកស្រីដឹងយ៉ាងម៉េចបានថាមានការប្រជុំអំពីវត្តមាន និងជោគវាសនារបស់ខ្មែរក្រោម និងជនជាតិវៀតណាមនៅក្នុងឃុំមួយចំនួននៅស្រុកត្រាំកក់នោះ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ តែខ្ញុំឆ្លើយច្រឡំ វង្វេង។

**ស៖** តើមេឃុំផ្សេងទៀត ឬក៏នៅពេលប្រជុំថ្នាក់ស្រុក ឬថ្នាក់តំបន់នោះ លោកស្រីមានធ្លាប់ឮថា មានការចេញបញ្ជាឲ្យធ្វើបញ្ជីគ្រួសារជនជាតិវៀតណាម និងគ្រួសារខ្មែរក្រោមដែរឬទេ?

**ឆ៖** ចាស ធ្លាប់ឮៗ តែមិនបានពិតប្រាកដទេ ព្រោះជាចចាមអារ៉ាមទេ។

**ស៖** ខ្ញុំនឹងមិនបង្ហាញអំពីបញ្ជីគ្រួសារខ្មែរក្រោមទាំងអស់ដែលមាននៅក្នុងឯកសារទេ ក៏ប៉ុន្តែខ្ញុំជ្រើសរើសយកឯកសារបី ហើយខ្ញុំនឹងសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញជាបន្តបន្ទាប់។ ដំបូង គឺឯកសារ E3/2438។ នេះគឺជាបញ្ជីគ្រួសារខ្មែរក្រោមនៅក្នុងឃុំគុស ធ្វើដោយឈ្មោះ យី នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧។

[១៣:៥៩:៣៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញនូវទំព័រទី១នៃបញ្ជីនេះ។ លោកស្រីសាក្សី លោកស្រីក៏សូមពិនិត្យមើលបញ្ជីដែលយើងប្រគល់ជូនទៅលោកស្រីនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយមេធាវីប្រឹក្សាសាក្សីសូមជួយសម្របសម្រួល ដើម្បីឲ្យសាក្សីហ្នឹងងាយឆាប់រកឃើញនៅឯកសារ និងទំព័រដែលសហព្រះរាជអាជ្ញាមានបំណងស្នើសុំដាក់បង្ហាញហើយនិងសួរទៅសាក្សីនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំនឹងមិនដល់ផ្តល់ ERN ទៅគ្រប់ឯកសារទេ ពីព្រោះឯកសារហ្នឹង គឺវាបញ្ជីវែងណាស់ដែលបង្ហាញអំពីគ្រួសារខ្មែរក្រោម។ ឯកសារ E3/2438 គឺនិយាយពាក់ព័ន្ធនឹងខ្មែរក្រោមដែលមកពីភ្នំពេញ ដែលជាទាហាន លន់ នល់។ ឯកសារផ្សេងទៀតគឺ E3/2281 គឺជាបញ្ជី៧៣គ្រួសារ គ្រួសារខ្មែរក្រោមដែលមកពីឃុំត្រពាំងជើង ដែលធ្វើនៅរយៈកាលដដែល គឺនៅថ្ងៃទី០៤ ឧសភា ឆ្នាំ១៩៧៧ដោយអាជ្ញាធរសហករណ៍។ ជាចុងក្រោយគឺបញ្ជីទី៣ គឺ E3/2262 ដែលជាបញ្ជីដោយផ្នែក មាន

៦៤គ្រួសារខ្មែរក្រោមដែលធ្វើនៅឃុំពពេល ដែលជាឃុំរបស់ប្តីលោកស្រី គឺឈ្មោះ ជន។ បញ្ជីនេះគឺបានបង្ហាញអំពីឈ្មោះប្តី ឈ្មោះប្រពន្ធ ចំនួនកូន ឃុំកំណើត មុខរបរ ឬក៏ឋានន្តរសក្តិនៅក្នុងរបប លន់ នល់ កន្លែងរស់នៅ គឺនៅពពេល ហើយនិងទីកន្លែងមកកន្លែងដើម គឺកម្ពុជាក្រោម ឬក៏វៀតណាម។ លោកស្រីសាក្សី យើងមានបញ្ជីមួយចំនួនដែលធ្វើឡើងដោយឃុំនៃស្រុកត្រាំកក់ ដែលវាមានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយនិងចុះកាលបរិច្ឆេទដូចគ្នា។ អ៊ីចឹងវាធ្វើឲ្យលោកស្រីចងចាំទេ ថាពិតជាមានការណែនាំមកពីស្រុក១០៥ ឲ្យធ្វើបញ្ជីដូចដែលខ្ញុំបានរៀបរាប់នេះ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស សូមជម្រាបលោកប្រធានថា ខ្ញុំបានធ្វើតែ ដឹងតែត្រឹមក្របខ័ណ្ឌឃុំរបស់ខ្ញុំ ក្រៅពីនោះដែលជាឃុំផ្សេងៗ ខ្ញុំអត់បានដឹងទេ ចាស។

[១៤:០៣:៣៣]

**ស៖** លោកស្រី អម្បាញ់មិញនេះលោកស្រីថានិយាយថា មានការប្រជុំបីដងក្នុងមួយខែនៅថ្នាក់ស្រុក។ ខ្ញុំមិនទាន់និយាយអំពីការប្រជុំនៅថ្នាក់តំបន់ទេ ក៏ប៉ុន្តែលោកស្រីបាននិយាយថា លោកស្រីបានចូលរួមនៅកិច្ចប្រជុំថ្នាក់តំបន់។ អ៊ីចឹងចម្លើយរបស់លោកស្រី គឺថាបញ្ហាខ្មែរក្រោមហ្នឹងគឺមិនត្រូវបានគេនិយាយនៅក្នុងពេលប្រជុំទេ មែនទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងដែរ។

**ស៖** តើលោកស្រីស្គាល់មនុស្សម្នាក់ឈ្មោះ សាន់ ឡុន ហៅ ឡាន់ ហៅ មួយ ដែលរស់នៅក្នុងឃុំជាងទង ដែលជាប្អូនថ្លៃរបស់ តាម៉ុក? លោកស្រីស្គាល់ទេ?

**ឆ៖** ចាស អត់ស្គាល់។

**ស៖** ខ្ញុំនឹងអានទូវអ្វីដែលបុគ្គលរូបនេះបានឆ្លើយនៅក្នុងឯកសារ E319/13.3.60។ គេបានឲ្យគាត់តទល់ទៅនឹងសក្ខីកម្មមួយ ហើយពេលនុំង គាត់បានឆ្លើយតប។ គាត់ឈ្មោះ សាន់ ឡុន គាត់បានឆ្លើយថាគាត់បានស្តាប់បង្គាប់ស្រុកត្រាំកក់ ហើយបញ្ជូនមនុស្ស គឺពួកវៀតណាម ពីឃុំមួយចំនួនទៅមន្ទីរស្រុក ខ្ញុំនឹងដកស្រង់នូវចម្លើយរបស់គាត់។ ចម្លើយ៤៥៤ ជាភាសាអង់គ្លេស៖ "ខ្ញុំមិនដឹងទេ កម្មាភិបាលជាន់ខ្ពស់បានប្រើប្រាស់ខ្ញុំ ដូច្នេះខ្ញុំគ្រាន់តែធ្វើប៉ុណ្ណោះ។ ពួកគេប្រើប្រាស់ខ្ញុំ ខ្ញុំគ្រាន់តែគោរពតាមពួកគេប៉ុណ្ណោះ។ ចម្លើយ -- សំណួរ៤៧៥៖ "តើលោកនាំមនុស្សទាំងអស់នោះមកពីណា? ចម្លើយ៤៧៥៖ ខ្ញុំប្រមូលពួកគេមកពីភូមិ។ សំណួរ៤៧៦៖ នៅពេលដែលលោកទៅឃុំ តើគេរៀបចំមនុស្សហ្នឹងទុកឲ្យ

ពួកលោក ឬមួយយ៉ាងម៉េច? ចម្លើយ៖ បាទ ពួកគេរង់ចាំនៅមន្ទីរឃុំ។ សំណួរ៤៧៧៖ តើអ្នកណាជាអ្នកប្រគល់មនុស្សទាំងអស់នោះឲ្យលោកដឹកជញ្ជូន? ចម្លើយ៖ គឺមេឃុំបានប្រគល់ពួកគេមកឲ្យ ហើយភី ទៅទទួលពួកគេ។ សំណួរ៤៧៨៖ តើលោកដឹកមនុស្សទាំងអស់នេះមកពីឃុំណា? តើមេឃុំហ្នឹងឈ្មោះអ្វី? ចម្លើយ៤៧៨៖ ឃុំទាំងអស់នោះរួមមាន ឃុំពពេល, លាយបូរ, ជាងទង ហើយនិង គុស"។ សូមបញ្ចប់ការដកស្រង់។

[១៤:០៧:២០]

ហើយបន្ទាប់មកទៀត សាន់ ឡូន ប្រាប់ឈ្មោះលោកថា លោកជាមេឃុំជាងទង។ ហើយបន្តទៀតនោះ ចម្លើយ៤៨៨ គាត់និយាយថា គាត់បានដឹងថាពួកទាំងអស់នោះត្រូវបានគេនាំយកទៅអប់រំ ឬក៏បញ្ជូនទៅវៀតណាមវិញ ហើយគាត់ក៏មិនដឹងថាមានរឿងអីកើតឡើងទៀតដែរ។ បាទ យើងមានមនុស្សម្នាក់ដែលបានបញ្ជូនវៀតណាមទៅពីឃុំជាងទង ពីឃុំពពេល ហើយនិងពីឃុំផ្សេងទៅមន្ទីរស្រុកត្រាំកក់។ តើលោកស្រីចាំថា តើមានរឿងហ្នឹងកើតឡើងមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនអាចតាមទាន់អ្វីដែលព្រះរាជអាជ្ញាកំពុងតែធ្វើនោះទេ ប៉ុន្តែលំដាប់លំដោយ គឺថាគេបង្ហាញឯកសារបីទៅឲ្យសាក្សី គឺឯកសារអំពីខ្មែរក្រោម ហើយគេឲ្យគាត់អានទៅលើផ្នែកមួយចំនួនរបស់ឈ្មោះ សាន់ លន ហើយបន្ទាប់មក និយាយអំពីគ្រួសារវៀតណាម ដែលត្រូវបានគេបញ្ជូនទៅវៀតណាម។ ដូច្នេះ ខ្ញុំមិនប្រាកដថានេះជាលំដាប់លំដោយ ឬក៏សាក្សីគាត់យល់អំពីអ្វីដែលគេនិយាយអំពីខ្មែរក្រោម ឬក៏និយាយពីវៀតណាម។ ខ្ញុំតាមដូចជាមិនទាន់ច្បាស់លាស់ទេ ប៉ុន្តែខ្ញុំគិតថានេះជាអ្វីដែលព្រះរាជអាជ្ញាគាត់កំពុងធ្វើ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្លាងឈល៖**

**ស៖** បាទ ពិតប្រាកដហើយលោកស្រីសាក្សី ខ្ញុំនិយាយពីគ្រួសារវៀតណាម ហើយខ្ញុំអំមិញខ្ញុំបាននិយាយអំពីរវាងការដោះដូរគ្នា រវាងវៀតណាម ហើយនិងខ្មែរក្រោម។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើលោកស្រីបានឮរឿងហ្នឹងទេ ឬគ្រាន់តែជាពាក្យចចាមអារ៉ាម ពីព្រោះនៅទីនោះ យើងមានសាក្សីនៅ

ត្រាំកក់ហ្នឹងនិយាយថា ខ្លួនហ្នឹងធ្លាប់បានដឹកវៀតណាមពីឃុំមួយចំនួន ទៅមន្ទីរស្រុកត្រាំកក់។ អ៊ីចឹង តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកស្រីនៅចាំព្រឹត្តិការណ៍ហ្នឹងដែរឬទេ គឺថា វៀតណាមទាំងអស់ហ្នឹងត្រូវបានដឹកពីភូមិ មកឃុំនោះ ទៅមន្ទីរស្រុកត្រាំកក់ លោកស្រីចាំរឿងរ៉ាវហ្នឹង ដែរឬទេ?

[១៤:១០:១៦]

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយ។ ទី១ គឺខ្ញុំសូមឆ្លើយអំពីឈ្មោះដែលអ្នកថាដឹកនាំនេះ គឺខ្ញុំអត់ដែល ស្គាល់ទេ អត់ដែលមានឈ្មោះហ្នឹងទេ។ សាន់ អីមិញ មិនមានទេ។ ទី២ ការដោះដូរនេះ ខ្ញុំក៏មិនបានចាំ ដែរ ខ្ញុំវាស្រពេចស្រពិលក្នុងពេលនោះ ខ្ញុំក៏សុខភាពអត់ល្អ។ ខ្ញុំអត់ចាំទេ។ ខ្ញុំមិនដែលស្គាល់។

**ស៖** មិនមែនឈ្មោះ សាន់ ទេ ខ្ញុំឲ្យឈ្មោះគាត់មិញនោះ គឺថា កាលនោះ គេស្គាល់ឈ្មោះគាត់ ថា ឈ្មោះ ឡូន ទេសម័យនោះៗ អ៊ីចឹង ឡូ និង ន តើលោកស្រីស្គាល់ឈ្មោះ ឡូន ហ្នឹងទេ? ឡូ និង ន?

**ឆ៖** ឡូន?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា ឈ្មោះដែលតំណាងសហព្រះរាជអាជ្ញាលើក អម្បាញ់មិញនេះ គឺជាឈ្មោះ ដែលត្រូវការពារដោយសំណុំរឿងផ្សេង ដូច្នេះសូមសហព្រះរាជ្ញាមិនគួរ លើកពីឈ្មោះនេះចំទេបាទ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

ហើយបន្ថែមពីលើនេះទៀត លោកប្រធាន ឈ្មោះរបស់គាត់ គឺឈ្មោះ សាន់ យើងនិយាយមួយ សាទៀតហើយ ប៉ុន្តែ--

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានខ្ញុំបន្តទៅទៀត ព្រោះថា យើងមានពេលវេលាតិចណាស់។

**សួរដោយ លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រីសាក្សី លោកស្រីបាននិយាយថា លោកស្រីមិនត្រូវបានគេតាំងតាំងឲ្យក្លាយជា

អនុស្រុកនោះ តើចាប់ពីខែ១០ ឆ្នាំ១៩៧៨ គឺប្រហែលជាពីរបីខែ មុនពេលវៀតណាមចូលតែប៉ុណ្ណោះ។ អ៊ីចឹងខ្ញុំសួរលោកថា តើអ្នកណាជាអនុប្រធានរបស់ តាសាន ដែលជាប្រធាន ជាចៅហ្វាយស្រុកនោះ ចន្លោះឆ្នាំ ពីដើម ៧៨ ទៅដល់ខែតុលា ឆ្នាំ៧៨ នេះ?

[១៤:១៣:០៩]

**ឆ៖** កាលនោះ សាន គឺមានតែម្នាក់ឯងទេ។ ខ្ញុំសូមជម្រាបដល់លោកប្រធានដែលឈ្មោះ រ៉ន ជាគណៈតំបន់ហ្នឹងគឺគ្រប់គ្រងក្នុងស្រុកត្រាំកក់ហ្នឹង គេចុះជាប់ ហៅថាចុះជាប់នឹងស្រុកត្រាំកក់ ហើយ មានឈ្មោះ សាន ហ្នឹង។ ហើយ ៧៨ ដែលខែ១០ ខ្ញុំបានមកនេះ គឺក្នុងពេលដែលខ្ញុំចុះទៅធ្វើស្រែប្រាំង ខ្ញុំទៅទទួលខាងកងនារីស្រែប្រាំង។ ឯពីមុនហ្នឹងអត់មានអ្នកណាទៀតទេ ព្រោះគេដោះដូរអស់ហើយ ខ្ញុំក៏អត់បានចាំដែរ។

**ស៖** ខ្ញុំ -- អម្បាញ់មិញ ខ្ញុំឮលោកស្រីនិយាយពី ឡូន ឬក៏ រ៉ន នៅស្រុកនោះ អ៊ីចឹងតើលោកស្រី អាចនិយាយម្តងទៀតមើល ឈ្មោះអម្បាញ់មិញនេះ នៅតំបន់ (សុំទោស) ឈ្មោះ រ៉ន ឬក៏ឈ្មោះ ឡូន អម្បាញ់មិញ?

**ឆ៖** ចាស ឈ្មោះ រ៉ន –រ ៉- ន។

**ស៖** បាទ ខ្ញុំសូមអរគុណ ព្រោះថាជាភាសាបារាំងមិញ មិនសូវច្បាស់បាទ។ នៅពេលដែល លោកស្រីក្លាយជាអនុប្រធានស្រុកហ្នឹងបន្ថែមពីលើតំណែងជាមេឃុំនោះ តើជាទំនួលខុសត្រូវធ្ងន់ដែល តម្រូវឲ្យលោកស្រីធ្វើការច្រើនលើសមុនឬក៏យ៉ាងណា?

**ឆ៖** ចាស ខ្ញុំអត់មានធ្វើការបានលើសមុនទេ ព្រោះអ៊ីខ្ញុំបានទទួលខាងធ្វើសេដ្ឋកិច្ចដឹកនាំធ្វើស្រែ ប្រាំង ដឹកនាំដាំដំណាំផ្សេងៗ តែមួយផ្នែក។

[១៤:១៥:០០]

**ស៖** តើនៅថ្នាក់ស្រុកហ្នឹង ដែលនៅក្រោម តាសានហ្នឹង អ្នកណាជាអ្នកទទួលខុសត្រូវខាង សន្តិសុខពាក់ព័ន្ធនឹងខ្មាំងក្នុងជួរ និងក្រៅជួរ។ ខ្ញុំចង់សួរលោកស្រីថា តើអ្នកណាជាអ្នកកាន់ខាងហ្នឹង?

**ឆ៖** ខាងហ្នឹង ខ្ញុំភ្លេចហើយ មានតែ -- ចាំបានតែ ភី, ចន ម្នាក់ទៀតឈ្មោះ ម៉ូវ។ ចាំបាន តែប៉ុណ្ណឹងទេ ខ្ញុំភ្លេចអស់។

**ស៖** បាទ ឥឡូវ ខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វីដែលលោកស្រីបានលើកឡើងនៅក្នុងកំណត់ ហេតុស្តាប់ចម្លើយរបស់លោកស្រី នៅចម្លើយ២១២។ នៅឯកសារដដែល គឺឯកសារ E319/12.3.2

ក្នុងចម្លើយនេះ លោកស្រីបាននិយាយថា "នៅសម័យខ្មែរក្រហម មានសំបុត្រមួយចំនួនត្រូវគេក្លែងបន្លំ"។ តើលោកស្រីចង់និយាយថាយ៉ាងម៉េចដែរ ពេលដែលលោកស្រីថាមានឯកសារដែលគេក្លែងក្លាយ លោកចង់មានន័យថាយ៉ាងម៉េចដែរ? លោកស្រីចង់មានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** ចាស ខ្ញុំសូមជម្រាបលោកប្រធាន។ កាលថ្ងៃដែលខ្ញុំបានទៅជួបការអញ្ជើញខ្ញុំមកភ្នំពេញទាំងលើកមុនហ្នឹង ការស៊ើបអង្កេតហ្នឹង មានសំបុត្រមួយគាត់លើកបង្ហាញខ្ញុំថា សំបុត្រនេះ គឺជាសំបុត្ររបស់ខ្ញុំ របស់នាងខ្ញុំ។ ហេតុតែខ្ញុំយកមកមើល ថាមិនមែនជាអក្សរខ្ញុំ ហើយគ្មានហត្ថលេខាទៀត។ បានខ្ញុំកំណត់ថា សំបុត្រនេះជាសំបុត្រក្លែងក្លាយ។ ចង់និយាយថាមានការជំទាស់ ឬក៏យ៉ាងណា។ ខ្ញុំចង់និយាយអ៊ីចឹង នេះទិសដៅខ្ញុំ។

**ស៖** នៅក្នុងកំណត់របស់លោកនោះ លោកស្រីថា សំបុត្រនោះត្រូវបានផ្ញើចេញចូលស្រុក ហើយនិងឃុំ តាមរយៈនីរសារដែលធ្វើការនៅមន្ទីរឃុំ ហើយនិងមន្ទីរស្រុក។ អ៊ីចឹង តើនីរសារទាំងអស់នេះ មានសិទ្ធិបើកសំបុត្រដែរឬទេ?

**ឆ៖** ចាស អត់ទេ។

[១៤:១៨:២០]

**ស៖** ដោយហេតុថានីរសារតែមួយដែលលោកស្រីស្គាល់នោះ គាត់ត្រូវរត់សំបុត្រពីឃុំទៅស្រុក តើសំបុត្រទាំងអស់នោះ អាចត្រូវក្លែងបន្លំដែរឬទេ?

**ឆ៖** ចាស ខ្ញុំអាច មិនអាចសន្និដ្ឋានបានដែរ។

**ស៖** បើសិនជាមនុស្សម្នាក់ដែលលោកមិនស្គាល់ ឬក៏អ្នកស្រុកក៏មិនស្គាល់គាត់ដែរ ហើយគាត់ក៏គ្មានសិទ្ធិដើរហើរក្នុងស្រុកហ្នឹង មកបង្ហាញខ្លួនឲ្យលោក -- មកជួបលោកស្រី ឬក៏ទៅជួបស្រុកនោះជាមួយនឹងឯកសារ តើក្នុងករណីហ្នឹងមានរឿងអីកើតឡើង ហើយតើលោកស្រីខ្លួនឯងផ្ទាល់ហ្នឹង លោកស្រីទុកចិត្តគេទេ?

**ឆ៖** ចាស--

[១៤:១៩:៣២]

**ប្រធានអង្គជំនុំ៖**

ខឹម ហឿន កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ព្រោះថាវាជាការស្នើសុំឲ្យមានការទាយស្មានដល់ទៅពីរដង ព្រោះសាក្សីគាត់មិនអាចឆ្លើយអំពីស្ថានភាពទាំងអស់នេះទេ វាជាការស្នើសុំឲ្យមានការទាយស្មាន ហើយវានៅក្រោយឆ្នាំ១៩៧៩ទៀត។ ដូច្នេះ ខ្ញុំគិតថាមិនគួរអនុញ្ញាតឲ្យមានការសួរសំណួរបែបនេះទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំដូចជាមិនយល់ទេ។ តែឥឡូវខ្ញុំសួរឡើងវិញម្ដងទៀត តើនៅសម័យនោះលោកស្រីធ្លាប់ឮថាមានមនុស្សដែលត្រូវបានគេចាប់ខ្លួន ដោយសារខ្លួនហ្នឹងអួតខ្លួនឯងថាជានីរសារ ដែលរត់សំបុត្ររវាងពីឃុំទៅស្រុកនៅស្រុកត្រាំកក់? តើករណីបែបហ្នឹងមានធ្លាប់កើតឡើងទេ មកកុហកគេថាខ្លួនជានីរសារនេះ?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស អត់មានទេ។ អត់ឮទេ។

[១៤:២១:០១]

**ស៖** អម្បាញ់មិញនេះលោកស្រីបាននិយាយទាក់ទងនឹងលិខិតក្លែងក្លាយនេះ លោកស្រីមិនមើលអក្សរខ្លួនឯងមិនស្គាល់ទេ មើលទៅថា ឃើញថាមិនមែនជាអក្សររបស់លោកស្រីទេ ហត្ថលេខាក៏មិនអ៊ីចឹងដែរ។ ក៏ប៉ុន្តែអម្បាញ់មិញនេះ លោកស្រីក៏បាននិយាយផងដែរថា មានមនុស្សម្នាក់នៅឃុំលោកស្រីហ្នឹងសរសេរជំនួសលោកស្រី ហើយលោកស្រីជាអ្នកអានឲ្យសរសេរតាម។ អ៊ីចឹង ខ្ញុំសួរលោកស្រីថាតើក្នុងករណីហ្នឹងនេះ លោកស្រីម៉េចក៏ប៊ានថា ឯកសារហ្នឹងជាឯកសារក្លែងក្លាយទៅវិញ បើសិនជាពេលខ្លះលោកស្រីឲ្យគេសរសេរឲ្យ? តើមានករណីហ្នឹងលោកស្រីយល់យ៉ាងម៉េចដែរ បើពេលខ្លះមិនមែនជាអក្សរលោកស្រី តែលោកស្រីឲ្យគេសរសេរឲ្យ?

**ឆ៖** ចាស ក្នុងការសរសេរ មានពេលខ្លះសរសេរឲ្យ ខ្លះក៏ខ្ញុំសរសេរខ្លួនឯង តែការសរសេរហើយសុទ្ធតែពិនិត្យ។

**ស៖** ដូច្នេះមុននឹងពេលផ្ញើសារណាមួយទៅស្រុកនោះ លោកស្រីតែងតែត្រួតពិនិត្យលើខ្លឹមសារច្បាស់លាស់។ តើត្រឹមត្រូវដែរឬទេ ខ្ញុំនិយាយដូច្នេះ?

**ឆ៖** ចាស ជួនកាលបើខ្ញុំអត់នៅ ក៏មានអ្នកតំណាងពិនិត្យ។

[១៤:២២:៥៨]

**ស៖** នៅចម្លើយ១៩៨ ដល់ ២០១ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី លោកស្រីនិយាយថា លោកស្រីស្គាល់អក្សររបស់ តាអាន -- តាអាន់។ ខ្ញុំចង់និយាយអំពី តាអាន់ ដែលជាប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់។ លោកស្រីនិយាយអំពីឯកសារមួយដែលលោកស្រីនិយាយថា មិនមែនជាអក្សររបស់ តាអាន់ ទេ ពីព្រោះថាលោកស្រីធ្លាប់ស្គាល់អក្សររបស់ តាអាន់ នេះ។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើ តាអាន់ នេះគាត់សរសេរប្រភេទឯកសារអ្វីដែរ ដែលលោកស្រីបានទទួលពីគាត់ក្នុងឋានៈជាមេឃុំ ឬក៏ជាក្នុងឋានៈជាសមាជិកគណៈកម្មការស្រុកបាទ?

**ឆ៖** ចាស ខ្ញុំដែលធ្លាប់ស្គាល់នេះ ដោយខ្ញុំធ្លាប់នៅរៀនសូត្រនៅផ្ទះភូមិជាមួយគ្នា ខ្ញុំធ្លាប់ស្គាល់តែការទាក់ទងជាឯកសារអីពីខាងមន្ទីរហ្នឹងមក គឺមានដែរ តែយូរៗមានម្តង តែខ្ញុំធ្លាប់ស្គាល់តាំងពីដើមមក។

**ស៖** អ្នកស៊ើបអង្កេតបានបង្ហាញឯកសារមួយ ឯកសារ E3/2012។ ខ្ញុំសូមឲ្យលោកស្រីជួយមើលឯកសារហ្នឹង។

[១៤:២៤:៤៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារហ្នឹង បញ្ចាំង។ ជាភាសាខ្មែរ ERN គឺ 0082728 (ស៊ីក), ជាភាសាអង់គ្លេសគឺ 002765--, ជាភាសាបារាំង 00797852។ គឺជាលិខិតមួយដែល អាន់ ផ្ញើនៅថ្ងៃទី០១ សីហា ឆ្នាំ១៩៧៧ ទៅដល់សមមិត្ត ហឿន។ ហើយមានសរសេរដូចទៅនេះក្នុងសំបុត្រនេះ “ស្នើបញ្ជូនកម្លាំងចុះទៅចាប់ខ្មាំងពីរនាក់នៅភូមិស្រែគ្រួរ ឈ្មោះទី១ ឡេន ស្រុកកំណើតនៅភ្នំពេញ ទី២ ឈ្មោះ ស៊ូ មកពីខេត្តមាត់ជ្រូក។ ពួកគេទាំងអស់នេះត្រៀមខ្លួនរត់ទៅវៀណាម ហើយពួកវាបានជាប់ចម្លើយរបស់ អ៊ិញ ហើយនិង អាថន ដែលយើងចាប់បានពីមុន”។ បាទ សូមបញ្ចប់ការដកស្រង់។ តើឈ្មោះ ឡេន ហើយនិង ស៊ូ ហើយ អ៊ិញ, ថន ដែលមិនមែនជាអ្នកស្រុកស្រែគ្រួរទេក៏ប៉ុន្តែបានរស់នៅទីនោះ នៅពេលដែលលោកស្រីបានធ្វើជាមេឃុំនោះ។ លោកស្រីនឹកឃើញឈ្មោះទាំងបីនាក់ហ្នឹងទេ? ហើយមាននឹកឃើញពីការចាប់ខ្លួនអ្នកទាំងអស់គ្នាទេ?

**ឆ៖** ខ្ញុំនឹកអត់ឃើញ អត់ស្គាល់ឈ្មោះហ្នឹង។

**ស៖** បាទ ខ្ញុំសូមផ្តល់ព័ត៌មានបន្តិចទៀតលើឈ្មោះទាំងអស់នេះ។ មាននៅក្នុងឯកសារ 157.13 នៅទំព័រជាភាសាខ្មែរ ERN គឺ00270847, ជាភាសាបារាំង គឺ 00971307, ជាភាសា

អង់គ្លេស 01064190 ដល់ 91។ គឺជាឯកសារដែលធ្វើនៅមន្ទីរក្រាំងតាចាន់ដែលសង្ខេបអំពីព័ត៌មានទទួលបានពីអ្នកទោសម្នាក់នុ៎ង។ ហើយយើងដឹងថាឈ្មោះ អ៊ុញ ហ្នឹង គឺឈ្មោះពេញគឺ គីម អ៊ុញ មានអាយុ ៣២ឆ្នាំ ហើយដែលគេនិយាយថាគាត់ហ្នឹងជាស័ក្តិ១ ហើយនិងគណនីករនៅក្នុងរបបលន់នល់។ គាត់ ហ្នឹងត្រូវបានចោទថាខ្សែរយៈរបស់ លាង ជាវ ហើយនិងខ្សែរយៈរបស់នាង។ តាមពិតឈ្មោះហ្នឹងគឺ គាត នឹង។ នៅក្នុងរបាយការណ៍នេះក៏មានរៀបរាប់ពេញរបស់ ឡេន ផងដែរ ហៅឈ្មោះពេញ តេង ឡេន ហើយមួយទៀតឈ្មោះ ស៊ូ – ឈ្មោះពេញនោះ ផាន់ ស៊ូ។ ទាក់ទងនឹងឈ្មោះ ថន នោះឈ្មោះពេញរបស់គាត់គឺ វាល់ ថន គាត់មានអាយុ៤៨ឆ្នាំ កើតនៅគិរីវង់ ហើយស័ក្តិ២ រហូតដល់ឆ្នាំ១៩៧៥។ ឥឡូវនេះលោកស្រីបានឈ្មោះពេញទាំងអស់ហើយ ឈ្មោះ គីម អ៊ុញ, វាល់ ថន ហើយនិងលាង ជាវ និង គាត ណោង ដែលគាត់ជាមេខ្សែរយៈ។ នេះបើតាមរបាយការណ៍ចេញពីក្រាំង តាចាន់។ តើលោកស្រីនឹកឃើញទេ អំពីការចាប់ខ្លួនបុគ្គលទាំងអស់នេះ ដែលខ្ញុំទៀតតែរៀបរាប់ឈ្មោះ ឲ្យនេះនឹកឃើញទេ?

**ឆ៖** ចាស ខ្ញុំមិនបានចាំ មិនទាំងស្គាល់ឈ្មោះ។

**ស៖** ចម្លើយ២០២ ដល់២០៥ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកស្រីបាននិយាយបីដងថាលោកស្រីមិនស្គាល់សំបុត្រជាក់លាក់ដែលអ្នកស៊ើបអង្កេតបានបង្ហាញទៅលោកស្រីនោះទេ។ នេះគឺជាលិខិតរបស់ អាន់ ដែលចុះថ្ងៃទី១ សីហា ឆ្នាំ១៩៧៧។ ឯកសារ គឺE3/2012 ប៉ុន្តែផ្ទុយទៅវិញ លោកស្រីបាននិយាយថា លោកស្រីធ្លាប់បានទទួលលិខិតប្រភេទនេះពី អាន់។ ខ្ញុំសូមអានជាភាសាអង់គ្លេស។

[១៤:៣០:៤១]

(អានភាសាអង់គ្លេស) “សំណួរ២០២៖ តើឃុំរបស់លោកស្រីធ្លាប់ទទួលលិខិតបែបនេះទេ? ឆ្លើយ៖ ចាស។ លិខិតហ្នឹងគឺបានបញ្ជូនទៅ ឃឹម ដែលទទួលខុសត្រូវខាងយោធា ហើយ ឃឹម ត្រូវយកលិខិតនេះមកឲ្យខ្ញុំ។ សំណួរ២០៣៖ តើលោកស្រីធ្លាប់ទទួលលិខិតប្រភេទនេះទេ? ចម្លើយ៖ ចាស ខ្ញុំធ្លាប់។ សំណួរ២០៤៖ តើលោកស្រីធ្លាប់ស្គាល់លិខិតនេះដែរឬទេ? លិខិតនេះ ត្រូវបានថតចម្លងពីលិខិតដើម? ចម្លើយ២០៤៖ គឺលិខិតប្រភេទនេះ ក៏ប៉ុន្តែខ្ញុំមិនចាំឈ្មោះក្នុងលិខិតនេះទេ។ សំណួរ២០៥៖ តើលោកស្រីធ្លាប់ទទួលលិខិតបែបនេះ ពីអាន់ ដែរឬទេ? ចម្លើយ៖ ចាស”។ សូមបញ្ចប់ការដកស្រង់។

[១៤:៣១:៥៣]

នៅពេលដែលលោកស្រីទទួលសំបុត្រពី អាន់ ដែលជាប្រធានមន្ទីរសន្តិសុខក្រាំតាចាន់ មន្ទីរសន្តិសុខស្រុកនោះ តើលោកស្រីមានលទ្ធភាពមិនធ្វើតាមបង្គាប់ដែរឬទេ?

**ឆ៖** សុំម្ដងទៀត អត់ច្បាស់។

**ស៖** បាទ នៅពេលដែលលោកស្រីទទួលសំបុត្រពីមន្ទីរសន្តិសុខក្រាំតាចាន់ គឺឈ្មោះ អាន់ ដែលលោកស្រីស្គាល់។ លោកស្រីបាននិយាយថា លោកស្រីបានទទួលមួយចំនួនដែរ តើក្នុងករណីហ្នឹងលោកស្រីមានលទ្ធភាពមិនគោរពទៅតាមអ្វីដែលសរសេរនៅក្នុងសំបុត្រហ្នឹងទេ? ឧទាហរណ៍ដូចថាបើគេតម្រូវឲ្យលោកស្រីចាប់មនុស្សអីជាដើមនេះ តើលោកស្រីមានលទ្ធភាពមិនទៅចាប់មនុស្សទៅតាមការបង្គាប់បញ្ជាដែរឬទេ?

**ឆ៖** ខ្ញុំអត់មានដែលបានចាប់មនុស្សទេ។ ខ្ញុំមានសិទ្ធិតែរាយការណ៍តែប៉ុណ្ណោះ។

[១៤:៣៣:១៨]

**ស៖** បាទ ខ្ញុំមិនបាននិយាយថា លោកស្រីជាអ្នកទៅចាប់មនុស្សដោយខ្លួនឯងនោះទេ។ ក៏ប៉ុន្តែគ្រាន់តែចង់សួរថាតើលោកធ្លាប់នាំមនុស្សទៅឲ្យស្រុកដែរឬទេ នៅពេលដែលទទួលសំបុត្រពី តាអាន់ហើយនោះ?

**ឆ៖** ទទួលសំបុត្រ--

**ស៖** លោកស្រី ខ្ញុំស្ដាប់អត់ឮការបកប្រែទេ។ សុំឲ្យនិយាយម្ដងទៀតបានទេ។

**ឆ៖** ការទទួលសំបុត្រហើយ គឺខ្ញុំអត់មានចាប់ ឬក៏បញ្ជូនទេ គឺសំបុត្រមកពីស្រុក គឺកងទ័ពស្រុក និងឈ្លបឃុំ គេរួមគ្នា។ ចំពោះខ្ញុំ ខ្ញុំអត់ទេ។

**ស៖** ខ្ញុំសូមអានសម្រង់មួយនៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រី គឺខ្ញុំអានជាភាសាអង់គ្លេស នៅចម្លើយ២០៦។

[១៤:៣៤:៤៦]

(អានភាសាអង់គ្លេស) "ខ្ញុំបានបញ្ជូនទៅឲ្យមនុស្សឈ្មោះ អាន់ ហើយខាង អាន់ ជាអ្នកធ្វើសកម្មភាពបន្តទៀត។ បន្ទាប់ពីទទួលសំបុត្រ ខ្ញុំឲ្យខាងភូមិទៅតាមរកមនុស្សដែលមានឈ្មោះនៅក្នុងសំបុត្រ។ តែខ្ញុំមិនចាំថា ភូមិរកមនុស្សនោះឃើញ ឬក៏អត់នោះទេ។ បន្ទាប់មកទៀត បើភូមិរកមនុស្សឃើញ ខ្ញុំនឹងបញ្ជូនមនុស្សនោះទៅមន្ទីរស្រុក។ សំណួរ២០៧ នៅពេលដែលលោកស្រីរៀបចំឲ្យភូមិស្វែងរកមនុស្ស មានន័យថាលោកស្រីឲ្យឈ្លបរបស់លោកស្រីទៅចាប់មនុស្សទាំងអស់នោះ តើត្រឹមត្រូវ

ដែរឬទេ? ចម្លើយ២០៧៖ ចាស ខ្ញុំឲ្យឈ្លបរបស់ខ្ញុំចុះទៅជាមួយនឹងភូមិ ដើម្បីស្វែងរកមនុស្សទាំងអស់នោះ ព្រោះឈ្លបមិនមែនជាអ្នកនៅក្នុងភូមិនោះទេ។ ចម្លើយ២០៨៖ ក្រោយពីចាប់មនុស្សហើយ ឈ្លបបញ្ជូនមនុស្សទៅថ្នាក់ឃុំសិន ព្រោះជួនកាលមនុស្សមិនមែននៅកន្លែងតែមួយនោះទេ។ ដូច្នេះ ត្រូវប្រមូលមនុស្សទាំងអស់នោះទៅថ្នាក់ឃុំសិន ទើបបញ្ជូនទៅថ្នាក់ស្រុក។ ចម្លើយ២០៩៖ ឈ្លបរាយការណ៍ទៅខ្ញុំអំពីការចាប់ខ្លួនមនុស្ស ហើយបន្ទាប់មក ឈ្លបបញ្ជូនទៅស្រុក។ សំណួរ២១០៖ តើឈ្លបបញ្ជូនមនុស្សទៅស្រុក ឬក៏បញ្ជូនទៅគុកក្រាំតាចាន់? ចម្លើយរបស់លោកស្រី គឺចម្លើយ២១០៖ គឺអាចថាបញ្ជូនគុកតែម្តង ហើយរាយការណ៍ទៅស្រុក ឬក៏អាចបញ្ជូនទៅស្រុក ព្រោះខ្ញុំមិនច្បាស់ត្រង់ចំណុចនេះទេ”។ សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងលោកស្រីបាននិយាយថា នៅពេលនោះក្រោយពីការចាប់មនុស្សទាំងអស់នោះហើយ ឈ្លបហ្នឹងនាំមកឃុំ។ អ៊ីចឹង ខ្ញុំសួរថាតើនៅឃុំហ្នឹងមានកន្លែងឃុំខ្លួនមនុស្សជាបណ្តោះអាសន្នដែរឬទេមុនពេលនឹងបញ្ជូនពួកគេទៅស្រុកនោះ? តើមានកន្លែងឃុំខ្លួនទេ?

**ឆ៖** ចាស អត់ទេ។ តែខ្ញុំអត់មានចាប់យកមដាក់ឃុំទេ មានតែពីខាងស្រុក គេមកស្រាវជ្រាវតាមការរាយការណ៍។

[១៤:៣៧:៥៣]

**សៈ** តើស្រុកនោះមានប្រាប់មកខាងឃុំលោកស្រីទេ ដែលប្រាប់ថាពួកគេកំពុងតែរកចាប់មនុស្សនោះ?

**ឆ៖** ចាស អាហ្នឹងមិនមែនខ្ញុំអ្នកទទួលទេ។ ខ្ញុំអត់ទទួលខាងយោធាទេ ព្រោះខ្ញុំជាស្រី។

**សៈ** បាទ សូមអរគុណ។ ខ្ញុំបានសម្រង់នៃចម្លើយរបស់លោកស្រីដ៏វែងមួយ ទាក់ទងចំណុចមួយថានៅពេលដែលលោកស្រីទទួលបានសំបុត្រពី អាន់ ហ្នឹងលោកស្រីត្រូវតែតាមចាប់បុគ្គលមួយចំនួន ឥឡូវនេះលោកស្រីបែរជានិយាយថា ស្រុកហ្នឹងមកចុះដល់កន្លែងតែម្តង ដើម្បីចាប់មនុស្ស។ ឥឡូវខ្ញុំសូមចោទសំណួរចុងក្រោយមួយទាក់ទងនឹងមន្ទីរក្រាំងតាចាន់ លោកស្រីបានលើកឡើងថា -- មានពីរសំណួរទៀត គឺនៅចម្លើយ២៤៤ លោកស្រីបាននិយាយថា មានមនុស្សដែលត្រូវបានគេសម្លាប់ខ្លួននៅក្រាំងតាចាន់ គ្រាន់តែលោកស្រីមិនឃើញដោយផ្ទាល់ភ្នែកខ្លួនឯងនោះទេ។ តើនៅក្នុងរបបហ្នឹងលោកស្រីមានដឹងថា មានមនុស្សត្រូវបានគេសម្លាប់នៅមន្ទីរក្រាំងតាចាន់ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានទៅមើល ហើយក៏អត់ដែលបានឃើញដែរ។

**ស៖** បាទ ខ្ញុំដឹងហើយ តែខ្ញុំសួរថាលោកស្រីធ្លាប់ឮគេនិយាយដែរឬទេ ដូចលោកស្រីបានឆ្លើយនៅក្នុងចម្លើយ២៤៤នេះ លោកស្រីឆ្លើយថា "មានមនុស្សដែលត្រូវបានគេសម្លាប់ខ្លួននៅមន្ទីរសន្តិសុខក្រាំងតាចាន់?"។

**ឆ៖** ធ្លាប់ឮ គ្រាន់តែធ្លាប់ តែអត់ដែលបានឃើញទេ។

**ស៖** នៅចម្លើយ២៤៧ លោកបាននិយាយថា មានគេបញ្ជូនមនុស្សទៅក្រាំងតាចាន់ ហើយមានអ្នកខ្លះចេញមកវិញ ហើយលោកស្រីបានឮគេនិយាយ។ លោកស្រីអាចប្រាប់ឲ្យច្បាស់ដែរឬទេ ថាអ្នកណាដែលត្រូវបានគេបញ្ជូនទៅមន្ទីរក្រាំងតាចាន់ ហើយក្រោយមកទៀត ពួកគេបាននិយាយប្រាប់លោកចេញមកវិញហើយនិយាយប្រាប់លោកស្រី?

**ឆ៖** ខ្ញុំភ្លេចបាត់ទៅហើយ ខ្ញុំមិនបានចាំទេ។ អ្នកនិយាយក៏មិនចាំ។

[១៤:៤១:០៦]

**ស៖** តើឈ្មោះ យាយញ៉ ហើយនិងក្រុមគ្រួសារគាត់ ដូចជាឈ្មោះ មាស សារ៉ាត់ ហៅ រ៉ាត់ ហើយនិងកូនប្រុសគាត់មួយទៀតឈ្មោះ មាស សុខា គេហៅ ខា នោះ។ តើលោកស្រីស្គាល់ពួកគាត់ទេ? គាត់មកពីភូមិស្រែគ្រូ នៅក្នុងឃុំរបស់លោកស្រីកាន់ដែរហ្នឹង ស្គាល់ឈ្មោះទាំងប៉ុន្មាននាក់ហ្នឹងទេ?

**ឆ៖** ចាស ស្គាល់តើ។

**ស៖** តើពួកគាត់ហ្នឹងហើយឬ ដែលនិយាយប្រាប់លោកស្រីអំពីអ្វីដែលកើតមានឡើងនៅមន្ទីរក្រាំងតាចាន់ ដែលប្រាប់លោកស្រីថា មានមនុស្សដែលត្រូវបានគេសម្លាប់នៅទីនោះ?

**ឆ៖** ប្រហែលជាពួកហ្នឹង ខ្ញុំភ្លេច ចាំមិនបាន។

**ស៖** តើលោកស្រីមានចាំពីសមាជិកក្រុមគ្រួសាររបស់ យាយញ៉ ផ្សេងទៀត ឧទាហរណ៍ប្ដីរបស់គាត់ឈ្មោះ មាស គុណ ហើយនិងប្ដីរបស់ មាស សារ៉ាត់ ដែលឈ្មោះ មុំ បឿន អីនេះ? លោកស្រីមានដឹងថាហេតុអ្វីបានជាបុគ្គលទាំងពីររូបនេះត្រូវបានគេបញ្ជូនទៅមន្ទីរក្រាំងតាចាន់ដែរឬទេ?

**ឆ៖** ចាស ខ្ញុំបានដឹង តែខ្ញុំមិនបានចាំសាច់រឿងអស់។ ពេលនោះថា មានខ្ញុំមិនចាំអស់ទេ មានផ្ដិតមេដៃរំលាយសហករណ៍ភូមិស្រែគ្រូរហ្នឹងចំនួនប៉ុន្មានទេខ្ញុំ ហើយក៏វាយការណ៍ទៅ គេធ្វើរាយការណ៍ពីភូមិ ហើយខ្ញុំក៏វាយទៅស្រុកទៀតទៅ។

**ស៖** តើលោកស្រីមានធ្លាប់បានឮគេនិយាយអំពីកិច្ចប្រជុំមួយ ដែលទំនងជាត្រូវបានរៀបចំឡើងនៅក្នុងភូមិស្រែគ្រូរដែល មាស គុណ ហើយនិង មុំ បឿន ហ្នឹងបានចូលរួមប្រជុំ ដែលគាត់រៀបចំប្រជុំ

ហ្នឹងដើម្បីរិះគន់អំពីការគ្រប់គ្រងភូមិហ្នឹង? តើលោកស្រីធ្លាប់ដឹងពីកិច្ចប្រជុំសម្ងាត់ហ្នឹងទេ?

**ឆ៖** ចាស ដឹងតើ។

[១៤:៤៤:០១]

**លោក វាំងសង់ វ៉ាយជ៍ ដេស្សាឯល៖**

លោកប្រធាន បើសិនជាលោកប្រធានចង់ដល់ម៉ោងសម្រាកហើយ ខ្ញុំយល់ស្របលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ លោកស្រី ខឹម ហឿន រួមទាំងមេធាវីប្រឹក្សាសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ ហើយសម្រាកពីពេលនេះទៅរហូតដល់ម៉ោងបី យើងចាប់ផ្ដើមបន្តនីតិវិធីនៃការសវនាការតទៅទៀត សូមជ្រាប។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០២:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សួស្ដីលោកស្រី ខឹម ហឿន ឥឡូវនេះយើងចាប់ផ្ដើមបន្តសវនាការទៀត។ តើលោកស្រីត្រៀមខ្លួនហើយឬនៅ?

**លោកស្រី ខឹម ហឿន៖**

ចាស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តទៅទៀតនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅភាគីតំណាងសហព្រះរាជអាជ្ញា និងរួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានពេលវេលាពេលនេះទៅរហូតដល់ម៉ោងចប់នៅរសៀលនេះ។

**លោក វាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** លោកស្រីសាក្សី ខ្ញុំមិនសួរវែងនោះទេ ខ្ញុំនឹងសួរសំណួរមួយចំនួនតូចទេ មុននឹងប្រគល់វេទិកានេះជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ មុនពេលឈប់សម្រាកអម្បាញ់មិញនេះ យើងនិយាយអំពីការចាប់ខ្លួនគ្រួសារ មាស គុណ និង មុំ បឿន។ លោកស្រីថា លោកស្រីស្គាល់ពួកគាត់។ ហើយអ្នកដែលនៅរស់រានមានជីវិតទាំងអស់នេះហើយ ដែលប្រាប់លោកស្រីអំពីអ្វីដែលបានកើតឡើងនៅមន្ទីរក្រាំងតាចាន់។ តើលោកស្រីអាចរៀបរាប់អំពីរឿងហេតុនៅភូមិស្រែគ្រូរ ខ្ញុំចង់ដឹងថាអ្នកណាជាអ្នកចេញសេចក្ដីសម្រេចឲ្យចាប់គ្រួសារនេះ? តើការសម្រេចហ្នឹងចេញមកពីថ្នាក់លើមែនទេ?

[១៥:០៤:៤៥]

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស សូមជម្រាបបញ្ហាដែល គុណ ដែលចាប់ហ្នឹងគឺ មុនដំបូងខ្ញុំចាំ ក៏វាភ្លេចខ្លះ គាត់បានទៅប្រជុំក្នុងភូមិ ប្រជុំក្នុងភូមិហ្នឹងផ្ដិតមេដៃ តែខ្ញុំមិនបានច្បាស់ទេ ខ្ញុំភ្លេចជាយូរហើយ។ ប្រហែលជា ៥០, ៦០, ៧០ អីក៏មិនដឹងដែរ អាហ្នឹងមិនច្បាស់។ ថាឲ្យផ្លាស់ប្ដូរ ឬរំលាយសហករណ៍ស្រែគ្រូរហ្នឹង។ អ៊ីចឹងពីភូមិគេរាយការណ៍មកឲ្យខ្ញុំ ខ្ញុំក៏រាយទៅខាងស្រុក។ ឯការចាប់ ការអីទៅនេះ គឺអត់មានខ្ញុំ ពួកខ្ញុំអ្នកចាប់ អ្នកអីទៅទេ គឺខាងឈ្លប ឬកងទ័ពស្រុកអីគេមកដោយខ្លួនគេ។ ធ្វើក ខាងផ្សេងក្រៅពីហ្នឹងទៀតក៏ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំមិនដែរដឹងទេរឿងចាប់ រឿងអី។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអានសម្រង់ផ្សេងទៀតនៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រី។ ពាក់ព័ន្ធនឹងរឿងរ៉ាវដែលថា លោកស្រីៗខ្លាចនៅក្នុងរបបនោះ។ គឺថាប្រសិនបើលោកស្រីមិនអនុវត្តតាមបញ្ជាពីថ្នាក់លើទេ ប្រហែលជាលោកស្រីមិនអាចរស់រានមានជីវិតបានទេ។ នេះជាចម្លើយរបស់លោកស្រី គឺនៅចម្លើយ២២០។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស “ទោះបីជាខ្ញុំមិនភ្លេច ឬភ្លេចក៏ដោយក៏នៅជំនាន់ខ្មែរក្រហមគឺត្រូវតែធ្វើដូច្នេះ បើមិនដូច្នេះទេគឺនឹងស្លាប់មិនខាន។ ខ្ញុំមិនចង់ធ្វើដូច្នេះទេ ព្រោះខ្ញុំខ្លាចបើខ្ញុំមិនធ្វើ ខ្ញុំនឹងបែកកូនបែកចៅមិនខាន”។ ចម្លើយ២៥៨៖ “វាពាក់ព័ន្ធទៅលើខ្ញុំ មិនអីទេ ទោះបីជាពាក់ព័ន្ធនឹងខ្ញុំក៏មិនអីដែរ ព្រោះខ្ញុំបានប្រគល់ខ្លួនហើយ ខ្ញុំសោកស្ដាយនូវអ្វីដែលបានកើតឡើង”។ ហើយ

និងចម្លើយ៣១០៖ "ប្រសិនបើខ្ញុំមិនជឿជាក់ទៅលើបដិវត្តន៍ តើខ្ញុំធ្វើយ៉ាងណាអាចរស់រានមានជីវិតរហូតមកដល់ឥឡូវនេះបាន"។ សូមបញ្ចប់ការដកស្រង់។

តើលោកស្រីអាចពន្យល់អំពីការភ័យខ្លាចក្នុងការប្រព្រឹត្តកំហុស ឬក៏ការមិនធ្វើតាមបញ្ជាដែលបានដាក់ជូនពីថ្នាក់លើនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោកស្រីនោះ?

[១៥:០៧:៥៨]

**ឆ៖** ចាស សូមបញ្ជាក់បើផែនការពីលើដាក់យ៉ាងម៉េចគឺខ្ញុំត្រូវតែអនុវត្តអ៊ីចឹង ដូចខ្ញុំបានជម្រាបខាងដើមចាស។

**ស៖** លោកស្រីបាននិយាយថា លោកស្រីសោកស្តាយចំពោះអ្វីដែលបានកើតឡើង។ ឥឡូវនេះលោកស្រីមានឱកាសនៅចំពោះមុខតុលាការហើយ អ៊ីចឹងលោកស្រីអាចពន្យល់ឲ្យបានច្បាស់ ថាតើលោកស្រីសោកស្តាយអ្វីខ្លះចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហមនោះ?

**ឆ៖** ចាស សូមជម្រាបថា ខ្ញុំសោកស្តាយដោយឃើញខ្មែរនិងខ្មែរបាក់បែកគ្នា សម្លាប់គ្នាអី។ ហើយក៏ការរស់នៅខុសប្រពៃណីអី ខ្ញុំសោកស្តាយត្រង់ហ្នឹង។ ហើយការបាក់បែកកូនចៅមិនបាននៅមូលគ្នាចាស គ្មានឱកាសជួបជុំប្តីប្រពន្ធ។

**ស៖** លោកស្រីបាននិយាយអំពីកិច្ចប្រជុំនៅថ្នាក់ស្រុកអម្បាញ់មិញនេះ ហើយនៅក្នុងចម្លើយរបស់លោកស្រីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតក៏លោកស្រីថាបានចូលរួមកិច្ចប្រជុំនៅថ្នាក់តំបន់ផងដែរ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើមានមហាសន្និបាតដែលត្រូវបានធ្វើនៅស្រុក -- នៅតំបន់១៣ ម្តងឬក៏ពីរដង ហើយឬក៏មានធ្វើនៅភូមិភាគនិរតីដែរឬទេ?

**ឆ៖** ចាស អត់ដែលបានធ្វើភូមិភាគទេ។ តែក្នុងតំបន់ ខ្ញុំមិនដែលបានចូលរួម មានធ្វើ តែខ្ញុំអត់បានចូលរួមទេ។ តែខ្ញុំមានបញ្ហាខាងសុខភាព។

[១៥:០៩:៣៦]

**ស៖** ខ្ញុំនឹងបញ្ចប់ការដកស្រង់មួយចំនួនបន្ថែមទៀត ជាពិសេសពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីបាននិយាយអំពីការប្រជុំនៅថ្នាក់តំបន់។ កិច្ចប្រជុំទាំងអស់ហ្នឹងគឺជាកិច្ចប្រជុំធម្មតាទេ មិនមែនជាមហាសន្និបាតទេ។ ខ្ញុំសូមដកស្រង់ឃ្លាជាភាសាអង់គ្លេសនៃកំណត់ហេតុរបស់លោកស្រី គឺE319/12.3.2 ដែលចាប់ផ្តើមពីចម្លើយទី៩០។

(អានភាសាអង់គ្លេស)៖ "ពួកគេឲ្យយើងរាយការណ៍អំពីបញ្ហាសន្តិសុខ។ សំណួរទី៩១៖ នៅក្នុង

កិច្ចប្រជុំ -- ប្រធានអង្គប្រជុំបានផ្តល់ការណែនាំ ឬក៏ការចង្អុលបង្ហាញជាក់លាក់ណាមួយ ដើម្បីកំណត់នរណាជាមុខសញ្ញាខ្មាំងដែរឬទេ? ហើយចម្លើយរបស់លោកស្រីទី៩១ លោកស្រឆ្លើយថា៖ ចាស មាននិយាយអំពីបញ្ហាខ្មាំង។ ខ្ញុំមិនសូវចាំពាក្យគេនិយាយនោះទេ។ សេចក្តីរាយការណ៍ពីភូមិដែលសរសេរជាលាយលក្ខណ៍អក្សរ គឺខ្ញុំត្រូវផ្ញើលិខិតលាយលក្ខណ៍អក្សរនោះ ទៅថ្នាក់លើតែម្តង។ (ហើយខាងក្រោមបន្តិច) ថ្នាក់លើណែនាំថា អ្នកណាខ្លះជាខ្មាំង ហើយខ្ញុំយកណែនាំទាំងអស់នោះ ទៅប្រាប់ភូមិវិញ។ គេនិយាយថា ឲ្យស្វែងរកអ្នកណាដែលប្រឆាំង។ គេពុំនិយាយថាខ្មាំងនោះទេ។ សំណួរ២៤៩៖ នៅក្នុងការប្រជុំជាមួយនឹងតំបន់ ឬក៏ស្រុក តើប្រធានអង្គប្រជុំបាននិយាយអំពីប្រភេទមនុស្សដែលត្រូវបានគេកំណត់ថាជាគោលដែលប្រឆាំងនឹងអង្គការដែរឬទេ? ចម្លើយ៖ មនុស្សដែលប្រឆាំងនឹងអង្គការ គឺជាមនុស្សដែលខូចខិល មិនល្អ។ និយាយជារួម គឺមនុស្សដែលមិនចេះស្តាប់គេ។ គេបានឲ្យតាមដានមនុស្សដែលសង្ស័យថាជាមនុស្សខិលខូច ឬមិនល្អជាដើម គឺទាំងប្រជាជនថ្មី និងប្រជាជនចាស់"។ សូមបញ្ចប់ការដកស្រង់។

[១៥:១៣:១៦]

តើលោកស្រីអាចបញ្ជាក់បានទេថា មេៗ ឬក៏កម្មាភិបាលតំបន់ណាខ្លះដែលបាននិយាយប្រាប់លោកស្រីអំពីបញ្ហាហ្នឹង គឺបញ្ហាខ្មាំង ហើយនិងបញ្ហាដែលថាត្រូវតែស្វែងរកអ្នកណាដែលប្រឆាំងនឹងអង្គការនោះ។ លោកស្រីអាចប្រាប់ឈ្មោះបានទេ? ឈ្មោះ ថាតើកម្មាភិបាលណាជាអ្នកពីចំណុចហ្នឹងប្រាប់លោកស្រី?

**ឆ៖** ខ្ញុំចាំមិនបានទេ ព្រោះច្រើនគ្នា។ ចាំបានថាត្រឹមការទទួលអប់រំ ឲ្យអប់រំពិនិត្យមើលតែប៉ុណ្ណឹងឯង។

**ស៖** ជាថ្មីម្តងទៀត ខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោកស្រីកាលពីមុន។ លោកស្រីនិយាយថា អ្នកមកពីភ្នំពេញដែលត្រូវបានជម្លៀសមកឃុំរបស់លោកស្រីហ្នឹងត្រូវបានសម្លាប់ចោល ពីព្រោះថាគេចោទថា ប្រឆាំងនឹងអង្គការ។ ខ្ញុំនឹងដកស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី គឺចម្លើយ២៤២។ ដកស្រង់ជាភាសាអង់គ្លេស។

[១៥:១៤:៤៥]

(អានភាសាអង់គ្លេស)៖"ចាស មានការកាប់សម្លាប់ច្រើន។ អស់លោកជាខ្មែរ អស់លោកច្បាស់ជាដឹងទាំងអស់គ្នា។ គឺយើងមានការបាត់បង់ដូចគ្នា។ សូម្បីតែខ្ញុំក៏បាត់បង់ដែរ។ ប្រជាជនមកពីភ្នំពេញ

ហើយត្រូវបានជម្លៀសទៅដល់កន្លែងខ្ញុំ ត្រូវបានគេសម្លាប់។ ប្រជាជនទាំងអស់នោះ ត្រូវបានគេរាយការណ៍ថា បានប្រឆាំងនឹងអង្គការ។ ហើយភូមិរាយការណ៍មកខ្ញុំ ហើយខ្ញុំរាយការណ៍បន្តទៀត។ រឿងប្រភេទនេះ កើតឡើងច្រើន"។ សូមបញ្ចប់ការដកស្រង់។

តើលោកស្រីដឹងដោយរបៀបណាអំពីជោគវាសនារបស់អ្នកភ្នំពេញដែលត្រូវបានជម្លៀសមកឃុំរបស់លោកស្រី ហើយដែលត្រូវបានគេសម្លាប់ចោលនោះ? អ្នកណាជាអ្នកនិយាយប្រាប់លោកស្រីអំពីរឿងនេះ? ហើយបើតាមការសន្និដ្ឋានរបស់លោកស្រីហ្នឹង ថាតើមានការចាប់ខ្លួនមនុស្ស ហើយនិងសម្លាប់ចោលប៉ុន្មាននាក់ដែរនៅក្នុងឃុំលោកស្រី?

**ឆ៖** ចាស ខ្ញុំមិនបានដឹងដែរ មិនដឹងបានប៉ុន្មាននាក់ដែរ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:១៧:០៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ លោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីអន្តរជាតិតំណាងឲ្យក្រុមជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងយើងនេះ។

**ស៖** ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរទៅកាន់លោកស្រី រហូតដល់បញ្ចប់រសៀលនេះ គឺត្រឹមម៉ោងបួន។ ជាដំបូង ខ្ញុំចង់បានការបំភ្លឺអំពីចំណុចមួយចំនួនពីលោកស្រី ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោកស្រីជាមេឃុំជាងទង។ តើលោកស្រីអាចជម្រាបបានទេថា តើនៅក្នុងឃុំរបស់លោកស្រីមានសហករណ៍ចំនួនប៉ុន្មាន?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ខ្ញុំអត់បានចាំទេ។ ខ្ញុំភ្លេចអស់ហើយ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំនឹងរំឭកការចងចាំរបស់លោកស្រី ពីព្រោះថាលោកស្រីបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតរួចហើយ គឺឯកសារ E319/12.3.2 ខ្ញុំសូមដកស្រង់ចម្លើយ១៤០ គឺថាមានសហករណ៍តែមួយទេនៅក្នុងឃុំរបស់លោកស្រី។ អ៊ីចឹងតើនៅពេលដែលខ្ញុំដកស្រង់នេះ ធ្វើឲ្យលោកស្រីចងចាំឡើងវិញទេ?

**ឆ៖** ចាស អត់ច្បាស់។ ស្តាប់អត់ច្បាស់។

**ស៖** ខ្ញុំនឹងសួរឡើងវិញលោកស្រីសាក្សី នៅក្នុងកំណត់ហេតុនៅចំពោះមុខចៅក្រមស៊ើបអង្កេត លោកស្រីបានឆ្លើយថា មានសហករណ៍តែមួយគត់នៅក្នុងឃុំរបស់លោកស្រី។ តើលោកស្រីនឹកឃើញទេ ចំណុចនេះ?

**ឆ៖** ចាស--

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិពិនិត្យមើល ដូចជាដកស្រង់មិនត្រូវទេ។ ក្នុងភូមិមួយមានសហករណ៍ ឬក្នុងឃុំមួយមានសហករណ៍មួយ។ ចម្លើយជាភាសាខ្មែរ ក្នុងភូមិមួយមានសហករណ៍មួយ។

[១៥:២០:០០]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សម្រាប់ជាកំណត់ហេតុតុលាការ ខ្ញុំនឹងអានចម្លើយ ហើយនិងខ្ញុំចូលទៅចំណុចផ្សេង ពីព្រោះថាវាមិនមែនជាអត្ថិភាពរបស់ខ្ញុំទេ។ ខ្ញុំសូមដកស្រង់នៅទីនេះ គឺចម្លើយ១៤០ ខ្ញុំនឹងអានសំណួរហ្នឹងជាភាសាអង់គ្លេស៖ “ឃុំគឺមានសហករណ៍តែមួយតែប៉ុណ្ណោះ”។ លោកស្រីសាក្សី តើលោកស្រីមានចាំទេថា លោកស្រីមានតួនាទីអ្វីទេនៅពេលដែលគេជ្រើសរើស ឬក៏តែងតាំងមេឃុំនោះ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** សូមម្តងទៀត។

**ស៖** តើលោកស្រីមានតួនាទីអ្វីទេ នៅពេលដែលគេជ្រើសរើស ឬតែងតាំងប្រធានសហករណ៍នោះ?

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ ប្រធានសហករណ៍ និងឃុំវាដោយឡែកពីគ្នា តែខ្ញុំស្តាប់អត់ច្បាស់។

**ស៖** ខ្ញុំនិយាយអំពីប្រធានសហករណ៍ តើលោកស្រីមានតួនាទីអ្វីទេ នៅពេលដែលគេជ្រើស

រើស បោះឆ្នោតជ្រើសរើស ឬក៏តែងតាំងប្រធានសហករណ៍ណាមួយនៅក្នុងឃុំរបស់លោកស្រីនោះ?

**ធ៖** ចាស ខ្ញុំមាននាទីអប់រំ ធ្វើម៉េចឱ្យប្រធានសហករណ៍ស្មោះត្រង់ជាមួយប្រជាជន ពិសេសក្នុងការហូបចុក ការអប់រំគ្នា កុំឱ្យខិលខូច កប់ចានកប់ឆ្នាំង ជាដើម។ល។ ចាស មានតែប៉ុណ្ណឹង។

[១៥:២២:៣៤]

**ស៖** សូមអរគុណ។ កាលពីព្រឹកមិញនេះ នៅពេលចាប់ផ្ដើមសវនាការ លោកស្រីនិយាយអំពីសហករណ៍នៅក្នុងឃុំរបស់លោកស្រី លោកស្រីបាននិយាយផងដែរ ខ្ញុំសូមដកស្រង់ លោកស្រីនិយាយអំពីកងកុមារ កងស្ត្រី និងកងយុវជន។ តើលោកស្រីបានចាំទេថា កាលពីព្រឹកមិញនេះលោកស្រីបានឆ្លើយអ៊ីចឹងនោះ?

**ធ៖** ចាស។

**ស៖** តើលោកស្រីធ្លាប់ទទួលបញ្ជាឱ្យបែងចែកស្ត្រី បុរស ហើយនិងយុវជនឱ្យនៅដាច់ដោយឡែកពីគ្នាទេ?

**ធ៖** ចាស។

**ស៖** តើគេមានពន្យល់ប្រាប់លោកស្រីទេថា ហេតុអ្វីបានជាចាំបាច់ត្រូវបំបែកបុរស ស្ត្រី កុមារ និងយុវជនឱ្យនៅបែកពីគ្នានោះ?

**ធ៖** ចាស បានជាគេបំបែកយ៉ាងនេះ តាមការអប់រំខាងលើ ថាកុំឱ្យនៅច្របូកច្របល់គ្នា។ ទី១ គឺខ្លាចខូចប៉ះពាល់សីលធម៌ នាទីបុរស ឬក៏យុវជន-យុវនារី ឯកុមារក៏គ្រប់គ្រងផ្សេងដើម្បីឱ្យមានការរៀនសូត្រខ្លះតាមពេលសម្រាក។

**ស៖** នៅពេលដែលលោកស្រីនិយាយថា ត្រូវបំបែកកុមារចេញ ព្រោះថាអាចអប់រំបាននៅពេលសម្រាកនោះ លោកស្រីអាចពន្យល់បានទេថា តើគេធ្វើរបៀបម៉េចដែរនៅក្នុងឃុំរបស់លោកស្រីហ្នឹងដែលថាយកកុមារទៅអប់រំនៅពេលដែលសម្រាកហ្នឹង?

[១៥:២៤:៤៤]

**ធ៖** ចាស អប់រំ គឺចង់និយាយថា ឱ្យបានរៀនអក្សរនៅពេលថ្ងៃ ពេលសម្រាកពីការងារ ឱ្យកុមារបានរៀនអក្សរសាស្ត្រ។

**ស៖** តើលោកស្រីធ្លាប់ទទួលបញ្ជាឱ្យកុមារធ្វើការទេ?

**ធ៖** ចាស ខ្ញុំទទួលតាមការណែនាំខាងលើ តែមិនធ្វើការធ្ងន់ធ្ងរពេកទេល្មម មិនដូចមនុស្សចាស់ទេ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលបន្តិចទៀតនេះ។ នៅពេលដែលសហព្រះរាជអាជ្ញាសួរបញ្ចប់នោះ គឺលោកស្រីថា លោកស្រីសោកស្ដាយបំផុតនោះគឺថា ដែលថាមិនអាចរស់នៅជាមួយសមាជិកគ្រួសារបាន។ នេះជាអ្វីដែលលោកស្រីសោកស្ដាយ។ អ៊ីចឹងលោកស្រីអាចពន្យល់ឲ្យបានលើសពីហ្នឹងទៀតទេថា ហេតុអ្វីបានជានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យគេមិនឲ្យមនុស្សរស់នៅជាមួយសមាជិកក្រុមគ្រួសាររបស់ខ្លួននោះ?

**ឆ៖** ចាស ខ្ញុំអាចយល់ថា រស់នៅតាមផ្នែកដូចជាបានជម្រាបខាងដើម តាមកងកុមារ កងស្ត្រី កងយុវជន និងកងយុវនារី ហេតុដូច្នេះបានអត់បាននៅជួបជុំកូនចៅប្ដីប្រពន្ធ។

[១៥:២៦:៥៥]

**ស៖** សូមអរគុណ។ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទៅនឹងចម្លើយមួយដែលយើងបានស្ដាប់នៅក្នុងសវនាការនេះ។ កាលពីប៉ុន្មានថ្ងៃមុនយើងបានស្ដាប់លោក ពេជ្រ ជឹម គឺនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០១៥ ប្រហែលជាម៉ោង០៩:៤១នាទី។ ពេលនោះ យើងបានសួរសំណួរទៅកាន់លោក ពេជ្រ ជឹម អំពីមូលហេតុអ្វីបានជាគេបង្កើតជាកងៗអ៊ីចឹងនោះ? ហើយពេលនុ៎ងគាត់បានឆ្លើយដូចតទៅ៖ "កងត្រូវបានបង្កើតឡើងដើម្បីឲ្យមានកម្លាំងធ្វើការ។ យើងត្រូវដឹងថា អ្នកណាជាកុមារ អ្នកណាជាយុវជន អ្នកណាជាស្ត្រីនៅក្នុងសហករណ៍។ យើងត្រូវតែក្ដោបក្ដាប់កម្លាំងដែលយើងមាន យើងត្រូវតែដឹងថា អ្នកណាខ្លះខ្សិល អ្នកណាខ្លះឈឺ អ៊ីចឹងហើយយើងត្រូវតែក្ដាប់កម្លាំងយើងឲ្យបានច្បាស់"។ តើលោកស្រីយល់យ៉ាងណាដែរអំពីចម្លើយរបស់លោក ពេជ្រ ជឹម នៅក្នុងសវនាការនេះ?

**ឆ៖** ចាស ខ្ញុំឯកភាព។

**ស៖** សូមអរគុណ។ នៅថ្ងៃដដែលនោះ គឺមុននឹងបន្តិចលោក ពេជ្រ ជឹម នៅពេលដែលគេសួរសំណួរពាក់ព័ន្ធនឹងវិន័យនៅក្នុងសហករណ៍ គាត់ឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "វិន័យគឺតឹងតែងណាស់ គឺប្រជាជនត្រូវតែគោរពតាមមិនអាចធ្វើអ្វីដោយសេរី ដោយខ្លួនឯងទេ យើងត្រូវធ្វើការជាមួយគ្នា ដើម្បីបង្កបង្កើនផលឲ្យបានតាមផែនការ។ មិនមាននរណានៅទំនេរទេ ត្រូវតែបំពេញការងារទាំងអស់គ្នា"។ អ៊ីចឹងតើលោកស្រីឯកភាពជាមួយនឹងចម្លើយរបស់លោក ពេជ្រ ជឹម ទេ?

[១៥:២៩:០៤]

**ឆ៖** ចាស ព្រោះពេលនោះ ពេលដែលខ្វះខាតស្បៀង ខ្វះខាតឧបត្ថម្ភប្រជាជនមកច្រើន ដល់តែរៀបចំបែបនេះ។

**ស៖** សូមអរគុណលោកស្រី។ តើអ្នកមូលដ្ឋានមានបានទទួលបញ្ជាឲ្យតាមដានប្រជាជនថ្មីទេ?

**ឆ៖** ចាស អាចៗមានតាមដានចាស ប៉ុន្តែមិនមែនខ្ញុំលើកបែបនេះក៏ខ្ញុំសូមមានយោបល់បន្ថែមថា មិនមែនខុសតែប្រជាជនថ្មីទេ ចាស់ក៏មានតាមដានដែរចាស។

**ស៖** សូមអរគុណ។ អ៊ីចឹង អ្នកណាជាអ្នកតាមដាមអ្នកមូលដ្ឋាន?

**ឆ៖** ចាស មានក្រុម មានភូមិ ដែលរៀបចំតាមក្រុមហ្នឹងគឺតាមដានគ្នាទៅវិញទៅមក។ មិនមែនតាមដានតែម្នាក់ៗ ជាបុគ្គលទេ។

**ស៖** សូមអរគុណលោកស្រីសាក្សី។ ខ្ញុំដូចជាមិនស្តាប់ការបកប្រែ -- ខ្ញុំស្តាប់ការបកប្រែជាភាសាបារាំងអត់យល់ទេ គឺដូចជាឮថា មានសមាជិកភូមិជាអ្នកតាមដានអ្នកមូលដ្ឋាន។ អ៊ីចឹង ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ លោកស្រីអាចពន្យល់បានទេ ពាក្យថា "តាមដាន ឬក៏ស្វែងរកនោះ"?

[១៥:៣១:១៨]

**ឆ៖** ចាស ការតាមដានមិនមែនសំដៅតែសមាជិកភូមិ ឬប្រធានភូមិ ឬក៏មេក្រុមទេ គឺមានសិទ្ធិតាមដានទាំងអស់គ្នា។

**ស៖** សូមអរគុណ។ អ៊ីចឹងតើមានអ្នកមកពីខាងថ្នាក់នោះ មកតាមដានអ្នកដែលធ្វើការនៅតាមការដ្ឋានទេ?

**ឆ៖** តែការដ្ឋានធ្វើរួមគ្នា ហ្នឹងការតាមដានជាការងារសម្ងាត់ ខ្ញុំក៏មិនបានយល់ដែរ ព្រោះការងារការដ្ឋានមានទាំងស្រុក មានទាំងឃុំ មានទាំងភូមិរួមគ្នា ចាស។

**ស៖** សូមអរគុណ។ តើលោកស្រីដឹងដោយរបៀបណាថាមនុស្សពីថ្នាក់ស្រុក តាមដានមនុស្សរួមទាំងអ្នកចាស់ផង អ្នកមូលដ្ឋានផងដែរនោះ។ អ៊ីចឹងពួកលោកស្រីទទួលបានព័ត៌មាននោះពីអ្នកណាដែរ?

**ឆ៖** ចាស ព័ត៌មានមិនបានទទួលពីអ្នកណាទេ គឺជាការពិត។ សូម្បីតែខ្លួនខ្ញុំ ក៏ខ្ញុំនៅភ័យខ្លាចគេតាមដានដែរ។ នេះជាការពិត។

[១៥:៣៣:២៤]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមបន្តទៅមុខទៀត ពាក់ព័ន្ធទៅនឹងការតាមដានដដែលហ្នឹង ហើយខ្ញុំចង់សួរអំពីវត្តមានរបស់ឈ្លបនៅក្នុងឃុំរបស់លោកស្រី ដែលយើងបាននិយាយនៅថ្ងៃនេះរួចមកហើយ។ តើលោកស្រីអាចជម្រាបបានទេថា តើមានឈ្លបប៉ុន្មាននាក់នៅក្នុងឃុំរបស់លោកស្រី?

**ឆៈ** ចាស ឈ្លបមិនទៀង ព្រោះឈ្លបនេះ គឺជ្រើសរើសចេញភូមិ។ ដូច្នេះខាងស្រុកត្រូវការ គឺដកអត់កំណត់។ អត់មានកំណត់ចំនួនទេ ផ្លាស់ប្ដូរជារៀងរហូត។

**សៈ** តើលោកស្រីអាចដឹងទេថា មានឈ្លបនៅតាមភូមិនីមួយៗនៅគ្រប់ឃុំ ឬក៏គេរៀបចំកងឈ្លបហ្នឹង តាមរបៀបផ្សេងទេ?

**ឆៈ** ខ្ញុំអត់យល់សំណួរ។ ចាស សូមម្ដងទៀត អត់យល់។

**សៈ** ខ្ញុំនឹងសួរឡើងវិញ។ ខ្ញុំចង់ដឹងថាតើនៅភូមិនីមួយៗហ្នឹង មានឈ្លបដែរឬទេ? ឬក៏ថាការរៀបចំឈ្លបនោះ ផ្សេងពីហ្នឹងទេ?

**ឆៈ** ឈ្លបមានតែក្នុងឃុំ ប៉ុន្តែក៏នៅតាមភូមិដែរ តាមស្នាក់ភូមិនេះខ្លះ ជួនកាលភូមិនោះអីចឹងវាមិនទៀង ចល័ត ចាស។

**សៈ** សូមអរគុណ ថាតើឈ្លបទាំងអស់នេះមានតួនាទីធ្វើអ្វីដែរ?

**ឆៈ** ចាស ឈ្លបទាំងអស់ តួនាទីឈ្លបមានច្រើន។ ១) ការពារសន្តិសុខ ក្រែងមានខ្មាំងសត្រូវមកពីក្រៅ ឬក៏មានបញ្ហាអីផ្សេងៗ។ ហ្នឹងមួយ ទី២ទៀត ក៏ឈ្លបនេះ ក៏មិនមានតួនាទីតែការពារសន្តិសុខទេ គឺមាននាទីបង្កើនផលដូចកសិករដែរ។

[១៥:៣៦:៥០]

**សៈ** ថាតើឈ្លប គាត់ធ្វើការងារនៅពេលយប់ ឬក៏នៅពេលថ្ងៃ តើលោកស្រីអាចរៀបរាប់ឲ្យបានលម្អិតដែរឬទេ ថាតើគេត្រួតពិនិត្យ ឬក៏តាមដានហ្នឹង គេតាមដានដោយរបៀបណា សូមលោកស្រីរៀបរាប់ឲ្យលម្អិតបន្តិច?

**ឆៈ** ខ្ញុំពិបាករៀបរាប់ដែរ ជួនកាលក៏ធ្វើយប់ដើរយាម ដើរល្បាតអីចឹងទៅ។ ជួនកាល ក៏មានសភាពការណ៍អីចឹងទៅ ក៏ធ្វើថ្ងៃទៅ។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមដកស្រង់នូវសម្រង់នូវសម្រង់នៃការសម្ភាសជាមួយដើមបណ្ដឹងរដ្ឋប្បវេណីដែលបានមកផ្ដល់សក្ខីកម្មនៅទីនេះ ហើយខ្ញុំចង់ឲ្យលោកស្រីបញ្ចេញមតិថាតើនៅក្នុងឃុំរបស់លោកស្រី តើមានហេតុការណ៍ដូចគ្នាឬក៏អត់? នោះគឺសាក្សី ជូ គឹមឡុន គឺឯកសារ E1/253.1 ហើយគាត់បានបញ្ជាក់នៅម៉ោង ០៩:៤៩:៥២ “នៅពេលរសៀល ប្រសិនបើឈ្លបឃើញដុតភ្លើង ឬក៏ពន្លឺទុំង ពេលនោះពួកគេនឹងមកទីកន្លែង ហើយសួរថាតើយើងធ្វើអ្វី”។ ថាតើការតាមដានដែលឈ្លបធ្វើហ្នឹង គឺធ្វើដូចគ្នានៅឃុំរបស់លោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំមិនបានប្រាកដប្រជាដែរ ក្តាប់មិនបានសព្វដែរ ហើយក៏មិនបានចាំ។

**ស៖** សូមអរគុណលោកស្រី។ ថាតើឈ្លបមានកាន់កាំភ្លើងដែរឬទេ?

**ឆ៖** ចាស មានខ្លះ អត់ខ្លះ។

**ស៖** តើឈ្លបហ្នឹងបានកាំភ្លើងមកពីណាដែរ លោកស្រីដឹងទេ នៅពេលនោះ គេបានពីណាមក?

**ឆ៖** តាមការដឹង ខ្ញុំ កាំភ្លើងគឺបានមកពីខាងលើ ខាងស្រុក ខាងអីទៀត ខ្ញុំមិនដឹងទេ តែខ្ញុំដឹងត្រឹមស្រុក។

[១៥:៣៩:៥៨]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ខ្ញុំចង់សួរពីសំណួរទូទៅពាក់ព័ន្ធនឹងអ្វីដែលលោកស្រីបានធ្វើនៅថ្នាក់ស្រុក។ លោកស្រីនិយាយថាលោកស្រីទទួលខុសត្រូវខាងកិច្ចការនារី។ តើលោកស្រីអាចរៀបរាប់បានទេថាតើវាមានបញ្ហាអ្វី ឬក៏មានការងារអ្វីខ្លះដែលលោកស្រីចូលរួមពាក់ព័ន្ធនៅការកិច្ចការនារីនោះ?

**ឆ៖** ចាស ខ្ញុំសូមមានយោបល់។ ការដែលខ្ញុំបាននិយាយថា ខ្ញុំគ្រប់គ្រងខាងនារី គឺបានអប់រំនារីអំពីសីលធម៌ អំពីការរស់នៅ ទី១។ ទី២ទៀត អប់រំធ្វើការងារ រួមធ្វើការងារបង្កបង្កើនផលដើម្បីដោះស្រាយជីវភាពខ្លួនឯង និងប្រជាជន។ នេះការយល់ដឹងរបស់ខ្ញុំ ខ្ញុំក៏មិនចាំបានអស់ដែរព្រោះភ្លេច។

**ស៖** សូមអរគុណ។ នៅពេលដែលគេស្តាប់ចម្លើយ គឺនៅពេលដែលអ្នកស៊ើបអង្កេតបានសួរ គឺសំណួរ១១០របស់លោកស្រី "ហើយខ្ញុំសូមនិយាយថា ស្ត្រី ឬក៏នារីភាគច្រើនគឺផ្នែកកុមារ មនុស្សចាស់ ឬអប់រំប៉ុណ្ណោះ"។ ដូច្នេះ តើលោកស្រីអាចនឹកឃើញដែរឬទេ ហើយតើលោកស្រីអាចបញ្ជាក់បានដែរឬទេ ថានេះគឺការងារដែលលោកស្រីធ្វើការភាគច្រើននៅក្នុងការងារ?

**ឆ៖** ខ្ញុំនឹកមិនឃើញ។

[១៥:៤២:២៧]

**ស៖** សូមអរគុណ។ តើលោកស្រីអាចពន្យល់បានទេ ថាតើស្ថានភាពការងាររបស់ស្ត្រីនៅក្នុងកងផ្សេងៗគ្នានៅក្នុងឃុំរបស់ស្រីហ្នឹងមានលក្ខណៈដូចម្តេចដែរ? តើស្ថានភាពការងាររបស់ស្ត្រីដែលលោកស្រីទទួលខុសត្រូវហ្នឹងមានលក្ខណៈយ៉ាងដូចម្តេចដែរ? ខ្ញុំសួរលោកស្រីម្តងទៀត។ ថាតើលក្ខខណ្ឌការងាររបស់ស្ត្រី ខុសពីលក្ខខណ្ឌការងាររបស់បុរសដែរឬទេ?

**ឆ៖** ចាស ការងារស្ត្រី គឺធ្វើការងារស្រាលជាងបុរស។

**ស៖** ថាតើនៅពេលដែលស្ត្រីមានផ្ទៃពោះ ថាតើមានអ្វីកើតឡើងថា ស្ត្រីហ្នឹងត្រូវធ្វើការរហូតទៅដល់ពេលឆ្លងទន្លេ ឬក៏មានការអនុញ្ញាតអនុគ្រោះអ្វីផ្សេង?

**ឆ៖** ចាស មានស្ត្រីដែលមានផ្ទៃពោះ គឺមានការអនុញ្ញាតឲ្យធ្វើការងារស្រាលៗដូចជា នៅក្នុងសហករណ៍ កន្លែងចុងភៅអីជាដើម ជួយធ្វើបន្លែ ជួយអី ការងារស្រាលៗចាស។

**ស៖** សូមអរគុណលោកស្រី។ យើងបានស្ដាប់សក្ខីកម្មផ្សេងៗគ្នា។ ហើយទាក់ទងទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ ខ្ញុំចង់លើកយកកំណត់ត្រារបស់ សាន ដែលយើងបានស្ដាប់ប៉ុន្មានសប្ដាហ៍មុន គឺអង្គជំនុំជម្រះបានស្ដាប់ គឺឯកសារ E1/281.1 ហើយគាត់បាននិយាយនៅប្រហែលម៉ោង ០១:៣១:៥៨ គឺថាគាត់ធ្វើការរហូតទៅដល់ពេលគាត់ឆ្លងទន្លេ។ គឺរហូតដល់ពេលគាត់សម្រាលកូនតែម្ដង។ តើលោកស្រីអាចប្រាប់បានដែរឬទេ ថាតើពេលខ្លះវាមានករណីបែបនេះដែរកើតឡើងនៅក្នុងឃុំរបស់លោកស្រី។ តើវាមានដែរឬទេ?

**ឆ៖** តាមការដែលខ្ញុំដឹង ក្រែងខ្ញុំមិនដឹង បើថាខ្ញុំដឹងដូចអត់មានឃើញអ៊ីចឹងទេ។ ក្រែងករណីដែលខ្ញុំមិនបានជួប ហើយក៏គេមិនបានរាយការណ៍ឲ្យដឹងផង។ នេះជាការពិត អត់មានធ្វើដល់សម្រាលទេ។

[១៥:៤៥:៤០]

**ស៖** សូមអរគុណ។ មុននេះបន្តិចលោកស្រីបាននិយាយថា ហេតុផលដែលកងកុមារត្រូវបានគេបង្កើតឡើង គឺដើម្បីអនុញ្ញាតឲ្យក្មេងៗទទួលបានការអប់រំ ដូច្នេះខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទាក់ទងទៅនឹងសក្ខីកម្មដែលយើងបានស្ដាប់នៅទីនេះ។ គឺយើងបានស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងហោចណាស់បីរូបដែលពួកគេនិយាយថា ពួកគេមិនអាចទៅ -- មិនបានចូលរៀន នៅពេលដែលពួកគេនៅក្នុងកងកុមារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមចាប់ផ្ដើមចម្លើយរបស់ អៀម យេន គឺឯកសារ E1/287.1 ហើយគាត់បាននិយាយថា គឺនៅប្រហែលជាម៉ោង០៩:៣៧ព្រឹក។ “នៅពេលនោះគឺមិនមានសាលា អ្វីដែលខ្ញុំអាចធ្វើបាន គឺធ្វើការងារសុទ្ធ”។ ហើយយើងបានស្ដាប់ឮសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបឈ្មោះ ប៊ុន សារឿន គឺឯកសារ E1/288.1 ហើយគាត់បាននិយាយនៅប្រហែលម៉ោង១០:៤៨ព្រឹក “គេប្រាប់យើងថា យើងត្រូវរៀនអាន និងរៀនសរសេរ ប៉ុន្តែនៅក្នុងកងរបស់ខ្ញុំ គឺថាយើងធ្វើការងារសុទ្ធ គឺថាគ្រាន់ គឺអត់មានធ្វើអ្វី មានតែធ្វើការងារ ហើយនិងហូប”។ ហើយបណ្ដឹងដដែលនេះ បាននិយាយថា “ខ្ញុំសោកស្ដាយយ៉ាងខ្លាំង ហើយការល្ងង់ខ្លៅរបស់ខ្ញុំគឺបណ្ដាល

មកពីរបបដោយសារតែពីនៅក្មេង ខ្ញុំមិនបានទៅរៀនទើបធ្វើឲ្យខ្ញុំល្ងង់ខ្លៅ"។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកស្រីមេធាវី!

សូមអញ្ជើញមេធាវី គង់ សំអុន!

[១៥:៤៧:៣៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួររបស់សហមេធាវីនាំមុខអន្តរជាតិ ដោយហេតុថាការលើកឡើងនូវសំណួរនេះ គឺជាផ្នែកជាប់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់នៃបទល្មើស ដែលមិនអាចយកមកធ្វើជាសក្ខីកម្មតតាំងជាមួយនឹងសាក្សី ដើម្បីបញ្ជាក់ពីអង្គហេតុនោះបានទេ។ បាទ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមិនយល់អំពីការជំទាស់នោះទេលោកប្រធាន។ ដូច្នេះខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំគ្រាន់តែចង់ផ្តល់ឱកាសដល់សាក្សីដើម្បីឲ្យឆ្លើយ ប៉ុន្តែឥឡូវនេះខ្ញុំបន្តទៅមុខទៀត។ ខ្ញុំមានសំណួរមួយចំនួន--

**ប្រធានអង្គជំនុំ៖**

ឈប់សិន កុំអាល។! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ ដើម្បីឲ្យយល់ច្បាស់ពីការជំទាស់របស់ខ្ញុំបាទ ខ្ញុំបាទសូមលើកទាក់ទងនឹងឯកសារ E319/7 ដែលជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ទាក់ទងនឹងចំណុច (គ)។ បាទ ខ្ញុំសូមអានជូន "គ្រប់ពេលទាំងអស់--" សូមទោស ខ្ញុំលើកចំណុចខុស។ សូមពេលបន្តិច--

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ប៉ុន្តែខ្ញុំសូមអនុញ្ញាតបន្តទៅមុខទៀត ដោយសារតែខ្ញុំមិនមានពេលវេលា ហើយសហភាតារបស់ខ្ញុំ គាត់អាចរកឯកសារហ្នឹងតែឯងចុះ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ឥឡូវនេះខ្ញុំនិយាយអំពីបញ្ហាចំណីអាហារ គឺថាមានកង្វះចំណីអាហារ។ ក្នុងនាមជាមេឃុំ តើលោកស្រីមានតួនាទីអ្វីពាក់ព័ន្ធទៅនឹងបញ្ហាចំណីអាហារ ក៏ដូចជាការបែងចែកចំណីអាហារនេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៥០:០៣]

**លោក គង់ សំអុន៖**

បាទ អធ្យាស្រ័យលោកប្រធាន ខ្ញុំរកឃើញហើយគឺឯកសារ E236/5/3/2 ជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ ដែលជាលិខិតផ្ញើជូនគ្រប់ភាគីទាំងអស់នៅក្នុងកម្មវត្ថុទាក់ទងទៅនឹងការបង្គាប់របស់អង្គជំនុំជម្រះឱ្យមានការរៀបចំផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-13 ហើយក្នុងផ្នែកមួយខ្ញុំសុំដកស្រង់៖ "គោលបំណងនៃសវនាការស្ដីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មមកលើជនរងគ្រោះ គឺដើម្បីផ្ដល់ឱកាសឱ្យដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការបង្ហាញភស្តុតាងដែលពាក់ព័ន្ធនឹងសំណងសមូហភាព និងផ្លូវចិត្ត វិធាន២៣(១)(ខ) នៃវិធានផ្ទៃក្នុង"។ បាទ សូមអរគុណ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំនឹងស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺនៅពេលក្រោយ ដូចដែលខ្ញុំនិយាយអ៊ីចឹង ខ្ញុំមិនយល់អំពីការជំទាស់របស់សហភាគីរបស់ខ្ញុំទេ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំសូមបន្តទៅមុខទៀត។ ប្រហែលជាខ្ញុំត្រូវសួរសំណួរឡើងវិញហើយ ដោយសារតែមានការរំខាន។

**ស៖** លោកស្រីបានប្រាប់កន្លងមកអំពីកង្វះរបៀបរបបអាហារ។ ខ្ញុំចង់សួរលោកស្រីដូចតទៅនេះ ក្នុងនាមជាមេឃុំ តើលោកស្រីមានតួនាទីអ្វីទាក់ទងទៅនឹងការបែងចែករបបអាហារនោះ?

[១៥:៥២:០៨]

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ការបែងចែកម្ហូបអាហារមិនមានអីលំបាកទេ គឺពេលនោះ ការខ្វះខាតគឺមានមែនតែនៅក្នុងមូលដ្ឋានខ្ញុំ ការហូបចុកបាយទឹកអត់សូវខ្វះទេ លើកលែងតែដល់ពេលដែលចុងរដូវជិតច្រូតកាត់អាចហូបបាយជ្រាយខ្លះ នេះចំពោះម្ហូប គឺមានការខ្វះខាតហើយ ព្រោះមនុស្សច្រើន ចាស។

**ស៖** សូមអរគុណ។ ចាតើអ្នកធ្វើ ឬក៏កម្មករ កសិករ គាត់មានតវ៉ាទេអំពីកង្វះអាហារ?

**ឆ៖** ចាស មានតវ៉ាចេះតែមានហើយ ប៉ុន្តែមិនដឹងបានមកពីណា បើខ្វះខាត ខ្ញុំក៏ដោះស្រាយអស់លទ្ធភាពហើយ តែវាខ្វះ។

**ស៖** ពាក់ព័ន្ធទៅនឹងកង្វះម្ហូបអាហារដែលលោកស្រីបាននិយាយ ថាតើមានប្រជាជនលួចអាហារ ឬក៏លួចរបស់ហូបចុកអីដែរឬទេ?

**ឆ៖** ចាស អាចមានលួច។

**ស៖** តើមានអ្វីកើតឡើងនៅពេលដែលគេរកឃើញអ្នកដែលលួចអាហារ ឬក៏លួចរបស់ហូបចុកនោះ?

**ឆ៖** ចាស គេឃើញគេអាចចាប់ ឬក៏គេនាំមកឲ្យភូមិអប់រំ ឬក៏រហូតដល់កន្លែងឃុំក៏មាន។

**ស៖** សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីនៅចម្លើយ១៤៧ ហើយខ្ញុំសូមដកស្រង់៖ "គឺថាមានចំណីអាហារតិចតួចបំផុត ការលួចគឺចាត់ទុកជាបទឧក្រិដ្ឋតូច បទល្មើសស្រាល"។ តើលោកស្រីចាំដែរឬទេ ដែលនិយាយថា ការលួចរបស់ហូបបន្តិចបន្តួចនោះ គឺជាបទល្មើសស្រាល?

**ឆ៖** ចាស។

**ស៖** ថាតើលោកស្រីទទួលបានព័ត៌មាននេះដោយរបៀបណា? អ្នកណាជាអ្នកប្រាប់លោកស្រី? គឺថាប្រាប់លោកស្រី ដែលថាការលួចរបស់ហូបជាបទល្មើសស្រាល ថាតើលោកស្រីទទួលបានណែនាំពីថ្នាក់លើ ដែលថាបទល្មើសបែបណាត្រូវកំណត់ជាបទល្មើសស្រាល ល្មើសធ្ងន់អីជាដើមនោះ?

[១៥:៥៥:៥៨]

**ឆ៖** ចាស បានទទួលការអប់រំខាងលើ ការលួចរបស់ហូបចុក មកពីការខ្វះខាត ឃ្លាន អាហ្នឹងជាបទល្មើសដែរ តែស្រាល។ បទល្មើសធ្ងន់ គឺការទំនាស់ប្រឆាំង។ ដល់ខ្លះ កប់ចានកប់ឆ្នាំងក៏មានដែរ។

**ស៖** ដូច្នេះ ការលួចចានឆ្នាំង គឺថ្នាក់លើ គេចាត់ទុកជាបទល្មើសធ្ងន់ អ៊ីចឹងមែនទេ?

**ឆ៖** មិនថាជាធ្ងន់ពេកទេ ប៉ុន្តែគ្រាន់តែវាមិនដូចការលួចហូបចុក ក្នុងការខ្វះខាតហូបឃ្លាននោះ។ ឃ្លាននោះគឺកំណត់ថាជាបទល្មើសស្រាល មកពីឃ្លាន។ ឯការកប់ចាន កប់ឆ្នាំង យកទៅក្រវាត់ចោលអាហ្នឹងជា ថាជាប្រឆាំង។

**ស៖** សូមអរគុណ។ ហើយយោងតាមការណែនាំរបស់លោកស្រីដែលលោកស្រីទទួលពីថ្នាក់លើ ថាតើបទល្មើសអ្វីដែលជាបទល្មើសធ្ងន់ជាងគេបំផុត?

**ឆ៖** បទល្មើសដែលធ្ងន់ជាងគេបំផុត គឺបទប្រឆាំង មានការលួចវ៉ៃ លួចបោក លួចបំផ្លាញទ្រព្យសម្បត្តិរបស់សហករណ៍អីជាដើម ចាស។

[១៥:៥៨:២៨]

**ស៖** ថាតើលោកស្រីធ្លាប់ឃើញបទល្មើសធ្ងន់ធ្ងរ ឬក៏ធ្លាប់ឃើញបទល្មើសបំផ្លាញទ្រព្យសម្បត្តិសហករណ៍ដែរឬទេ? តើលោកស្រីអាចផ្តល់ឧទាហរណ៍បានដែរឬទេ?

**ផ៖** ចាស ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ តែខ្ញុំបានទទួលដំណឹង ចាស។

**ស៖** ឥឡូវនេះ យើងមានឧទាហរណ៍នៃបទល្មើសធ្ងន់ធ្ងរ ដូចជាការបំផ្លាញទ្រព្យសម្បត្តិសហករណ៍ជាដើម តើលោកស្រីមានឧទាហរណ៍នៃការបំផ្លាញទ្រព្យសម្បត្តិសហករណ៍ដែរឬទេ?

**ផ៖** ខ្ញុំបានឧទាហរណ៍ជូនខាងដើមហើយ គឺបំផ្លាញទ្រព្យសម្បត្តិសហករណ៍ គឺបំផ្លាញទ្រព្យសម្បត្តិរួម ជាឧបករណ៍ប្រើប្រាស់ ឬក៏ជាឆ្នាំងចាន ឬក៏ជាសម្ភារៈអីផ្សេងៗ ហ្នឹងវាមានជាហូរហែ។

**ស៖** សូមអរគុណលោកស្រី ខ្ញុំមានសំណួរពីរបីបន្ថែមទៀត ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។ នៅព្រឹកនេះ គឺយើងបានស្តាប់ឮអំពីការរៀបការ និងការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ លោកស្រីបានប្រាប់យើងថា លោកស្រីបានទទួលការបញ្ជាច្បាស់លាស់ពីថ្នាក់លើពាក់ព័ន្ធទៅនឹងអ្វីដែលអាចចាត់ទុកថាជាបទល្មើសស្រាល បទល្មើសធ្ងន់ជាដើម។ តើលោកស្រីមានទទួលការបញ្ជា ការណែនាំពីថ្នាក់លើទាក់ទងនឹងការរៀបការដែរឬទេ?

**ផ៖** ចាស ការរៀបការ ដូចខ្ញុំជម្រាបពីព្រឹកកន្លងហើយ ការរៀបការជាបញ្ហាមួយដែលរៀបចំឡើងដោយសាមីខ្លួន ទី១។ ទី២ទៀត ដោយមានការរៀបចំសាកសួរ ឬក៏ផ្សំផ្គុំ អាហ្នឹងមាន ផ្សំផ្គុំជាប្តីប្រពន្ធឱ្យរៀបការ។ តែខ្លះក៏អាចយល់ព្រម ខ្លះក៏មិនយល់ព្រម។ នេះខ្ញុំបានជម្រាបខាងដើមហើយ ឯការសម្រេច ដូចខ្ញុំបានជម្រាបហើយ រាយការណ៍ជាគូនារីបុរស ហើយបញ្ជូនទៅខាងលើសម្រេចគាត់តបមកវិញ យើងខ្ញុំនឹងអនុវត្ត។

[១៦:០១:៤៩]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ខ្ញុំសូមអាននូវចម្លើយរបស់ ពេជ្រ ជឹម នៅពេលដែលគាត់បានផ្តល់សក្ខីកម្មនៅថ្ងៃទី២៣ ខែមេសា គាត់បានផ្តល់នូវការពន្យល់នៅម៉ោង ០៩:២៤:៣៦វិនាទី ហើយគាត់និយាយថា "ប្រធានកងនារី ត្រូវចាត់ទុកថាជាម្តាយរបស់នារីៗទាំងអស់នោះ"។ ដូច្នេះ ខ្ញុំចង់ដឹងថាតើសមាជិករបស់កងដែលចង់រៀបការហ្នឹងត្រូវយល់ស្រប ឬក៏មិនយល់ស្រប។ តើលោកស្រីយល់ស្របដែរឬទេថា មេកងនារីហ្នឹង គឺជាម្តាយរបស់នារីទាំងអស់នេះ តើលោកស្រីអាចពន្យល់បានទេថាហេតុអ្វី?

**ឆ៖** ចាស ដែលមេកងនារីចាត់ទុកដូចជាម្ដាយរបស់នារី គឺត្រឹមត្រូវ។ ពីសម័យនោះ ភាគីច្រើន គេហៅមេកងហ្នឹងជាម៉ែដែរ គេហៅម៉ែទាំងអស់។ ដោយហេតុអ្វីបានជាគេហៅម៉ែ គឺការអប់រំរបស់មេកងនារីទៅលើសមាជិករបស់ខ្លួន គេថាមានការកក់ក្ដៅ ស្រឡាញ់រាប់អានអ៊ីចឹងទៅ អ៊ីចឹងហៅថាជាម៉ែហ្នឹងមួយ។ ទី២ទៀត ការរៀបចំគូស្រករ ក៏ចេញពីម៉ែប្រធាននារីហ្នឹងដែរ ដែលក្ដាប់បានថានារីនេះត្រូវរៀបចំជាមួយបុរសនោះ បើអាចត្រូវរ៉ូវគ្នាអ៊ីចឹងទៅ ហើយក៏រាយការណ៍មក។ នេះខ្ញុំសូមបញ្ជាក់។

**ស៖** សូមអរគុណ។ ថាតើមានដែរឬទេ ដែលថាអ្នកដែលត្រូវរៀបការ មិនដឹងថាតើអ្នកដែលខ្លួនរៀបការនោះគឺជាអ្នកណា?

**ឆ៖** ចាស ខ្ញុំអាចដឹង ដឹង បើខ្ញុំរៀបរាប់វាច្រើន តែខ្ញុំសូមសង្ខេបថា នៅតាមកងទ័ពគឺមានច្រើនរៀបចំដែលមិនស្គាល់ តែបើនៅមូលដ្ឋានគឺការជួបជុំគ្នាញឹកញាប់អាចស្គាល់គ្នា ចាស។ តែក៏មិនមែនបានល្អទាំងអស់ដែរ ខ្លះក៏មានបាក់បែកគ្នាដែរ រៀបហើយ។

**ស៖** សូមអរគុណ។ យើងបានស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅថ្ងៃ២៩ មករា គឺឈ្មោះ ជាំង ស្រីមុំ ដែលបានរៀបការនៅក្នុងរបបនោះ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅនិយាយម៉ោង១៣:៥៧នាទី គាត់និយាយថា គាត់មិនដែលស្គាល់ប្ដីរបស់គាត់នោះទេ។ ថាតើលោកស្រីធ្លាប់ឃើញថាមានស្ថានភាពបែបនេះកើតឡើងដែរឬទេ នៅក្នុងពេលនោះ?

[១៦:០៥:៥៤]

**ឆ៖** ចាស ខ្ញុំមិនបានថា មិនស្គាល់ទេ គ្រាន់បានថា ការរៀបចំហើយវាមានបាក់បែកគ្នា ដោយមិនត្រូវរ៉ូវគ្នា ហ្នឹងមាន។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរមួយចុងក្រោយ ដូច្នេះលោកប្រធានខ្ញុំសូមអនុញ្ញាតបន្តសំណួរមួយចុងក្រោយរបស់ខ្ញុំ។ លោកស្រីសាក្សី ថាតើសួរនាទីរបស់ឈ្លប គឺត្រូវតាមដានប្ដីប្រពន្ធដែលទើបរៀបការគ្នានៅយប់ដំបូងបន្ទាប់ពីរៀបការ? ថាតើវាកើតឡើងនៅក្នុងឃុំរបស់លោកស្រីដែរឬទេ?

**ឆ៖** ចាស បញ្ហាទាំងអស់នេះខ្ញុំអត់បានយល់ដែរ។ ខ្ញុំអត់បានយល់ ហើយក៏អត់បានដាក់ផែនការឲ្យតាមដានដែរ។ នេះបើកើតឡើង ដោយខ្ញុំអត់ដឹង។

**ស៖** សូមអរគុណលោកស្រី។ ជាចុងក្រោយនេះ ខ្ញុំចង់ដឹងថាតើថ្នាក់លើមានបានពន្យល់ថា គេ -- ថា១ត្រូវផ្ដល់កូនមកឲ្យអង្គការ ដូច្នេះអង្គការជាអ្នករៀបចំ។ តើលោកស្រីធ្លាប់ឮគេនិយាយថា កូន១ត្រូវផ្ដល់មកឲ្យអង្គការដែរឬទេ?

**ឆ៖** ដូចជាមិនមានទេ ខ្ញុំមិនបានឮទេ ព្រោះកូនប្រមូលមកទាំងអស់ហើយ មិនបានឮថាផ្តល់ឲ្យអង្គការទេ។

[១៦:០៨:២៥]

**លោកស្រី ម៉ារី ហ្គ្វីរ៉ូដ៍៖**

សូមអរគុណលោកស្រីសាក្សីដែលបានផ្តល់ឱកាសឆ្លើយសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំសូមបញ្ចប់ការសួរសំណួររបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកស្រី ខឹម បឿន។

**លោកស្រី ខឹម បឿន៖**

ចាស។

**ប្រធានអង្គជំនុំ៖**

ឥឡូវសវនាការថ្ងៃនេះដល់ពេលសមស្របសម្រាកហើយលោកស្រី ខឹម បឿន។ លោកស្រី ខឹម បឿន រួមទាំងមេធាវីប្រឹក្សាសាក្សីលោក ម៉ម រិទ្ធា អាចសម្រាកបានហើយ។ ហើយសវនាការនៅថ្ងៃស្អែកនឹងបន្តធ្វើចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយសូមអញ្ជើញលោកស្រី ខឹម បឿន រួមទាំងមេធាវីប្រឹក្សាចូលរួមផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅថ្ងៃស្អែកទៀត ពីកន្លែងដែលលោក លោកស្រីអង្គុយនោះ។ លោកស្រីអាចៗសម្រាកបានហើយ។

[១៦:០៩:២២]

លោក វ៉ិចទ័រ កូប៉េ អង្គជំនុំជម្រះមានបញ្ហាបន្តិច សូមសួរទៅលោក វ៉ិចទ័រ កូប៉េ ពីព្រោះអង្គជំនុំជម្រះបានទទួលនូវសំណើសុំមួយតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង ថាលោកបានដាក់នូវសំណើសុំមួយ សុំឲ្យអង្គជំនុំជម្រះលើកសវនាការដែលគ្រោងធ្វើនៅថ្ងៃសុក្រទី០៨ ខែឧសភា ទៅ -- នៅចុងសប្តាហ៍នេះទៅពេលក្រោយ ដោយលោកត្រូវមានការងារបន្ទាន់ត្រូវធ្វើដំណើរត្រឡប់ទៅប្រទេសរបស់លោក។ ហើយតើលោកអាចបញ្ជាក់ភាពជាបន្ទាន់នៃការងាររបស់លោក ដែលលោកដាក់សំណើសុំដើម្បីលើកសវនាការទៅថ្ងៃក្រោយ ដោយមិនសុំឲ្យអង្គជំនុំជម្រះធ្វើសវនាការនៅថ្ងៃសុក្រ ទី០៨ ខែឧសភា ចុងសប្តាហ៍នេះបានឬទេ? ពីព្រោះសំណើសុំរបស់លោកហាក់ដូចជាមានដាក់យឺតពេលបន្តិច ហើយអង្គជំនុំជម្រះក៏មានបំណងស្តាប់នូវមូលហេតុដែល -- នៃសំណើ

សុំនេះ ពីព្រោះអង្គជំនុំជម្រះសម្រេច ត្រូវសម្រេចលើបញ្ហានេះបន្ទាន់ ពីព្រោះហេតុផល គឺអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទសវនាការស្តាប់សក្ខីកម្មមួយរូបនៅចុងសប្តាហ៍នេះ តាមរយៈប្រព័ន្ធសោទស្សន៍ដែលបាននិងកំពុងដំណើរការនាពេលនេះ និងអូសទៅធ្វើរហូតដល់ចុងសប្តាហ៍។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ អាចបញ្ជាក់បានទេដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានសម្រេចលើបញ្ហានេះជម្រាបទៅភាគីពាក់ព័ន្ធ សាធារណជន ក៏ដូចជាអង្គភាពគាំពារសាក្សី និងអ្នកជំនាញ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំយល់ស្របថា -- ជាមួយអង្គជំនុំជម្រះថាយើងហាក់ដូចជាយឺតបន្តិច។ ហើយភាគីដទៃដែលបានស្នើសុំផ្អាកនៅពេលរសៀលថ្ងៃសុក្រ ដើម្បីឲ្យយើងធ្វើការសួរដេញដោល។ ដូច្នេះសំណើរបស់ខ្ញុំគឺថា ដោយសារស្ថានភាពសុខភាពរបស់បុគ្គលិក -- របស់ដៃគូជាតិរបស់ខ្ញុំគឺថាគាត់ប្រហែលជាដូចក្រុម ខៀវ សំផន អ៊ីចឹងដែរ គឺគាត់ត្រូវសួរដេញដោលទៅលើសាក្សីរូបនេះ។ ដូច្នេះ ខ្ញុំគិតថាវាមិនមែនជាចំណុច -- វាដូចជាគ្មានជម្រើសនោះទេ។ ដូចដែលអង្គជំនុំជម្រះបានដឹងថា មេធាវីថ្មីដែលជំនួសសហមេធាវីរបស់ខ្ញុំគឺថា មានមែន ប៉ុន្តែដោយសារតែសាក្សីដែលយើងត្រូវសួរដេញដោលនៅពេលខាងមុខនេះ ខ្ញុំគិតថា ក្នុងដំណាក់កាលនេះវាហាក់ដូចជាមិនអាចឲ្យលោក សុវណ្ណា មកសួរសាក្សីនៅក្នុងដំណាក់កាលចុងក្រោយបែបនេះទេ។ ហេតុដូច្នេះហើយ ដោយសារតែយើងស្នើសុំផ្អាកការសួរសាក្សី ប៉ុន្តែមិនមែនសួរនៅថ្ងៃសុក្រទេ ប៉ុន្តែសួរនៅពេលក្រោយនៅពេលណាដែលអង្គជំនុំជម្រះយល់ស្របថា យល់ថាល្អ។ ខ្ញុំទទួលស្គាល់ថាសំណើហ្នឹងវាយឺត ប៉ុន្តែយើងដាក់សំណើហ្នឹងដោយសារតែបញ្ហាសុខភាពរបស់លោក សុន អរុណ។

[១៦:១២:៥៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីឲ្យមានការបញ្ជាក់ច្បាស់គឺដើម្បីបញ្ហារៀបចំ គឺថាយើងធ្វើការស្តាប់ចម្លើយតាមរយៈវីដេអូសោតទស្សន៍ ហើយឥឡូវនេះក្រុមការងារគាត់រៀបចំរួចហើយ ដូច្នេះតើលោកអាចបញ្ជាក់បានឬទេថាហេតុអ្វីបានជាលោកមិនអាចធ្វើបាន?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដ ប៉ុន្តែខ្ញុំ -- និយាយតាមត្រង់ ខ្ញុំមិនចង់ប្រាប់ឲ្យពិភពលោកដឹងអំពីបញ្ហានេះទេ។ ខ្ញុំគ្រាន់តែអាចប្រាប់បានថា វាជាការងារបន្ទាន់ ហើយខ្ញុំដឹងការងារនេះយូរមកហើយ ប៉ុន្តែវាជាកាតព្វ-

កិច្ចរបស់ខ្ញុំ។ ប៉ុន្តែដូចដែលខាងមេធាវី ខៀវ សំផន ដូច្នេះដែរ ពួកគេ -- ដូច្នេះអ្វីដែលខ្ញុំអាចធ្វើបាន គឺធ្វើបានពីសហមេធាវីជាតិរបស់ខ្ញុំ ប៉ុន្តែបញ្ហាសំខាន់មួយគឺថា សហមេធាវីរបស់ជាតិខ្ញុំគាត់មិនអាចសួរសំណួរសាក្សីនៅថ្ងៃសុក្របាន។ ហើយសហមេធាវីជាតិរបស់ខ្ញុំថ្មីហ្នឹងក៏គាត់មិនទាន់អាចសួរសំណួរទៅបាន។ ដូច្នេះហើយទើបយើងលើកសំណើនេះនៅពេលយឺត ហើយខ្ញុំគិតថានេះគឺជាហេតុផល។ ហើយវាមាន -- វានឹងបង្កឲ្យមានជាបញ្ហា។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងត្រូវតែដោះស្រាយទាំងអស់គ្នា។

[១៦:១៤:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះមានភាគីដទៃទៀតមានមតិយោបល់អ្វីទេ លើសំណើសុំរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ នេះ?

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សម្រាប់ក្រុមមេធាវីលោក ខៀវ សំផន យើងអត់មានអីជំទាស់ទៅនឹងសំណើនេះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ចុះភាគីម្ខាងទៀត តើមានបញ្ហាដែរទេ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានគឺយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។ ពិតណាស់ វាគួរឲ្យសោកស្តាយណាស់ ពីព្រោះថាយើងបានរៀបចំសម្ភារៈអីហើយអស់ហើយ ហើយយើងគិតថាចង់ឲ្យបានទៅលឿន។ អានេះមិនមែនជាជំហរយើងទេ ដែលចង់ឲ្យលើកសវនាការនោះ ក៏ប៉ុន្តែអ្វីៗគឺសម្រេចទៅលើអង្គជំនុំជម្រះតែប៉ុណ្ណោះ។

[១៦:១៥:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់ និងបានបញ្ជាក់នូវសំណើសុំរបស់ខ្លួន របស់លោកមេធាវី វ៉ិចទ័រ កូប៉េ។ អង្គជំនុំជម្រះនឹងពិចារណាសម្រេចលើបញ្ហានេះ ឆាប់ៗខាងមុខនេះ អាចជម្រាបជូនភាគីនៅថ្ងៃនៅព្រឹកថ្ងៃស្អែក។

បាទ ឥឡូវនេះ សវនាការថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ច

ដំណើរសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែក ទី០៥ ខែឧសភា ឆ្នាំ២០១៥ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ យើងនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ខឹម ឿន តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេស -- ពីខេត្តបាត់ដំបងជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើង។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៧ នាទី)*